# រាជរដ្ឋាភិបាលកម្ពុជា

## របាយការណ៍

## ទស្សនកិច្ចសិក្សានៃគណៈប្រតិភូជាន់ខ្ពស់ក្រសួងមហាផ្ទៃ និង គ.ជ.អ.ប.
## នៅសហព័ន្ធស្វីស និងសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់



**ពីថ្ងៃទី២១ ដល់ថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២៤**

**រៀបចំដោយលេខាធិការដ្ឋាន គ.ជ.អ.ប. ដោយមានការគាំទ្រពី ISD/GIZ និង SDC**



# មាតិកា


**ក. សេចក្តីផ្តើម ........................................................ 1**

**១. គោលបំណងនៃឧស្សាហកិច្ចសិក្សា ............................................3**

**២. សមាសភាពគណៈប្រតិភូ ............................................3**

**៣. កម្មវិធីនៃឧស្សាហកិច្ចសិក្សា ............................................6**

**ខ. លទ្ធផលនៃឧស្សាហកិច្ចសិក្សា និងការសិក្សាស្រាវជ្រាវ ..................10**

**១. ប្រព័ន្ធអភិបាលកិច្ចនៅប្រទេសស្វីស ............................................10**

**១.១. អំពីទិដ្ឋភាពទូទៅនៃប្រទេសស្វីស ............................................10**

**១.២. ការរៀបចំរដ្ឋាភិបាលពហុកម្រិតនៅប្រទេសស្វីស ..................11**

**១.៣. មុខងារ ភារកិច្ច ទំនាក់ទំនងការងារ និងកិច្ចសហប្រតិបត្តិការអន្តររដ្ឋាភិបាល ............................................14**

១.៣.១. កិច្ចសហប្រតិបត្តិការតាមខ្សែបណ្តោយ ............................................16

១.៣.២. កិច្ចសហប្រតិបត្តិការតាមខ្សែទទឹង ............................................18

១.៣.៣. រដ្ឋបាលមូលដ្ឋាន៖ ស្វ័យតាព និងសិទ្ធិក្នុងការធ្វើសេចក្តីសម្រេចចិត្តកិច្ចការ និងមុខងាររបស់រដ្ឋាភិបាលមូលដ្ឋាន ............................19

១.៣.៤. ការត្រួតពិនិត្យ និងអធិការកិច្ច ............................................23

១.៣.៥. ការចូលរួមរបស់ប្រជាពលរដ្ឋ និងឧបករណ៍ប្រជាធិបតេយ្យ ............24

១.៣.៦. តួនាទី និងមុខងាររបស់សមាគមរដ្ឋាភិបាលមូលដ្ឋានប្រទេសស្វីស...28

១.៣.៧. ប្រព័ន្ធប៉ូលិសនៅប្រទេសស្វីស ............................................32

**២. ប្រព័ន្ធអភិបាលកិច្ចនៃប្រទេសអាល្លឺម៉ង់ ............................................35**

**២.១. អំពីទិដ្ឋភាពទូទៅនៃប្រទេសអាល្លឺម៉ង់ .................................35**
**២.២. ការរៀបចំរដ្ឋាភិបាលពហុកម្រិតនៅប្រទេសអាល្លឺម៉ង់.............35**
២.២.១. ប្រភេទអង្គភាពរដ្ឋបាលមូលដ្ឋាន.......................................38
២.២.២. ការរៀបចំស្ថាប័ននៅកម្រិតមូលដ្ឋាន .................................43
២.២.៣. កិច្ចការ និងមុខងារនានារបស់រដ្ឋាភិបាលមូលដ្ឋាន........................48
២.២.៤. ហិរញ្ញវត្ថុរដ្ឋាភិបាលមូលដ្ឋាន ...............................................51
២.២.៥. សេវាការពារប្រជាពលរដ្ឋនិងគ្រប់គ្រងគ្រោះមហន្តរាយ និងសេវាសង្គ្រោះបន្ទាន់ ....................................................................53
២.២.៦. ការចូលរួមរបស់ប្រជាពលរដ្ឋ .................................................56
២.២.៧. កិច្ចសហប្រតិបត្តិការខ្សែបណ្ដោយ និងខ្សែទទឹងរវាងរដ្ឋ និងរដ្ឋបាលមូលដ្ឋាន ..........................................................................58
២.២.៨. ការត្រួតពិនិត្យ ការធ្វើអធិការកិច្ច និងការត្រួតពិនិត្យផ្នែកច្បាប់ ........60
២.២.៩. ឌីជីថលតាវូបនីយកម្ម.............................................................63
២.២.១០. តួនាទី និងមុខងាររបស់សមាគមរដ្ឋាភិបាលមូលដ្ឋាន ....................65
**គ. មេរៀន និងបទពិសោធន៍សំខាន់ៗដែលគណៈប្រតិភូបានរៀនសូត្រ....66**
**ឃ. សេចក្ដីសន្និដ្ឋាន ..........................................................81**

## ក. សេចក្តីផ្តើម

**"កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ"** ឬហៅម្យ៉ាងទៀតថា **"កំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ"** គឺជាកំណែទម្រង់ស្នូលដ៏សំខាន់មួយក្នុងចំណោមកំណែទម្រង់ស្នូលសំខាន់ៗនានារបស់រាជរដ្ឋាភិបាល ជាអាទិ៍ កំណែទម្រង់រដ្ឋបាលសាធារណៈ កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កំណែទម្រង់ច្បាប់ និងកំណែទម្រង់ប្រព័ន្ធយុត្តិធម៌។ គោលបំណងសំខាន់នៃការធ្វើកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ គឺការបង្កើតវប្បធម៌ប្រជាធិបតេយ្យនៅមូលដ្ឋានដោយមានការចូលរួមយ៉ាងសកម្មពីប្រជាពលរដ្ឋ ការលើកកម្ពស់គុណភាពសេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន ដើម្បីឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងដែលមានលក្ខណៈដោយឡែកៗពីគ្នារបស់ប្រជាពលរដ្ឋនៅតាមមូលដ្ឋាននីមួយៗ សំដៅលើកស្ទួយគុណភាពជីវិតរបស់ប្រជាពលរដ្ឋ និងចូលរួមកាត់បន្ថយភាពក្រីក្រប្រកបដោយប្រសិទ្ធភាព។ រហូតមកដល់បច្ចុប្បន្ននេះ គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប.) បានដឹកនាំ សម្របសម្រួលរៀបចំ និងបញ្ចប់ការអនុវត្តកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ រយៈពេល១០ឆ្នាំ ដំណាក់កាលទី១ (២០១០-២០២០) និងកំពុងបន្តដឹកនាំសម្របសម្រួលអនុវត្តកម្មវិធីជាតិសម្រាប់រយៈពេល១០ឆ្នាំ ដំណាក់កាលទី២ (២០២១-២០៣០) ក្នុងគោលបំណងដើម្បីលើកកម្ពស់ការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យប្រកបដោយបរិយាប័ន្ន សមធម៌ និងយុត្តិធម៌ និងបន្តរួមចំណែកក្នុងការអនុវត្តយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១របស់រាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋសភា ដើម្បីឈានសម្រេចបាននូវចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០ ក្លាយជាប្រទេសដែលមានចំណូលកម្រិតខ្ពស់។

ទោះបីជាការអនុវត្តនូវកំណែទម្រង់នេះសម្រេចបាននូវសមិទ្ធផលធំៗជាច្រើនក៏ដោយ ក៏នៅមានបញ្ហាប្រឈមជាច្រើន ដោយសារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនៅក្នុងដំណាក់កាលនេះបានឈានទៅដល់ដំណាក់កាលស៊ីជម្រៅដែលមានលក្ខណៈស្មុគស្មាញ និងសាំញ៉ាំ ព្រមទាំងមានផលប៉ះពាល់ដល់សិទ្ធិអំណាច និងធនធានរបស់ស្ថាប័ន ជាពិសេសគឺការធ្វើឱ្យមានការផ្លាស់ប្តូរផ្នត់គំនិត និងរបៀបរបបបំពេញការងាររបស់មន្ត្រីឱ្យស្របទៅតាមបែបបទថ្មីនៃកំណែទម្រង់នេះដែលតម្រូវឱ្យមានការប្រកាន់ខ្ជាប់នូវឥរិយាបថជាមន្ត្រីបម្រើសេវាជូនប្រជាជននៅមូលដ្ឋានប្រកបដោយវិជ្ជាជីវៈ និងក្រមសីលធម៌យ៉ាងពិតប្រាកដ។ ទោះបីយ៉ាងនេះក្តី ផ្អែកលើគោលការណ៍គន្លឹះនៃអភិបាលកិច្ចល្អ និងការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យដោយមានការចូលរួមពីប្រជាជន ការធ្វើកំណែទម្រង់វិមជ្ឈការត្រូវបានទទួលស្គាល់ថាជាជម្រើសដ៏សមស្រប និងមានប្រសិទ្ធភាពបំផុតក្នុងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលសាធារណៈដែលប្រទេសជាច្រើនលើសកលលោកកំពុងប្រកាន់យក។

នៅក្នុងកិច្ចដំណើរការនៃការអនុវត្តកំណែទម្រង់ដ៏មានសារៈសំខាន់នេះ សាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ និងសហព័ន្ធស្វីសបានចូលរួមចំណែកយ៉ាងសំខាន់តាមរយៈការគាំទ្រផ្នែកបច្ចេកទេស និងធនធានតាំងពីដំណាក់កាលដំបូងជាច្រើនឆ្នាំកន្លងមក។ នាពេលបច្ចុប្បន្នប្រទេសទាំងពីរកំពុងចូលរួមគាំទ្រដល់ការអនុវត្តកម្មវិធីជាតិ ដំណាក់កាលទី២ តាមរយៈការផ្តល់ហិរញ្ញប្បទានរួមគ្នាលើការអនុវត្ត "កម្មវិធីធ្វើឱ្យប្រសើរឡើងដល់ការផ្តល់សេវាជូនប្រជាពលរដ្ឋនៅកម្ពុជា" ហៅកាត់ជាភាសាអង់គ្លេសថា ISD (Improved Service Delivery for Citizens in Cambodia) ដែលចាប់ផ្តើមអនុវត្តចាប់ពីខែមីនា ឆ្នាំ២០២២ រហូតដល់ខែធ្នូ ឆ្នាំ២០២៥ ដែលមានថវិកាសរុបប្រមាណ ១០,៧២លានអឺរ៉ូ។

ក្រោមការសម្របសម្រួលរបស់ទីភ្នាក់ងារសហប្រតិបត្តិការអាល្លឺម៉ង់

(GIZ) និងទីភ្នាក់ងារសហប្រតិបត្តិការសម្រាប់ការអភិវឌ្ឍស្វីស (SDC) និងដោយមានគោលការណ៍អនុញ្ញាតដ៏ខ្ពង់ខ្ពស់របស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** គណៈប្រតិភូជាន់ខ្ពស់នៃព្រះរាជាណាចក្រកម្ពុជាដឹកនាំដោយ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ស សុខា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.អ.ប.** បានធ្វើដំណើរទស្សនកិច្ចសិក្សានៅសហព័ន្ធស្វីស និងសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ បានប្រព្រឹត្តទៅចាប់ពីថ្ងៃទី២១ ដល់ថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២៤ ដើម្បីសិក្សាស្វែងយល់អំពីការធ្វើកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនៅប្រទេសទាំងពីរ។

## ១. គោលបំណងនៃទស្សនកិច្ចសិក្សា

ទស្សនកិច្ចសិក្សានេះមានគោលបំណង ដើម្បី (១). ពង្រឹង និងពង្រីកទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសហព័ន្ធស្វីស និងសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ (២). សិក្សាស្វែងយល់ និងដកស្រង់មេរៀនបទពិសោធន៍ល្អៗអំពីប្រព័ន្ធរដ្ឋបាលមូលដ្ឋាន និងវិមជ្ឈការនៅប្រទេសទាំងពីរ ព្រមទាំងស្វែងយល់អំពីទិដ្ឋភាពសំខាន់ៗពាក់ព័ន្ធនឹងប្រព័ន្ធរដ្ឋបាលមូលដ្ឋានដ៏មានប្រសិទ្ធភាពក្នុងការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋដែលរួមមានដូចជា ការបែងចែកមុខងារ ការផ្តល់ស្វ័យភាព និងសិទ្ធិអំណាចក្នុងការធ្វើសេចក្តីសម្រេចចិត្តនៅថ្នាក់រដ្ឋបាលនីមួយៗ ការរៀបចំរដ្ឋបាលពហុកម្រិត ការចូលរួមរបស់ប្រជាពលរដ្ឋ និងកិច្ចការហិរញ្ញវត្ថុរដ្ឋបាលមូលដ្ឋាន ជាដើម។

## ២. សមាសភាពគណៈប្រតិភូ

គណៈប្រតិភូជាន់ខ្ពស់នៃព្រះរាជាណាចក្រកម្ពុជា ដឹកនាំដោយ

**ឯកឧត្តមអភិសន្តិបណ្ឌិត ស សុខា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប.)** និងមានការចូលរួមអមដំណើរដោយ **ឯកឧត្តម សក់ សេដ្ឋា ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស និងជាអនុប្រធានអចិន្ត្រៃយ៍នៃ គ.ជ.អ.ប. លោកជំទាវ កែ សួនសុភី ស សុខា ប្រធានកិត្តិយសក្រុមការងារយេនឌ័រ ក្រសួងមហាផ្ទៃ** ព្រមទាំងថ្នាក់ដឹកនាំ និងមន្ត្រីជាន់ខ្ពស់នៃក្រសួងមហាផ្ទៃ លេខាធិការដ្ឋាន គ.ជ.អ.ប. និងរដ្ឋបាលថ្នាក់ក្រោមជាតិដូចមានរាយនាមខាងក្រោម៖

| | |
|---|---|
| ១. **ឯកឧត្តមអភិសន្តិបណ្ឌិត ស សុខា** | ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.អ.ប. |
| ២. **ឯកឧត្តម សក់ សេដ្ឋា** | ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស និងជាអនុប្រធានអចិន្ត្រៃយ៍នៃ គ.ជ.អ.ប. |
| ៣. **លោកជំទាវ កែ សួនសុភី ស សុខា** | ប្រធានកិត្តិយសក្រុមការងារយេនឌ័រ ក្រសួងមហាផ្ទៃ |
| ៤. **ឯកឧត្តម ចាន់ សុធា** | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប. |
| ៥. **ឯកឧត្តមនាយឧត្តមសេនីយ៍ ស ថេត** | អគ្គស្នងការនគរបាលជាតិ ក្រសួងមហាផ្ទៃ |
| ៦. **ឯកឧត្តម សួស យ៉ារ៉ា** | អគ្គនាយករដ្ឋបាល ក្រសួងមហាផ្ទៃ |
| ៧. **លោកជំទាវ មិថុនា ភូថង** | អភិបាលខេត្តកោះកុង |

| | |
|---|---|
| ៨. **ឯកឧត្តម ជ័យ សម្បត្តិផល្លា** | ប្រធានអង្គភាពវិភាគ និងអភិវឌ្ឍន៍គោលនយោបាយ |
| ៩. **លោកឧត្តមសេនីយ៍ទោ ឌិត វិសិដ្ឋ** | ប្រធាននាយកដ្ឋានទំនាក់ទំនងអន្តរជាតិ ក្រសួងមហាផ្ទៃ |
| ១០.**លោកជំទាវឧត្តមសេនីយ៍ទោ ស ស៊ីណា** | អនុប្រធាននាយកដ្ឋានផែនការសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| ១១.**លោកស្រី ប៊ិន បូខ្មែរ** | អភិបាលស្រុករុក្ខគិរី ខេត្តបាត់ដំបង |
| ១២.**លោកស្រី គីម ញៀប** | អភិបាលខណ្ឌដង្កោ រាជធានីភ្នំពេញ |
| ១៣. **លោកឧត្តមសេនីយ៍ត្រី ខេង ប៉ូលីដា** | អនុប្រធាននាយកដ្ឋានទំនាក់ទំនងអន្តរជាតិ |
| ១៤. **លោកស្រី សំបូរ សម្ផស្ស** | ជំនួយការឯកឧត្តម អភិសន្តិបណ្ឌិត |
| ១៥. **លោកស្រី រិទ្ធ ម៉ានុត** | ជំនួយការឯកឧត្តម អភិសន្តិបណ្ឌិត |
| ១៦. **លោក សំអិត ថនវឌ្ឍនា** | មន្ត្រីព័ត៌មាន។ |

ក្រៅពីប្រតិភូជាន់ខ្ពស់នៃព្រះរាជាណាចក្រកម្ពុជា ក៏មានការចូលរួមពីមន្ត្រីនៃទីភ្នាក់ងារនៃកិច្ចសហប្រតិបត្តិការស្វីស ប្រចាំនៅកម្ពុជា (SDC) និងទីភ្នាក់ងារកិច្ចសហប្រតិបត្តិការអាល្លឺម៉ង់ ប្រចាំនៅកម្ពុជា (GIZ/ISD) ដើម្បីជួយសម្របសម្រួល និងគាំទ្រដល់ដំណើរការទស្សនកិច្ចនៅប្រទេសទាំងពីរខាងលើ ដូចមានរាយនាមខាងក្រោម៖

| | |
|---|---|
| ១. **លោក** Markus Bürli | នាយកប្រតិបត្តិទីភ្នាក់ងារស្វីសសម្រាប់កិច្ចសហប្រតិបត្តិការ និងការអភិវឌ្ឍប្រចាំកម្ពុជា |

២. លោកស្រី ទូន សាយរួយ — មន្ត្រីកម្មវិធីអភិបាលកិច្ច និងការចូលរួមរបស់ប្រជាពលរដ្ឋ

៣. លោកស្រី Friederike Burkert — ប្រធានគ្រប់គ្រងកម្មវិធី ISD/GIZ

៤. លោក ម៉ែន គុណរ័ត្ន — ប្រធានក្រុមការងារវិមជ្ឈការកម្មវិធី ISD/GIZ។



ដំណើរទស្សនកិច្ចសិក្សារបស់គណៈប្រតិភូជាន់ខ្ពស់នៃព្រះរាជាណាចក្រកម្ពុជា នៅសហព័ន្ធស្វីស និងសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់

## ៣. កម្មវិធីនៃទស្សនកិច្ចសិក្សា

ដំណើរទស្សនកិច្ចនេះបានប្រព្រឹត្តទៅតាមកម្មវិធីដូចខាងក្រោម៖

| កាលបរិច្ឆេទ | កម្មវិធី | អ្នកសម្របសម្រួល/ឧទ្ទេសនាម |
|---|---|---|
| **១. ទស្សនកិច្ចនៅប្រទេសស្វីស** | | |
| ២២ មេសា ២៤ | • កិច្ចស្វាគមន៍ដោយទីភ្នាក់ងារស្វីស (SDC)៖ ការណែនាំសមាសភាពគណៈប្រតិភូ | • ឯកឧត្តមអភិសន្តិបណ្ឌិត ស សុខា<br>• លោក Markus Bürli |

| | | |
|---|---|---|
| | និងកម្មវិធីទស្សនកិច្ចសិក្សា<br>• បទបង្ហាញ៖ លក្ខណៈពិសេសនៃប្រព័ន្ធនយោបាយប្រទេសស្វីស<br>• បទបង្ហាញ៖ តួនាទីរបស់រដ្ឋបាលឃុំ<br>• ការធ្វើទស្សនកិច្ចវិមានរដ្ឋសភា<br>• កិច្ចស្វាគមន៍ដោយលោកអភិបាលក្រុង Bern | • សាស្ត្រាចារ្យ Sean Müller សកលវិទ្យាល័យ Lausanne នៃទីក្រុង Bern<br>• បណ្ឌិត Jürg Wichtermann នាយកសមាគមឃុំទីក្រុង Bernese<br>• លោក Alecvon Graffenried អភិបាលក្រុង Bern |
| **២៣ មេសា ២៤** | • បទបង្ហាញអំពី៖<br>– ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈពហុកម្រិត<br>– ការចូលរួមរបស់ប្រជាពលរដ្ឋនៅប្រទេសស្វីស៖ ការអនុវត្តឧបករណ៍ប្រជាធិបតេយ្យ<br>– ការទទួលខុសត្រូវ និងកិច្ចសហប្រតិបត្តិការពហុកម្រិតក្នុងវិស័យសុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ<br>• ការជួបសម្តែងការគួរសមជាមួយរដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការបរទេស (ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ឯកឧត្តមទេសរដ្ឋមន្ត្រី និងមន្ត្រីជាន់ខ្ពស់រួមមាន៖ ឯកឧត្តម ចាន់ សុធា | • លោក **Peter Schwendener** អនុប្រធាននាយកដ្ឋានរដ្ឋបាលហិរញ្ញវត្ថុ<br>• លោកស្រី **Dr. Erika Schläppi,** Ximpulse; **Eva**<br>• លោក **Daniel Bohne** អគ្គលេខាធិការទីបញ្ជាការប៉ូលីសថ្នាក់ខេត្ត<br>• លោក Alexandre Fasel រដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការបរទេស |

| | | |
|---|---|---|
| | ឯកឧត្តម ស ចេត និងលោក ខេង ប៉ូលីដា) | |
| **២៤ មេសា ២៤** | • ទស្សនកិច្ចនៅឃុំ Zollikofen<br>• ការបូកសរុបលទ្ធផលទស្សនកិច្ច និងការពិសារអាហារថ្ងៃត្រង់ (បិទកម្មវិធីក្នុងប្រទេសស្វីស) | • **ឯកឧត្តមអភិសន្តិបណ្ឌិត ស សុខា**<br>• លោក Daniel Bichsel អភិបាលក្រុង<br>• លោក Markus Bürli |
| **២. ទស្សនកិច្ចនៅប្រទេសអាល្លឺម៉ង់** | | |
| **២៥ មេសា ២៤** | • ការស្វាគមន៍ និងណែនាំ<br>• បទបង្ហាញ និងពិភាក្សា៖ ប្រព័ន្ធរដ្ឋាភិបាលមូលដ្ឋាននៅប្រទេសអាល្លឺម៉ង់ (ឧ. ទីក្រុង Kempten)<br>• បទបង្ហាញ និងទស្សនកិច្ច៖ ការអនុវត្តយុទ្ធសាស្ត្រទីក្រុងវៃឆ្លាតនៅទីក្រុង Kempten<br>• បទបង្ហាញ និងពិភាក្សា៖ ការចូលរួមរបស់យុវជនក្នុងការងារនៅរដ្ឋាភិបាលមូលដ្ឋាន<br>• ទស្សនកិច្ច៖ ទីស្នាក់ការកិច្ចសហប្រតិបត្តិការអន្តរឃុំសម្រាប់ការពារស៊ីវិល និងការឆ្លើយតបបន្ទាន់។ | • លោក Thomas Kiechle អភិបាលក្រុង និងបណ្ឌិត Richard Schießl, និងប្រធាននាយកដ្ឋាន<br>• បណ្ឌិត Richard Schießl, និងបុគ្គលិក<br>• បណ្ឌិត Richard Schießl, និងបុគ្គលិក<br>• លោក Jugendhaus តំណាងយុវជន<br>• បណ្ឌិត Richard Schießl, និងបុគ្គលិក |
| **២៦ មេសា ២៤** | • ទស្សនកិច្ចក្រសួងមហាផ្ទៃ កីឡា និងសមាហរណកម្ម | • **ឯកឧត្តមអភិសន្តិបណ្ឌិត ស សុខា**<br>• ឯកឧត្តម សក់ សេដ្ឋា |

| | | |
|---|---|---|
| | នៅរដ្ឋ Bavaria, បទបង្ហាញ៖ ប្រព័ន្ធអភិបាលកិច្ចពហុកម្រិត<br>• ការជួបសម្តែងការគួរសមជាមួយលោក Eric Beißwenger រដ្ឋមន្ត្រីអធិការបតីរដ្ឋ Bavaria<br>• ទស្សកិច្ចទៅកាន់រដ្ឋបាលស្រុក the Bezirksregierung Oberbayern<br>✓ បទបង្ហាញ៖ កិច្ចការ និងមុខងាររបស់ Bezirksregierung ក្នុងនាមជាអាជ្ញាធរ រដ្ឋបាលជាន់ខ្ពស់<br>✓ ការត្រួតពិនិត្យរដ្ឋបាលមូលដ្ឋាន<br>✓ ការរៀបចំពហុកម្រិតសម្រាប់គ្រប់គ្រងគ្រោះមហន្តរាយ និងការពារស៊ីវិលនៅរដ្ឋ Bavaria | • ឯកឧត្តម ចាន់ សុធា<br>• ឯកឧត្តមនាយឧត្តមសេនីយ៍ ស ថេត<br>• លោកឧត្តមសេនីយ៍ត្រី ខេង ប៉ូលីដា<br>• Harald Welsch ប្រធានផ្នែក<br>• Sabine Kahle-Sander អនុប្រធានរដ្ឋបាល Bezirksregierung<br>• Stefanie Weber ប្រធាននាយកដ្ឋានសណ្តាប់ធ្នាប់សាធារណៈ កិច្ចការរដ្ឋបាលមូលដ្ឋាន និងសន្តិសុខសង្គម។ |
| **២៧ មេសា ២៤** | **ការធ្វើមាតុភូមនិវត្តន៍មកកាន់ប្រទេសកម្ពុជាវិញ** | |

## ខ. លទ្ធផលនៃទស្សនកិច្ចសិក្សា និងការសិក្សាស្រាវជ្រាវ

## ១. ប្រព័ន្ធអភិបាលកិច្ចនៅប្រទេសស្វីស

### ១.១. អំពីទិដ្ឋភាពទូទៅនៃប្រទេសស្វីស

ប្រទេសស្វីសជាប្រទេសមួយដែលស្ថិតនៅក្នុងទ្វីបអឺរ៉ុប (អឺរ៉ុបកណ្តាល) ដែលមានទេសភាពស្រស់ត្រកាល មានអាកាសធាតុចម្រុះ មានក្រឡាផ្ទៃសរុបប្រមាណ ៤១.២៨៥គីឡូម៉ែតការ៉េ និងមានប្រជាជនសរុបប្រមាណ ៨.៧ លាននាក់ ដែលមានដង់ស៊ីតេប្រជាជន ២០៨នាក់ ក្នុងមួយគីឡូម៉ែត្រការ៉េ។ ប្រទេសស្វីសត្រូវបានស្គាល់ថាជាប្រទេសដែលប្រើប្រាស់ភាសាចម្រុះចំនួនបួនគឺ៖ ភាសាអាល្លឺម៉ង់ (៦២%) ភាសាបារាំង(២៣%) ភាសាអ៊ីតាលី(៨%) និងភាសារ៉ូមានស៍(០,៥%)។ គិតត្រឹមឆ្នាំ២០២៣ ផលិតផលក្នុងស្រុកសរុបសម្រាប់ប្រជាជនមួយនាក់ (GDP Per Capita) នៅក្នុងប្រទេសស្វីសមានចំនួន ៨៥.១២១ដុល្លារអាមេរិកក្នុងមួយឆ្នាំ។ តួលេខនេះ បង្ហាញឱ្យឃើញថាប្រទេសស្វីសជាប្រទេសដែលមានសេដ្ឋកិច្ចរឹងមាំ ភាពចម្រុះនៃឧស្សាហកម្ម និងកម្រិតជីវភាពខ្ពស់។



រូបភាពទី១៖ ផែនទីសហព័ន្ធស្វីស



រូបភាពទី២៖ ផែនទីខេត្តទាំង២៦



រូបភាពទី៣៖ ផែនទីឃុំទាំង ២១៣១





រូបភាពទី៤៖ កម្រិតនៃរដ្ឋាភិបាលប្រទេសស្វីស

## ១.២. ការរៀបចំរដ្ឋាភិបាលពហុកម្រិតនៅប្រទេសស្វីស

ប្រទេសស្វីសត្រូវបានដំណើរការក្រោមប្រព័ន្ធនយោបាយដែលមានលក្ខណៈពិសេស ជារដ្ឋសហព័ន្ធប្រកបដោយប្រជាធិបតេយ្យ និងវិមជ្ឈការ។ ប្រព័ន្ធរដ្ឋាភិបាលប្រទេសនេះ ត្រូវបានចែកចេញជាបីកម្រិតផ្សេងៗគ្នា គឺ **រដ្ឋាភិបាលសហព័ន្ធ ចំនួន១ (Confederation Government) រដ្ឋាភិបាលខេត្ត ចំនួន២៦ (Cantons) និងរដ្ឋាភិបាលឃុំ ចំនួន២.១៣១ (Municipalities)**។ រដ្ឋាភិបាលខេត្ត និងរដ្ឋាភិបាលឃុំមានសិទ្ធិអំណាចជាច្រើន។ រដ្ឋាភិបាលខេត្តអាចធ្វើការសម្រេចចិត្តប្រកបដោយស្វ័យភាពលើការរៀបចំរចនាសម្ព័ន្ធ នីតិវិធីរដ្ឋបាល និងអនុវត្តកិច្ចការ ឬមុខងារជាច្រើនក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ព្រមទាំងអាចអនុម័ត និងដាក់ឱ្យអនុវត្តច្បាប់នានា និងមានចំណូលផ្ទាល់របស់ខ្លួនផងដែរ។

នៅថ្នាក់សហព័ន្ធ អំណាចត្រូវបានបែងចែក**ជា អំណាចនីតិប្បញ្ញត្តិ អំណាចនីតិប្រតិបត្តិ និងអំណាចតុលាការ**។

រដ្ឋសភាស្វីស (អំណាចនីតិប្បញ្ញត្តិ) មានតំណាងរាស្ត្រចំនួន **២៤៦នាក់** និងត្រូវបានចែកចេញជាសភាចំនួនពីរប្រភេទគឺ៖ (១). **ក្រុមប្រឹក្សាជាតិ** (ជាសភាធំដែលមានតំណាងរាស្ត្រចំនួន ២០០នាក់) តំណាងឱ្យប្រជាពលរដ្ឋស្វីសទាំងមូល និង(២). **ក្រុមប្រឹក្សារដ្ឋ** (ជាសភាតូច ដែលមានតំណាងរាស្ត្រចំនួន ៤៦នាក់) តំណាងឱ្យថ្នាក់ខេត្ត ដែលក្នុងនោះមានតំណាងចំនួន ០២រូប មកពីខេត្តនីមួយៗលើកលែងតែខេត្តតូចៗចំនួន០៦ ដែលមានតំណាងតែមួយរូប។ តំណាងរាស្ត្រទាំងអស់នេះត្រូវបានបោះឆ្នោតផ្ទាល់ដោយប្រជាជនស្វីសរៀងរាល់៤ឆ្នាំម្តង។ ប្រធានសភាប្រភេទនីមួយៗត្រូវបានបោះឆ្នោតជ្រើសរើសដោយសមាជិកសភារបស់ខ្លួនក្នុងអាណត្តិ០១ឆ្នាំ ហើយមិនអាច

ឈរឈ្មោះឡើងវិញបានឡើយ។ ការសម្រេចកិច្ចការធំៗនានានៅក្នុងសភា ចាំបាច់ត្រូវមានការឯកភាពដោយសភាទាំងពីរប្រភេទ (ក្រុមប្រឹក្សាជាតិ និង ក្រុមប្រឹក្សារដ្ឋ)។ ដោយសារប្រទេសស្វីសអនុវត្តលទ្ធិប្រជាធិបតេយ្យពាក់កណ្តាលផ្ទាល់ (Semi Direct Democracy) ដូចនេះ មានការលំបាកក្នុងកែប្រែច្បាប់ដែលបានសម្រេច រួចហើយដោយសភា និងរាល់ការធ្វើវិសោធនកម្មលើរដ្ឋធម្មនុញ្ញទាមទារឱ្យមានមតិភាគច្រើនទ្វេភាគី ពោលគឺ សំឡេងឆ្នោតភាគច្រើនរបស់ប្រជាពលរដ្ឋ និងសំឡេងគាំទ្រភាគច្រើននៃខេត្តទាំង២៦ ដែលជាហេតុធ្វើឱ្យខេត្តតូចៗ (ខេត្តជនបទ) ក៏មានសំឡេងស្មើនឹងខេត្តធំៗ (ទីក្រុង)ដែរ។

អំណាចប្រតិបត្តិត្រូវបានចែករំលែកនៅក្នុងចំណោមសមាជិកក្រុមប្រឹក្សាសហព័ន្ធចំនួន **០៧រូប** ដែលសមាជិកម្នាក់ៗត្រូវដឹកនាំ និងមើលការខុសត្រូវលើក្រសួងចំនួន០១។ សមាជិកក្រុមប្រឹក្សាសហព័ន្ធទាំង ០៧រូបនេះត្រូវបានបោះឆ្នោតដោយសភា (ក្រុមប្រឹក្សាជាតិ និងក្រុមប្រឹក្សារដ្ឋ) សម្រាប់អាណត្តិ០៤ឆ្នាំ និងតំណាងឱ្យគណបក្សនយោបាយធំៗទាំង៤នៅក្នុងប្រទេសស្វីស តំណាងឱ្យតំបន់និយាយភាសាទាំង៣នៃប្រទេសស្វីស និងតំណាងឱ្យយេនឌ័រទាំងពីរភេទ (បច្ចុប្បន្នមានសមាជិកក្រុមប្រឹក្សាជាស្ត្រីចំនួន ០៣រូប)។ យោងតាមរដ្ឋធម្មនុញ្ញសហព័ន្ធ ក្រុមប្រឹក្សាសហព័ន្ធត្រូវធ្វើការសម្រេចចិត្តក្នុងលក្ខណៈជាសមូហភាព ដោយក្រុមប្រឹក្សាសហព័ន្ធម្នាក់ៗមានសិទ្ធិស្មើៗគ្នា។ ប្រធានាធិបតីសហព័ន្ធស្វីសត្រូវបានបោះឆ្នោតរួមគ្នាដោយសភាទាំងពីរ ក្នុងនោះមានសភាក្រុមប្រឹក្សាជាតិចំនួន **២០០រូប** និងសភាក្រុមប្រឹក្សារដ្ឋចំនួន ៤៦រូប ដែលមានអាណត្តិ០១ឆ្នាំ និងអាចឈរឈ្មោះបានតែម្តងគត់។ ប្រធានាធិបតីធ្វើជាប្រធាននៃកិច្ចប្រជុំ និងជាតំណាងឱ្យរដ្ឋាភិបាលស្វីស។ ក្រោយពេលធ្វើការសម្រេចចិត្តណាមួយ សមាជិកក្រុមប្រឹក្សាសហព័ន្ធត្រូវរក្សាជំហរឯកភាពជាឯកច្ឆ័ន្ទក្នុងពេលបង្ហាញខ្លួនទៅសាធារណជន ទោះបីជា

ពួកគេមានភាពផ្ទុយគ្នាខ្លះលើទស្សនៈផ្ទាល់ខ្លួន ឬលើជំហររបស់គណបក្សខ្លួនក៏ដោយ។ ក្រុមប្រឹក្សាសហព័ន្ធ គឺជាអាជ្ញាធរប្រតិបត្តិកម្រិតខ្ពស់ជាងគេបំផុតនៅក្នុងប្រទេសស្វីស។

ដូចនៅថ្នាក់សហព័ន្ធដែរ អំណាចនៅថ្នាក់ខេត្តត្រូវបានបែងចែកជា៖ អំណាចនីតិប្បញ្ញត្តិ អំណាចនីតិប្រតិបត្តិ និងអំណាចតុលាការ។ ខេត្តភាគច្រើនមានសភា (នីតិប្បញ្ញត្តិ) ដោយមានចំនួនតំណាងរាស្ត្រខុសៗគ្នា។ រដ្ឋាភិបាលខេត្ត (នីតិប្រតិបត្តិ) ជាធម្មតាមានសមាជិកចំនួនចាប់ពី **៥ទៅ ៧រូប**។ ទាំងសភា និងរដ្ឋាភិបាលខេត្តត្រូវបានបោះឆ្នោតដោយប្រជាពលរដ្ឋរៀងរាល់ ៤ឆ្នាំម្តង។ សភាខេត្តជាអ្នកបង្កើតច្បាប់ និងគោលនយោបាយនានា ព្រមទាំងចូលរួមធ្វើការសម្រេចចិត្តលើបញ្ហារដ្ឋបាលសំខាន់ៗ ក៏ដូចជាបញ្ហាពាក់ព័ន្ធទៅនឹងចំណូល និងចំណាយផ្សេងៗ។ រដ្ឋាភិបាលខេត្តជាអ្នកអនុវត្តច្បាប់ និងគោលនយោបាយ រួមទាំងការគ្រប់គ្រងកិច្ចការប្រចាំថ្ងៃ ធនធាន និងធានាឱ្យមានការផ្តល់សេវាសាធារណៈប្រកបដោយប្រសិទ្ធភាពនៅក្នុងខេត្ត។

ដូចថ្នាក់សហព័ន្ធ និងថ្នាក់ខេត្តដែរ ឃុំនីមួយៗមានអង្គនីតិប្បញ្ញត្តិរបស់ខ្លួន។ នៅឃុំធំៗមានសភារបស់ខ្លួន ប៉ុន្តែឃុំតូចៗមួយចំនួនប្រជាជនរួមផ្តុំគ្នាដើម្បីបំពេញតួនាទីនេះ (ប្រជាធិបតេយ្យផ្ទាល់)។ នៅឃុំធំៗជាច្រើនទោះបីជាមានសភាឃុំក៏ដោយ នៅទីបញ្ចប់សន្លឹកឆ្នោតរបស់ប្រជាពលរដ្ឋជាអ្នកកំណត់នូវអ្វីៗទាំងអស់ ដោយហេតុថាប្រជាពលរដ្ឋត្រូវបោះឆ្នោតលើច្បាប់ផែនការនានា និងលើបញ្ហាហិរញ្ញវត្ថុសំខាន់ៗ តាមរយៈការធ្វើប្រជាមតិ។ សមាជិកនីតិប្រតិបត្តិរបស់ឃុំ (ភាគច្រើនហៅថាក្រុមប្រឹក្សាឃុំ) ត្រូវបានបោះឆ្នោតដោយប្រជាពលរដ្ឋផ្ទាល់នៅក្នុងឃុំនីមួយៗ។ រដ្ឋបាលឃុំមានសមាជិកមួយចំនួនប្រែប្រួលទៅតាមទំហំ និងប្រជាសាស្ត្រ (ឧទាហរណ៍ ករណីឃុំមួយនៃទីក្រុង Bern មានសមាជិកគណៈអភិបាល៥រូប និងក្រុមប្រឹក្សា៨០រូប)

ដោយរួមមានមេឃុំ/ចៅហ្វាយក្រុង និងក្រុមប្រឹក្សាផ្សេងទៀត។ មេឃុំ/ចៅហ្វាយក្រុង គឺជាប្រធានរដ្ឋបាលឃុំ និងតំណាងឱ្យឃុំ។

### ១.៧. មុខងារ ភារកិច្ច ទំនាក់ទំនងការងារ និងកិច្ចសហប្រតិបត្តិការអន្តររដ្ឋាភិបាល

រដ្ឋាភិបាលសហព័ន្ធមានការទទួលខុសត្រូវលើវិស័យមួយចំនួនដែលរដ្ឋធម្មនុញ្ញផ្តល់សិទ្ធិអំណាចឱ្យដូចជា៖ ការរៀបចំអាជ្ញាធរនានានៅថ្នាក់សហព័ន្ធ កិច្ចការបរទេស កិច្ចការកងទ័ពនិងការការពារប្រជាពលរដ្ឋ ការការពារបរិស្ថាន (ទទួលខុសត្រូវរួម) ការកំណត់តំបន់ប្រើប្រាស់ដីធ្លី (ទទួលខុសត្រូវរួម) គោលនយោបាយថាមពល (ទទួលខុសត្រូវរួម) គោលនយោបាយនុយក្លេអ៊ែរ សេវាប្រៃសណីយ៍និងទូរគមនាគមន៍ គោលនយោបាយរូបិយប័ណ្ណ របបសន្តិសុខសង្គម (ការចូលនិវត្តន៍) ច្បាប់រដ្ឋប្បវេណី ច្បាប់ព្រហ្មទណ្ឌ នីតិវិធីឧក្រិដ្ឋកម្មនិងស៊ីវិល កិច្ចការគយ និងការប្រមូលពន្ធសហព័ន្ធ និងកិច្ចការពាក់ព័ន្ធទៅនឹងសញ្ជាតិ (ទទួលខុសត្រូវរួម)។ កិច្ចការទាំងឡាយណាដែលមិនមានចែងនៅថ្នាក់សហព័ន្ធ គឺជាកិច្ចការរបស់ថ្នាក់ខេត្ត និងឃុំ។ ទោះបីយ៉ាងណាក៏ដោយ ដោយសារកិច្ចការមួយចំនួននៅថ្នាក់ខេត្តកាន់តែមានភាពស្មុគស្មាញ និងតម្រូវឱ្យមានការផ្សារភ្ជាប់គ្នារវាងរដ្ឋបាលខេត្ត និងរដ្ឋបាលសហព័ន្ធ ដូចនេះ សិទ្ធិអំណាចកាន់តែច្រើនឡើងៗគឺត្រូវបានចែករំលែករួមគ្នាក្នុងចំណោមរដ្ឋាភិបាលសហព័ន្ធ និងរដ្ឋាភិបាលខេត្ត។ តាមគោលការណ៍នៃរដ្ឋធម្មនុញ្ញ រដ្ឋាភិបាលសហព័ន្ធអាចអនុវត្តបានតែកិច្ចការណាដែលខេត្តមិនអាចអនុវត្តបានប៉ុណ្ណោះ ឬកិច្ចការដែលតម្រូវឱ្យមានបទប្បញ្ញត្តិរួមគ្នា។

រដ្ឋធម្មនុញ្ញសហព័ន្ធស្វិសបានធានានូវស្វ័យភាពរបស់ឃុំ។ តាមរយៈរដ្ឋធម្មនុញ្ញនេះ ច្បាប់របស់ខេត្តបានតម្រូវឱ្យរដ្ឋាភិបាលខេត្តនីមួយៗទទួល

ខុសត្រូវក្នុងការកំណត់អំពីក្របខណ្ឌនៃសិទ្ធិអំណាច និងតួនាទីរបស់ឃុំនីមួយៗ។ ក្នុងន័យនេះ រដ្ឋាភិបាលខេត្តនីមួយៗត្រូវកំណត់អំពីចំនួនឃុំ និងសិទ្ធិអំណាចរបស់ឃុំនីមួយៗដោយគោរពតាមគោលការណ៍ Subsidiarity ដែលកំណត់ដោយរដ្ឋធម្មនុញ្ញ។ បើទោះបីជា ឃុំត្រូវអនុវត្តទៅតាមក្របខណ្ឌច្បាប់សហព័ន្ធ និងច្បាប់ខេត្ត និងមានទម្រង់ផ្សេងៗគ្នាទៅតាមខេត្តនីមួយៗក៏ឃុំទាំងនោះមានលក្ខណៈទូទៅមួយចំនួនដូចគ្នាផងដែរ។ ជាទូទៅ ឃុំមានសិទ្ធិអំណាច និងមុខងារមួយចំនួនដែលត្រូវអនុវត្តស្របទៅតាមក្របខណ្ឌច្បាប់សហព័ន្ធ និងច្បាប់ខេត្ត រួមមានដូចជា ការរៀបចំរចនាសម្ព័ន្ធឃុំ ការគ្រប់គ្រងមត្តេយ្យ និងបឋមសិក្សា ការគ្រប់គ្រងសំរាមនិងទឹក ការកសាងផ្លូវថ្នល់ក្នុងឃុំ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋាន កិច្ចការប៉ូលីសមូលដ្ឋាន ការកំណត់តំបន់ប្រើប្រាស់ដីធ្លី ការប្រមូលពន្ធថ្នាក់ឃុំ និងកិច្ចការពាក់ព័ន្ធទៅនឹងសញ្ជាតិ។

នៅក្នុងការអនុវត្តជាក់ស្តែង លើវិស័យជាច្រើនក្នុងកិច្ចការសាធារណៈមិនអាចចែកដាច់ពីគ្នាបានឡើយ ហើយតែងតែមានភាពពាក់ព័ន្ធគ្នា ឬអនុវត្តត្រួតគ្នា។ ទំនាក់ទំនង និងកិច្ចសហការអន្តររដ្ឋាភិបាលមានសារៈសំខាន់ណាស់នៅក្នុងការគ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារជាក់ស្តែងដែលត្រូវធ្វើឡើងដោយមានការផ្សារភ្ជាប់គ្នារវាងសមត្ថកិច្ចនៃថ្នាក់រដ្ឋបាលកម្រិតផ្សេងៗគ្នា។ បើទោះបីជា កិច្ចសហប្រតិបត្តិការរួមគ្នានេះត្រូវការចំណាយទៅលើធនធានហិរញ្ញវត្ថុ ធនធានមនុស្ស និងពេលវេលាក៏ដោយ ក៏កិច្ចសហប្រតិបត្តិការនេះត្រូវបានចាត់ទុកថាជាកត្តាជោគជ័យនៃប្រព័ន្ធគ្រប់គ្រងរបស់ប្រទេសស្វីស ដែលឈរលើមូលដ្ឋាននៃការស្រុះស្រួលផ្ទៃកនយោបាយ។ ទោះបីជាយ៉ាងណាភាពស្មុគស្មាញនាពេលបច្ចុប្បន្នពាក់ព័ន្ធនឹងការបែងចែកភារកិច្ច និងការទទួលខុសត្រូវអាចមានផលប៉ះពាល់ទៅលើកត្តាតម្លាភាព និងខ្សែគណនេយ្យភាព

នៅគ្រប់កម្រិតទាំងអស់នៅក្នុងប្រព័ន្ធនយោបាយស្វីស។ យន្តការ និងស្ថាប័នអន្តររដ្ឋាភិបាលជាច្រើនត្រូវបានរៀបចំ ដើម្បីសម្របសម្រួលកិច្ចសហប្រតិបត្តិការនៅគ្រប់កម្រិតរដ្ឋបាលនៃប្រទេសស្វីស។

### ១.៣.១. កិច្ចសហប្រតិបត្តិការតាមខ្សែបណ្តោយ

- **កិច្ចសហប្រតិបត្តិការរវាងសហព័ន្ធ និងខេត្ត៖** ប្រព័ន្ធរដ្ឋាភិបាលស្វីសមានការរីកលូតលាស់ដោយសារកិច្ចសហប្រតិបត្តិការជិតស្និតរវាងរដ្ឋាភិបាលសហព័ន្ធ និងរដ្ឋាភិបាលខេត្ត ដែលធ្វើឱ្យទំនាក់ទំនងអន្តររដ្ឋាភិបាលនេះ គឺជាចំណុចមួយដ៏មានសារៈសំខាន់។ រដ្ឋាភិបាលខេត្តត្រូវបានពិគ្រោះយោបល់លើគ្រប់បញ្ហាទាំងអស់របស់សហព័ន្ធពាក់ព័ន្ធនឹងខេត្ត ពិសេសតាមរយៈវេទិការដ្ឋាភិបាលខេត្ត និងវេទិការបស់រដ្ឋមន្ត្រីនៅថ្នាក់ខេត្ត។ ចំពោះមុខងារដែលត្រូវទទួលខុសត្រូវរួមគ្នា និងមុខងារដែលខេត្តត្រូវអនុវត្តតាមសេចក្តីសម្រេចចិត្ត និងកិច្ចការនានារបស់សហព័ន្ធបន្ទុកនេះត្រូវធ្វើឡើងតាមរយៈការផ្តល់ហិរញ្ញវត្ថុរួមគ្នា។ ចំពោះការចំណាយសម្រាប់អនុវត្តមុខងារផ្ទាល់របស់ខ្លួន រដ្ឋាភិបាលខេត្តត្រូវរ៉ាប់រងដោយប្រើប្រាស់ចំណូលផ្ទាល់របស់ខ្លួន យោងតាមគោលការណ៍រដ្ឋធម្មនុញ្ញ ស្តីពីសមភាពហិរញ្ញវត្ថុ។ បន្ថែមលើនេះ យន្តការសមភាពហិរញ្ញវត្ថុ (ការចូលរួមគ្នាលើបន្ទុកចំណាយ និងហិរញ្ញវត្ថុ) បានលើកកម្ពស់ដល់សាមគ្គីភាពរវាងរដ្ឋាភិបាលសហព័ន្ធ និងរដ្ឋាភិបាលខេត្ត ក៏ដូចជារវាងរដ្ឋាភិបាលខេត្ត និងរដ្ឋាភិបាលខេត្តផងដែរ។
- **កិច្ចសហប្រតិបត្តិការរវាងខេត្ត និងឃុំ៖** ដោយសាររដ្ឋាភិបាល

ខេត្តជាអ្នកកំណត់សិទ្ធិអំណាច សម្រាប់ឃុំ ដូចនេះ ទំនាក់ទំនងរវាងរដ្ឋាភិបាលខេត្ត និងរដ្ឋាភិបាលឃុំមានភាពខុសគ្នាពីខេត្តមួយទៅខេត្តមួយ។ ស្ថាប័ន និងយន្តការជាច្រើនត្រូវបានបង្កើត និងដាក់ឱ្យអនុវត្ត។ ក្នុងពេលរដ្ឋាភិបាលខេត្តផ្ទេរប្រតិភូកម្មកិច្ចការរបស់ខ្លួនទៅឱ្យរដ្ឋាភិបាលឃុំ រដ្ឋាភិបាលខេត្ត ត្រូវត្រួតពិនិត្យលើសកម្មភាពដែលអនុវត្តដោយរដ្ឋាភិបាលឃុំ។ ក្នុងពេលដែលរដ្ឋាភិបាលឃុំអនុវត្តសកម្មភាពក្នុងក្របខណ្ឌស្វ័យភាពរបស់ខ្លួន រដ្ឋាភិបាលខេត្តត្រូវពិនិត្យមើលថាតើរដ្ឋាភិបាលឃុំបានគោរពទៅតាមច្បាប់ និងមិនអនុវត្តសិទ្ធិអំណាចហួសពីច្បាប់អនុញ្ញាត។ តាមច្បាប់ខេត្តត្រូវពិគ្រោះយោបល់ជាមួយឃុំលើកិច្ចការដែលពាក់ព័ន្ធទៅនឹងដំណើរការរៀបចំ និងដាក់ចេញច្បាប់ និងគោលនយោបាយ។ នៅក្នុងខេត្តជាច្រើន ឃុំបានរួមគ្នាតាមការស្ម័គ្រចិត្តក្នុងការលើកឡើងនូវសំឡេងរបស់ខ្លួនមករដ្ឋាភិបាលខេត្ត និងរដ្ឋាភិបាលសហព័ន្ធ។ នៅខេត្ត Bern សមាគមឃុំ Bernese បានប្រមូលផ្តុំគ្នាស្ទើរគ្រប់ឃុំ ក្នុងគោលបំណងរួមកម្លាំងការពារផលប្រយោជន៍រួម និងគាំទ្រដល់ឃុំ។ សមាគមនេះ បានដើរតួនាទីយ៉ាងសំខាន់នៅក្នុងដំណើរការនយោបាយដែលពាក់ព័ន្ធទៅនឹងគ្រប់វិស័យ/កិច្ចការទាំងអស់របស់ឃុំ។

- **កិច្ចសហប្រតិបត្តិការរវាងឃុំ និងរដ្ឋាភិបាលសហព័ន្ធ៖** ទំនាក់ទំនងដោយផ្ទាល់រវាងថ្នាក់ឃុំ និងថ្នាក់សហព័ន្ធមានកម្រិតតិចតួច ដោយសារខេត្ត គឺជាអ្នកកំណត់កិច្ចការដល់ឃុំនៅក្នុងខេត្តរបស់ខ្លួន។ ទោះបីជាយ៉ាងនេះក៏ដោយ ឃុំក៏បានបង្កើតឡើងនូវសមាគមនានានៅថ្នាក់ជាតិ (សមាគមឃុំស្វីស និងសមាគមទីក្រុងស្វីស

ដែលតំណាងឱ្យផលប្រយោជន៍ទីក្រុងធំៗ)។ សមាគមទាំងពីរមានសារៈសំខាន់សម្រាប់ជាវេទិកាក្នុងការរៀបចំបណ្ដាញ និងផ្លាស់ប្ដូរយោបល់រវាងឃុំនិងឃុំ និងរវាងទីក្រុងនិងទីក្រុង ក្នុងគោលដៅតស៊ូមតិជាមួយរដ្ឋាភិបាលសហព័ន្ធ ដើម្បីការពារផលប្រយោជន៍របស់ឃុំ និងទីក្រុង។ សមាគមទាំងនោះសម្ដែងនូវមតិយោបល់ទៅលើសំណើច្បាប់នានា និងតំណាងឱ្យសំឡេងរបស់ឃុំ ក្នុងការជជែកដេញដោលជាសាធារណៈតាមប្រព័ន្ធផ្សព្វផ្សាយនានា។

### ១.៣.២. កិច្ចសហប្រតិបត្តិការតាមខ្សែទទឹង

- កិច្ចព្រមព្រៀងអន្តរខេត្តចំនួន ៧៦០ ត្រូវបានរៀបចំឡើង ដែលកិច្ចព្រមព្រៀងទាំងនេះបង្កើតស្តង់ដាររួមតែមួយ និងបានលើកកម្ពស់ដល់កិច្ចសហប្រតិបត្តិការរវាងខេត្ត និងខេត្តលើបញ្ហាជាច្រើនពាក់ព័ន្ធនឹងសមត្ថកិច្ចរបស់ខេត្ត។ កិច្ចព្រមព្រៀងទាំងនេះអាចប្រកាសជាទូទៅថាមានលក្ខណៈគតិយុត្តដោយរដ្ឋាភិបាលសហព័ន្ធ។ លើសពីនេះទៅទៀត ស្ថាប័នអន្តរខេត្តមួយចំនួនត្រូវបានបង្កើតឡើង ដើម្បីជួយសម្របសម្រួលលើគោលនយោបាយរវាងខេត្ត និងខេត្ត។ ឧទាហរណ៍ វេទិកាចំនួន១៦ សម្រាប់ប្រធាននាយកដ្ឋាននៅថ្នាក់ខេត្ត (ត្រូវបានស្គាល់ថាជារដ្ឋមន្ត្រីថ្នាក់ខេត្ត) និងវេទិកានៃរដ្ឋាភិបាលថ្នាក់ខេត្ត (ដូចជាវេទិកាសម្រាប់ប្រធាននាយកដ្ឋានហិរញ្ញវត្ថុថ្នាក់ខេត្ត) ត្រូវបានបង្កើតឡើង។ កិច្ចសហប្រតិបត្តិការសម្រាប់កងកម្លាំងប៉ូលីសថ្នាក់ខេត្ត និងថ្នាក់ឃុំក៏ត្រូវបានពិភាក្សាយ៉ាងលំអិតផងដែរ។

- ដូចនៅថ្នាក់ខេត្តដែរ កិច្ចសហប្រតិបត្តិការអន្តរឃុំបានដើរតួនាទីយ៉ាងសំខាន់ក្នុងការធានាដល់ការផ្តល់សេវាប្រកបដោយប្រសិទ្ធភាព និងការដោះស្រាយបាននូវបញ្ហានានាដែលប្រឈមដោយឃុំ។ នៅក្នុងវិធីសាស្ត្រនៃកិច្ចសហប្រតិបត្តិការនេះ ឃុំបានអនុវត្តតាមទម្រង់នានាដូចជា ការផ្តល់សេវារួមគ្នា ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធរួមគ្នា ការផ្តល់មូលនិធិរួមគ្នា និងការរៀបចំផែនការរួមគ្នា ជាដើម។ ជាទូទៅ កិច្ចប្រឹងប្រែងរួមគ្នាទាំងនោះ រួមមាន៖ ការអនុវត្តគម្រោង និងការផ្តល់សេវាពាក់ព័ន្ធនឹងសាលារៀន ទឹកប្រព័ន្ធលូទឹកស្អុយ សេវាសង្គម ការងារសំណង់ វិទ្យាសាស្ត្រកំព្យូទ័រ ។ល។ ឧទាហរណ៍ នៅឃុំ Zollikofen បានបង្ហាញអំពីការប្រើប្រាស់ជាទូទៅនូវកិច្ចសហប្រតិបត្តិការតាមខ្សែទទឹងរវាងឃុំ និងឃុំក្នុងការគ្រប់គ្រងការងារឆ្លើយតបបន្ទាន់ ដូចជាការពន្លត់អគ្គីភ័យជាដើម។ នៅក្នុងខេត្តមួយចំនួន សមាគមឃុំបានដើរតួនាទីយ៉ាងសំខាន់ក្នុងការផ្តល់ការគាំទ្រតាមខ្សែទទឹងទៅដល់សមាជិករបស់ខ្លួន។ ឧទាហរណ៍ កិច្ចប្រឹងប្រែងរួមគ្នាលើការអភិវឌ្ឍសមត្ថភាព ការសម្របសម្រួល ការផ្លាស់ប្តូរមេរៀនបទពិសោធន៍ និងការចងជាបណ្តាញ ជាដើម។

### ១.៣.៣. រដ្ឋបាលមូលដ្ឋាន៖ ស្វ័យតាព និងសិទ្ធិក្នុងការធ្វើសេចក្តីសម្រេចចិត្ត កិច្ចការ និងមុខងាររបស់រដ្ឋាភិបាលមូលដ្ឋាន

ខេត្ត និងឃុំមានកម្រិតស្វ័យភាពខុសៗគ្នា ហើយស្វ័យភាពដ៏មានសារៈសំខាន់ទាំងនេះបានអនុញ្ញាតឱ្យខេត្ត និងឃុំអាចគ្រប់គ្រងកិច្ចការរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព។ ខេត្តមានអធិបតេយ្យលើកិច្ចការនានា លើកលែង

តែអធិបតេយ្យទាំងនោះកម្រិតដោយរដ្ឋធម្មនុញ្ញសហព័ន្ធ។ នេះមានន័យថា ខេត្តនីមួយៗអាចមានរដ្ឋធម្មនុញ្ញ មានរដ្ឋាភិបាល និងមានសិទ្ធិអំណាចលើការធ្វើសេចក្តីសម្រេចចិត្តនានា រួមទាំងអាចអនុវត្តសិទ្ធិអំណាចនានា ដែលមិនមានចែងថាជាសិទ្ធិអំណាចរបស់រដ្ឋសហព័ន្ធផងដែរ។

អនុវត្តតាមគោលការណ៍នៃការបែងចែងអំណាច (Subsidiarity) កិច្ចការជាច្រើនត្រូវអនុវត្តដោយថ្នាក់រដ្ឋាភិបាលទាបជាងគេបំផុត។ នៅកម្រិតទាបបំផុត ជាទូទៅឃុំមានកម្រិតស្វ័យភាពខ្ពស់ (ទាំងស្វ័យភាពលើការរៀបចំរដ្ឋបាល ស្វ័យភាពលើការអនុវត្តកិច្ចការ និងស្វ័យភាពលើបញ្ហាហិរញ្ញវត្ថុ) ដែលស្វ័យភាពទាំងនោះមានចែងនៅក្នុងច្បាប់របស់ខេត្ត។ ជាធម្មតា ឃុំត្រូវបានផ្តល់អំណាចក្នុងការអនុវត្តកិច្ចការ ព្រមទាំងការទទួលខុសត្រូវនានា និងអាចផ្តល់សេវាជូនដល់ប្រជាពលរដ្ឋតាមទំហំ និងកម្រិតដែលឃុំអាចផ្តល់បាន និងតាមសមត្ថភាពហិរញ្ញវត្ថុរបស់ឃុំនីមួយៗ។ ទោះបីជាយ៉ាងនេះក៏ដោយ តាមរយៈការកើនឡើងនូវវិស័យត្រូវទទួលខុសត្រូវរួមគ្នា កិច្ចការ និងសេវាជាក់លាក់ជាច្រើនត្រូវបានឧបត្ថម្ភធនដោយរដ្ឋាភិបាលថ្នាក់ខេត្ត និងសហព័ន្ធ។

- **ស្វ័យភាពក្នុងការរៀបចំរដ្ឋបាល៖** ខេត្តមានសេរីភាពក្នុងការកំណត់ក្របខណ្ឌរដ្ឋធម្មនុញ្ញ និងស្ថាប័ននយោបាយរបស់ខ្លួន។ នៅក្នុងក្របខណ្ឌច្បាប់សហព័ន្ធ អាជ្ញាធរខេត្តអាចបង្កើតស្ថាប័ន និងដំណើរការនយោបាយរបស់ខ្លួន អាចជួលបុគ្គលិក អាចកំណត់អត្រាពន្ធ និងអាចធ្វើការសម្រេចចិត្តលើចំណាយនានា។ ជាមួយគ្នានេះផងដែរ ឃុំមានសេរីភាពក្នុងការបង្កើតប្រព័ន្ធរដ្ឋបាលរបស់ខ្លួន ប៉ុន្តែត្រូវអនុលោមតាមស្តង់ដាដែលកំណត់ដោយថ្នាក់ខេត្ត។ ជាធម្មតា ឃុំអាចធ្វើការសម្រេចចិត្តអំពីរចនាសម្ព័ន្ធ និងចំនួនបុគ្គលិកទៅតាមតម្រូវការ និងកិច្ចការជាក់លាក់ ក៏ដូចជាអាច

បង្កើតនូវនីតិវិធី និងដំណើរការការងារ ដូចជា ការរៀបចំផែនការ ការរៀបចំថវិកា ការចំណាយ និងការអនុវត្តការងារជាដើម។ ឧទាហរណ៍៖ ការរៀបចំកិច្ចការប៉ូលីសនៅថ្នាក់ខេត្តបង្ហាញអំពីមធ្យោបាយនានា ដែលខេត្តអាចរៀបចំកម្លាំងប៉ូលីសបាន។

- **ស្វ័យភាពនៃការកំណត់កិច្ចការ៖** ខេត្តមានសេរីភាពក្នុងការកំណត់ ការរៀបចំ និងការអនុវត្តកិច្ចការ និងការទទួលខុសត្រូវនានា (ឬផ្ទេរកិច្ចការទាំងនោះទៅឱ្យឃុំ)។ ជាទូទៅ ខេត្តមានសិទ្ធិអំណាចជាចម្បងៗក្នុងវិស័យមួយចំនួនដូចជា វិស័យអប់រំ វប្បធម៌ ប៉ូលីស ទំនាក់ទំនងរវាងតំបន់និងរដ្ឋ វិស័យសុខភាពសាធារណៈ ព្រៃឈើ ទឹក ពន្ធដារថ្នាក់ខេត្ត និងកិច្ចការពាក់ព័ន្ធទៅនឹងសញ្ជាតិ (កិច្ចការទទួលខុសត្រូវរួមគ្នា)។ នៅថ្នាក់ឃុំ អាស្រ័យលើការកំណត់របស់ខេត្តនីមួយៗ ឃុំមានអំណាចលើវិស័យមួយចំនួនដូចជា វិស័យអប់រំ (មត្តេយ្យសិក្សា និងបឋមសិក្សា) ការគ្រប់គ្រងសំរាម និងទឹក ការការពារបរិស្ថាន និងការអភិរក្សធនធានធម្មជាតិ ហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋាន (ការសាងសង់ផ្លូវថ្នល់ និងសំណង់សាធារណៈនានា) កិច្ចការប៉ូលីសមូលដ្ឋាន ការពន្លត់អគ្គីភ័យ ការប្រមូលពន្ធនៅថ្នាក់ឃុំ ការកំណត់តំបន់ប្រើប្រាស់ដីធ្លី និងកិច្ចការពាក់ព័ន្ធទៅនឹងសញ្ជាតិជាដើម (កិច្ចការទទួលខុសត្រូវរួមគ្នា)។ ឧទាហរណ៍ ខេត្ត Bern បង្ហាញអំពីការអនុវត្តគោលការណ៍នៃការចែករំលែកការទទួលខុសត្រូវរួមគ្នា។ ក្នុងវិស័យសុខាភិបាល កាលពីមុនមន្ទីរពេទ្យមូលដ្ឋានមានអ្នកជំងឺតិចតួច ដូចនេះកិច្ចការនេះទទួលខុសត្រូវដោយឃុំ។ សព្វថ្ងៃនេះ ដោយសារសេវាសុខាភិបាលកាន់តែមានភាពស្មុគស្មាញ មានតម្លៃថ្លៃ មានតម្រូវការខ្ពស់ និង

មានអ្នកជំងឺច្រើន ដូចនេះកិច្ចការនេះទទួលខុសត្រូវដោយថ្នាក់ខេត្តវិញ។ នៅក្នុងវិស័យអប់រំ ខេត្ត Bern បានបង្ហាញឧទាហរណ៍ដ៏ល្អលើការចែករំលែកការទទួលខុសត្រូវរវាងថ្នាក់រដ្ឋបាលនីមួយៗ។ ក្នុងពេលដែលថ្នាក់ឃុំទទួលខុសត្រូវលើកម្រិតមត្តេយ្យ និងបឋមសិក្សា ថ្នាក់ខេត្តបានផ្តោតការយកចិត្តទុកដាក់លើសាលារៀនកម្រិតខ្ពស់ៗ និងមហាវិទ្យាល័យ។ ជាមួយគ្នានេះផងដែរ ឃុំទទួលខុសត្រូវលើហេដ្ឋារចនាសម្ព័ន្ធសាលារៀន និងការជួលគ្រូបង្រៀន រីឯខេត្តទទួលខុសត្រូវលើការរៀបចំកម្មវិធីសិក្សាគ្រប់កម្រិត ការត្រួតពិនិត្យគុណភាពនៃការបង្រៀន និងការបណ្តុះបណ្តាលគ្រូ។ នៅខេត្ត Bern ឃុំអាចអនុវត្តកិច្ចការសំខាន់នានាឱ្យតែពួកគេអាចធ្វើបាន (មិនមានបញ្ជីកិច្ចការជាក់លាក់សម្រាប់ឃុំឡើយ) ហើយឃុំទាំងនោះក៏អាចស្ម័គ្រចិត្តអនុវត្តកិច្ចការមួយចំនួនទៀតបានផងដែរ (ឧ.កិច្ចការវប្បធម៌ ចរាចរណ៍ កីឡា...) បើសិនជាឃុំទាំងនោះអាចធ្វើបាន។

- **ស្វ័យភាពហិរញ្ញវត្ថុ៖** កិច្ចការនេះបានជួយដល់រដ្ឋាភិបាលកម្រិតនីមួយៗ ទទួលខុសត្រូវក្នុងការគ្រប់គ្រងធនធានរបស់ខ្លួនសម្រាប់គាំទ្រដល់ការផ្តល់សេវាសាធារណៈ។ នៅក្នុងប្រទេសស្វីស ខេត្ត និងឃុំមានស្វ័យភាពក្នុងការកំណត់ និងប្រមូលចំណូល (ទាំងចំណូលពន្ធ និងចំណូលមិនមែនពន្ធ) ប្រសិនបើការទទួលខុសត្រូវនេះមិនបានប្រគល់ទៅរដ្ឋាភិបាលសហព័ន្ធទេ។ ចំណូលពីការយកពន្ធផ្ទាល់បានដើរតួនាទីយ៉ាងសំខាន់ក្នុងការបង្កើតចំណូលសម្រាប់ឃុំ (**៦០%នៃចំណូលសរុបរបស់ឃុំ**) សម្រាប់ខេត្ត (**៥០%**) និងសម្រាប់រដ្ឋាភិបាលសហព័ន្ធ (**៤០%**)។ ទោះបីជា

យ៉ាងនេះក៏ដោយ ពន្ធលើការប្រើប្រាស់ (VAT) ទាំងស្រុងបានក្លាយជាប្រភពចំណូលសម្រាប់រដ្ឋាភិបាលសហព័ន្ធ។ បន្ថែមពីការប្រមូលពន្ធ ឃុំ និងខេត្តក៏ទទួលបានផលប្រយោជន៍ពីប្រភពនានាផងដែរ ដូចជា ថ្លៃសេវាពីអ្នកប្រើប្រាស់ **(ប្រហែល១០% សម្រាប់ខេត្ត និង២០%សម្រាប់ឃុំ)** ការផ្ទេរពីរដ្ឋាភិបាលសហព័ន្ធ **(ប្រហែល៣០%សម្រាប់ខេត្ត និងជាង១០%សម្រាប់ឃុំ)** និងប្រភពចំណូលផ្សេងៗទៀត **(ប្រហែល១០%សម្រាប់ខេត្ត និងតិចជាង១០%សម្រាប់ឃុំ)**។ បន្ថែមលើសនេះ យន្តការសមភាពផ្នែកហិរញ្ញវត្ថុត្រូវបានរៀបចំដោយយន្តការនេះបានដើរតួនាទីយ៉ាងសំខាន់ក្នុងការធានាឱ្យមានតុល្យភាពថវិកានៅតាមបណ្ដាខេត្ត និងឃុំដែលបាត់ផលប្រយោជន៍ដោយសារកត្តាភូមិសាស្ត្រ ឬប្រជាសាស្ត្រ (ការចែករំលែកបន្ទុក) ឬបាត់បង់ផលប្រយោជន៍ផ្នែកសេដ្ឋកិច្ច (សមធម៌សម្រាប់ពង្រឹងស្ថានភាពហិរញ្ញវត្ថុ)។

### ១.៣.៤. ការត្រួតពិនិត្យ និងអធិការកិច្ច

ឃុំមិនមានទំនាក់ទំនងដោយផ្ទាល់ជាមួយរដ្ឋាភិបាលសហព័ន្ធលើការងារត្រួតពិនិត្យ និងការធ្វើអធិការកិច្ចទេ។ ជាបឋម ឃុំត្រូវធានាថា ភាពមិនប្រក្រតីនានាត្រូវបានដោះស្រាយដោយខ្លួនឯង។ ដោយសារកម្រិតស្វ័យភាពរបស់ឃុំត្រូវបានកំណត់ដោយច្បាប់ខេត្ត ដូចនេះ ខេត្តអាចធ្វើកិច្ចអន្តរាគមន៍ប្រសិនបើឃុំមិនអាចដោះស្រាយកិច្ចការរបស់ខ្លួនបាន។ ចំពោះការត្រួតពិនិត្យលើបញ្ហាហិរញ្ញវត្ថុ ខេត្ត Bern មានច្បាប់យ៉ាងតឹងរឹងក្នុងការពិនិត្យមើលស្ថានភាពហិរញ្ញវត្ថុរបស់ឃុំ ដោយខេត្តអាចតាមដានត្រួតពិនិត្យ និងធ្វើកិច្ចអន្តរាគមលើបញ្ហាហិរញ្ញវត្ថុនានា ដូចជា បញ្ហាថវិកា ការដំឡើងអត្រាពន្ធជាដើម។ បន្ថែមលើសនេះ អាជ្ញាធរខេត្តត្រូវទទួលខុសត្រូវក្នុងការធានាថា

បណ្ដាសហគមន៍ និងអាជ្ញាធរឃុំមានកិច្ចដំណើរការការងារជាធម្មតា។ អាជ្ញាធរខេត្តអាចអន្តរាគមន៍ជាក់ស្ដែង ក្នុងករណីដែលក្រុមប្រឹក្សាឃុំមិនមានដំណើរការការងារ ឬមិនបានអនុវត្តកិច្ចការជាកាតព្វកិច្ចមួយចំនួន។ ជាការកត់សម្គាល់ឃុំអាចធ្វើការតតាំងនឹងការសម្រេចចិត្តនានានៅថ្នាក់ខេត្តចំពោះមុខតុលាការជាន់ខ្ពស់របស់សហព័ន្ធ។ ឃុំមានសិទ្ធិតវ៉ាអំពីការរំលោភបំពានលើការធានានានា ដែលបានផ្ដល់ដល់ឃុំដោយរដ្ឋធម្មនុញ្ញសហព័ន្ធ ឬរដ្ឋធម្មនុញ្ញខេត្ត ហើយឧបករណ៍នេះត្រូវបានប្រើប្រាស់ជាញឹកញាប់។

### ១.៣.៤. ការចូលរួមរបស់ប្រជាពលរដ្ឋ និងឧបករណ៍ប្រជាធិបតេយ្យ

ប្រព័ន្ធនយោបាយប្រទេសស្វីសផ្ដល់អំណាចដល់ប្រជាពលរដ្ឋក្នុងការចូលរួមដោយផ្ទាល់នៅក្នុងដំណើរការនយោបាយតាមរយៈ ការបោះឆ្នោត ការពិគ្រោះយោបល់ ការធ្វើប្រជាមតិ ការបង្កើតគំនិតផ្ដួចផ្ដើមរបស់ប្រជាពលរដ្ឋ និងការប្ដឹងតវ៉ា។ ឧបករណ៍ និងយន្តការទាំងនេះ បានជំរុញឱ្យប្រជាពលរដ្ឋស្វីសចូលរួមដោយផ្ទាល់ក្នុងការធ្វើសេចក្ដីសម្រេចចិត្ត និងចូលរួមបោះឆ្នោតលើបញ្ហាសំខាន់ៗមួយចំនួននៅគ្រប់កម្រិត។

នៅថ្នាក់សហព័ន្ធ ប្រជាពលរដ្ឋអាចស្នើសុំឱ្យមានការធ្វើវិសោធនកម្មលើរដ្ឋធម្មនុញ្ញ តាមរយៈការបោះឆ្នោតប្រជាប្រិយភាព (popular vote)។ សម្រាប់ការបង្កើតគំនិតផ្ដួចផ្ដើមថ្មីនៃការធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញទាមទារឱ្យមានប្រជាពលរដ្ឋចុះហត្ថលេខាគាំទ្រចំនួន **១០០.០០០នាក់ឡើង ក្នុងរយៈពេល ១៨ខែ**។ ជាទូទៅ សំណើសុំវិសោធនកម្មលើរដ្ឋធម្មនុញ្ញ ឬការជាសមាជិកក្នុងស្ថាប័នអន្តរជាតិណាធំៗត្រូវធ្វើឡើងតាមរយៈការបោះឆ្នោតដោយប្រជាពលរដ្ឋ។ រីឯការធ្វើវិសោធនកម្មលើច្បាប់សហព័ន្ធ ការសម្រេចចិត្តរបស់រដ្ឋសភា និងសន្ធិសញ្ញាអន្តរជាតិអាចត្រូវធ្វើឡើងតាមរយៈការធ្វើប្រជាមតិក្នុង

លក្ខណៈជាជម្រើស។ ការបោះឆ្នោតដោយប្រជាពលរដ្ឋអាចធ្វើឡើង ប្រសិនបើមានប្រជាពលរដ្ឋចុះហត្ថលេខាចំនួន **៥០.០០០នាក់ ក្នុងរយៈពេល១០០ថ្ងៃ**។ ការធ្វើប្រជាមតិជាជម្រើសមួយ ក៏អាចត្រូវបានរៀបចំឡើងផងដែរ បើសិនមានការស្នើសុំពីរដ្ឋាភិបាលខេត្តចំនួន៨។ ការធ្វើប្រជាមតិមានលក្ខណៈប្រហាក់ប្រហែលនឹងការធ្វើវ៉េតូដែរ។ ច្បាប់ណាមួយដែលមិនទទួលបានជោគជ័យក្នុងការធ្វើប្រជាមតិ នឹងមិនអាចយកទៅអនុវត្តបានឡើយ។

ឧបករណ៍ទាំងនេះក៏ត្រូវបានប្រើប្រាស់ផងដែរនៅថ្នាក់ខេត្ត និងថ្នាក់ឃុំ បើទោះបីជាមានលក្ខណៈខុសគ្នាទៅតាមបរិបទនីមួយៗក៏ដោយ។ នៅថ្នាក់ឃុំ ការធ្វើប្រជាមតិ (ជាកាតព្វកិច្ច និងជម្រើស) ត្រូវបានប្រើប្រាស់ជាទូទៅសម្រាប់បញ្ហានានាដូចជា ការផ្លាស់ប្តូរច្បាប់ឃុំ ថវិកាប្រចាំឆ្នាំ ការចំណាយលើសពីកម្រិតកំណត់ ការកំណត់អត្រាពន្ធ និងច្បាប់ពាក់ព័ន្ធទៅនឹងសំណង់ជាមូលដ្ឋាននានា ជាដើម។ ឃុំមានសេរីភាពក្នុងការកំណត់ និងសម្រេចអំពីទំហំសិទ្ធិក្នុងការចូលរួមនយោបាយ។ ជាទូទៅ ប្រជាពលរដ្ឋគ្រប់រូបមានសិទ្ធិទទួលបាននូវព័ត៌មានអំពីសកម្មភាពរបស់រដ្ឋ និងអាចតវ៉ាដល់អាជ្ញាធរនានាពាក់ព័ន្ធទៅនឹងសកម្មភាពរបស់រដ្ឋដែលបង្កឱ្យមានកង្វល់ជាក់លាក់ណាមួយតាមរយៈនីតិវិធីរដ្ឋបាល ឬនីតិវិធីច្បាប់។

ក្រៅពីឧបករណ៍ខាងលើ ឃុំប្រើប្រាស់ទម្រង់នៃការចូលរួម ឬភាពជាតំណាងក្រោមរូបភាពផ្សេងៗ ដែលមានលក្ខណៈទន់ភ្លន់។ ជាទូទៅ សម្រាប់អាជ្ញាធរខេត្ត និងសហព័ន្ធ ការផ្តល់ព័ត៌មានជាសាធារណៈ តាមរយៈបណ្តាញព័ត៌មាន និងការពិគ្រោះយោបល់លើផែនការ និងសំណើនានាត្រូវបានធ្វើឡើងជាធម្មតា ជាពិសេសក្នុងពេលរៀបចំការធ្វើសេចក្តីសម្រេចចិត្ត។ ឧទាហរណ៍នៅក្រុង Bern បានទាក់ទាញឱ្យមានការចូលរួមពីបណ្តាយន្តការនៅក្នុងកិច្ចការសាធារណៈនានា ដូចជា ការចូលរួមពីសភាយុវជន ក្រុមប្រឹក្សាមាតា

បិតាសិស្ស ក្រុមប្រឹក្សាមនុស្សចាស់ (គណៈកម្មការនៃក្រុមប្រឹក្សាឃុំ) រួមទាំងការចូលរួមពីចលនាជនបរទេសរស់នៅប្រទេសស្វីស តាមរយៈសមាគមជាបងប្អូននានា ដើម្បីចូលរួមរៀបចំ និងកែលំអបរិស្ថានរស់នៅ ជាដើម។

ឧបករណ៍លទ្ធិប្រជាធិបតេយ្យនេះ មានផលវិជ្ជមានច្រើនចំពោះទំនាក់ទំនងរវាងអាជ្ញាធរ និងប្រជាពលរដ្ឋ។ ដូចបានលើកឡើងដោយអភិបាលក្រុង Bern អាជ្ញាធរក្រុងបានទទួលផលប្រយោជន៍ជាច្រើនលើការផ្តល់ព័ត៌មាន និងការពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋនៅដំណាក់កាលដំបូងៗ ដើម្បីចៀសវាងការធ្វើជំទាស់នៅពេលក្រោយ។ ទោះបីមានការពន្យាពេលខ្លះៗ និងធ្វើឱ្យដំណើរការនេះកាន់តែចំណាយខ្ពស់ ប៉ុន្តែការសម្រេចចិត្តត្រូវបានរំពឹងថាមានការឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែង មានតម្លាភាព និងមានគណនេយ្យភាពកាន់តែច្រើន ហើយដំណើរការនៃការចូលរួមនេះជួយឱ្យមានការទទួលយកនូវការធ្វើសេចក្តីសម្រេចចិត្តមួយប្រកបដោយលក្ខណៈរឹងមាំនៅទីបញ្ចប់។

ឧបករណ៍នៃលទ្ធិប្រជាធិបតេយ្យផ្ទាល់នេះ គឺជាឧបករណ៍ដ៏មានឥទ្ធិពលសម្រាប់អង្គការសង្គមស៊ីវិលដែលកំពុងខិតខំធ្វើឱ្យមានការផ្លាស់ប្តូរលើបញ្ហាជាក់លាក់ ឬផលប្រយោជន៍នៃក្រុមណាមួយនៅថ្នាក់មូលដ្ឋាន នៅថ្នាក់ខេត្ត និងនៅថ្នាក់សហព័ន្ធ។ ការរៀបចំគំនិតផ្តួចផ្តើមរបស់ប្រជាពលរដ្ឋអាចជួយដល់ពួកគេក្នុងការទាក់ទាញឱ្យទទួលបាននូវការយកចិត្តទុកដាក់ពីអ្នកកាន់អំណាច ធ្វើឱ្យមានការផ្លាស់ប្តូររបៀបវារៈនយោបាយសម្រាប់ការជជែកវែកញែកជាសាធារណៈ និងចាប់ផ្តើមការផ្លាស់ប្តូរ ប្រសិនបើពួកគេរៀបចំខ្លួនបានល្អ និងអាចបញ្ចុះបញ្ចូលអ្នកបោះឆ្នោតភាគច្រើនឱ្យគាំទ្រពួកគេបាន។ នៅប្រទេសស្វីស មានការយល់ដឹងយ៉ាងទូលំទូលាយអំពីសិទ្ធិក្នុងការបញ្ចេញមតិ ហើយសមាគមនានាបានដើរតួនាទីយ៉ាងសំខាន់ក្នុងការជួយប្រជាពលរដ្ឋ

ឱ្យចូលរួម និងរួមជាកម្លាំងលើបញ្ហាទាំងនេះ។

ប្រទេសស្វីសមានអង្គការសង្គមស៊ីវិលច្រើនដែលមានលក្ខណៈចម្រុះ និងមានការអភិវឌ្ឍ។ ការសិក្សាថ្មីៗបានប៉ាន់ប្រមាណថាសមាគមប្រហែល **១០០.០០០** ត្រូវបានបង្កើតឡើងដែលភាគច្រើននៃសមាគមទាំងនោះមានឫសគល់នៅក្នុងសហគមន៍ថ្នាក់មូលដ្ឋាន។ ច្បាប់រដ្ឋប្បវេណីបានបង្កលក្ខណៈងាយស្រួលក្នុងការបង្កើតសមាគមឯកជនមិនទទួលផលប្រយោជន៍។ សមាគមទាំងនោះទទួលបាននូវភាពស្របច្បាប់ តាមរយៈការអនុម័តលើលក្ខន្តិកៈសមាជិកដោយមិនចាំបាច់មានការត្រួតពិនិត្យ និងការចុះឈ្មោះជាមុន ឬមានកាតព្វកិច្ចក្នុងការរៀបចំរបាយការណ៍ទៅអាជ្ញាធររដ្ឋឡើយ។ អាជ្ញាធររដ្ឋអាចធ្វើកិច្ចអន្តរាគមន៍តាមក្រោយ ក្នុងករណីមានការអនុវត្តសកម្មភាព ឬគោលដៅខុសពីលក្ខន្តិកៈ។

អង្គការសង្គមស៊ីវិលដើរតួនាទីយ៉ាងសំខាន់នៅក្នុងជីវភាពសង្គម និងជីវភាពនយោបាយនៅក្នុងប្រទេសស្វីស។ ការចូលរួមរបស់អង្គការសង្គមស៊ីវិលផ្តោតលើគោលបំណងសំខាន់ៗដូចជា ការរៀបចំសកម្មភាពពាក់ព័ន្ធកីឡា និងការលំហែកំសាន្ត សកម្មភាពវប្បធម៌ (ដូចជាការរៀបចំការប្រគុំតន្ត្រី ឬក្លឹបសិក្សានានា) ការការពារ និងការបញ្ចុះបញ្ចូល ដើម្បីផលប្រយោជន៍ក្រុមជាក់លាក់ណាមួយ (ដូចជា ក្រុមស្ត្រី ក្រុមយុវជន និងក្រុមអ្នកប្រកបការងារអាជីពផ្សេងៗទៀត) សកម្មភាពសាសនា សកម្មភាពពាក់ព័ន្ធការងារមនុស្សធម៌ ការការពារបរិស្ថាន និងការចូលរួមសកម្មភាពពាក់ព័ន្ធនយោបាយជាដើម។

ការងារស្ម័គ្រចិត្ត គឺជាទស្សនទានគន្លឹះនៅក្នុងគោលការណ៍ប្រជាធិបតេយ្យនៅក្នុងប្រទេសស្វីស និងគោលការណ៍ក្នុងការរៀបចំអង្គការសង្គមស៊ីវិលឱ្យមានដំណើរការ។ មានអ្នកស្ម័គ្រចិត្តប្រមាណ **១,៨ លាននាក់** (ធៀបនឹងចំនួនប្រជាជនសរុបប្រមាណ ៩លាននាក់) បានកំពុងចូលរួមដោយ

ស្ម័គ្រចិត្តជាមួយស្ថាប័នផ្សេងៗ។ មានប្រជាជនប្រមាណ **៨០០.០០០នាក់** ផ្សេងទៀតបានកំពុងចូលរួមអនុវត្តសកម្មភាពដោយស្ម័គ្រចិត្តជាមួយបណ្តាសមាគមឯកជននានា (៨០%នៃសមាគមទាំងនោះស្ថិតនៅថ្នាក់មូលដ្ឋាន)។ ការងារស្ម័គ្រចិត្តអាចជាការងារផ្លូវការ (ដូចជា សមាជិកក្រុមប្រឹក្សាឃុំដែលបានជាប់ឆ្នោត ឬក្រុមប្រឹក្សាផ្នែកប្រតិបត្តិរបស់សមាគមណាមួយ...) ឬអាចជាការងារមិនផ្លូវការ (ដូចជា ការគាំទ្រលើសកម្មភាពជាក់លាក់មួយចំនួនពាក់ព័ន្ធនឹងសមាគមមាតាបិតាសិស្សជាដើម)។ អង្គការសង្គមស៊ីវិលភាគច្រើននៅប្រទេសស្វីសជាសមាគមតូចៗ ដែលបានទទួលការគាំទ្រមូលនិធិពីការបង់ប្រាក់របស់សមាជិក ឬពីការផ្តល់មូលនិធិដោយស្ម័គ្រចិត្តពីអ្នកគាំទ្រមួយចំនួន ហើយសមាគមទាំងនោះបានដំណើរការភាគច្រើននៅក្នុងពេលវេលាដែលសមាជិករបស់ពួកគេបានចូលរួមដោយមិនគិតប្រាក់។

ការយល់ដឹងយ៉ាងទូលំទូលាយអំពីសិទ្ធិក្នុងការបញ្ចេញមតិ និងអំពីសមាគមបានដើរតួនាទីយ៉ាងសំខាន់ក្នុងការជួយប្រជាពលរដ្ឋឱ្យចូលរួម និងរួមជាកម្លាំងលើបញ្ហាទូទៅនានាជាច្រើន ជាពិសេសក្នុងវិស័យនយោបាយ។ ឧបករណ៍ប្រជាធិបតេយ្យផ្ទាល់ គឺជាឧបករណ៍ដ៏មានឥទ្ធិពលនៅថ្នាក់មូលដ្ឋាន ថ្នាក់ខេត្ត និងថ្នាក់សហព័ន្ធ។ ការរៀបចំគំនិតផ្តួចផ្តើម ឬប្រជាមតិអាចជួយរដ្ឋសភាក្នុងការលើកឡើងនូវសំឡេង និងអាចឱ្យអាជ្ញាធរយកចំណុចទាំងនោះទៅពិចារណា និងអាចធ្វើឱ្យមានផលប៉ះពាល់ដល់របៀបវារៈនយោបាយ និងការជជែកវែកញែកជាសាធារណៈផងដែរ។

### ១.៣.៦. តួនាទី និងមុខងាររបស់សមាគមរដ្ឋាភិបាលមូលដ្ឋានប្រទេសស្វីស

មានសំណួរជាច្រើនថាតើសំឡេង និងផលប្រយោជន៍របស់ឃុំត្រូវបានគិតគូរយ៉ាងដូចម្តេចនៅក្នុងដំណើរការនៃការធ្វើសេចក្តីសម្រេចចិត្តរបស់ថ្នាក់

ខេត្ត និងថ្នាក់សហព័ន្ធ។ ដូចបានរៀបរាប់កន្លងមកហើយ នៅក្នុងប្រទេសស្វីស ថ្នាក់ខេត្តមានតួនាទីយ៉ាងសំខាន់នៅក្នុងការកំណត់វិសាលភាពនៃកិច្ចការរបស់ឃុំ និងទំនាក់ទំនងអន្តររដ្ឋាភិបាល រចនាសម្ព័ន្ធ ស្តង់ដាសេវារបស់ឃុំ ប្រព័ន្ធផ្តល់មូលនិធិ និងយន្តការធ្វើឱ្យមានសមធម៌ផ្នែកហិរញ្ញវត្ថុជាដើម។ ដូចនេះ វាមានសារៈសំខាន់ណាស់សម្រាប់ឃុំក្នុងការមានឥទ្ធិពលទៅលើការធ្វើសេចក្តីសម្រេចចិត្តនៅក្នុងសភាក៏ដូចជានៅក្នុងរដ្ឋាភិបាលថ្នាក់ខេត្ត ក៏ដូចជាការលើកជាមតិ/សំឡេងនៅក្នុងកិច្ចដំណើរការរដ្ឋបាល ក៏ដូចជាចំពោះសាធារណជនទូទៅ។

នៅបណ្តាខេត្តភាគច្រើន ឃុំនានាបានចូលរួមបង្កើតជាសមាគម ឧ. សមាគមឃុំរបស់ខេត្តBernese (**Association of Bernese Municipalities**) ដែលជាសមាគមតំណាងឱ្យផលប្រយោជន៍ឃុំនៅខេត្តBernese អស់រយៈពេលស្ទើរតែ៧០ឆ្នាំមកហើយ។ ៩៨%នៃឃុំនៅក្នុងខេត្ត គឺជាសមាជិករបស់សមាគម ដែលទទួលបានមូលនិធិទាំងស្រុងពីការបង់ថ្លៃសមាជិកភាព។ សមាគមត្រូវបានគ្រប់គ្រងដោយច្បាប់ឯកជន និងមិនមានឋានៈជាផ្លូវការឡើយ។ គោលបំណងសំខាន់របស់សមាគម គឺធ្វើជាតំណាងផលប្រយោជន៍ដល់ឃុំនៅចំពោះមុខខេត្ត Bernese។ សមាគមនេះ ក៏បានខិតខំប្រឹងប្រែងក្នុងការរក្សាស្វ័យភាពរបស់ឃុំ និងបានប្តេជ្ញាចិត្តចូលរួមក្នុងការងារបែងចែងកិច្ចការ/មុខងាររវាងថ្នាក់ខេត្ត និងថ្នាក់ឃុំ ក៏ដូចជាការរៀបចំឱ្យមានប្រព័ន្ធផ្តល់មូលនិធិសមស្របផងដែរ។ បន្ថែមលើសនេះ សមាគមក៏បានផ្តល់សេវាគាំទ្រមួយចំនួនក្នុងនាមសមាជិករបស់ខ្លួនផងដែរ។

មុខងាររបស់សមាគមត្រូវបានផ្អែកលើគោលការណ៍ទូទៅមួយចំនួន ដែលធានាបាននូវភាពស្របច្បាប់ ភាពគួរឱ្យជឿទុកចិត្តបាន និងសមត្ថភាពរបស់សមាគមក្នុងការធ្វើជាតំណាងឱ្យឃុំទាំងអស់នៅខេត្ត Bernese។ ក្នុង

ចំណោមគោលការណ៍ទាំងនេះ អព្យាក្រឹតភាពខាងផ្នែកនយោបាយ គឺមានសារៈសំខាន់ជាងគេបង្អស់។ សមាគមមិនត្រូវបានអនុញ្ញាតឱ្យប្រកាន់ជំហរណាមួយនៅក្នុងវិវាទរវាងឃុំ និងឃុំឡើយ ប៉ុន្តែត្រូវខិតខំប្រឹងប្រែងធ្វើឱ្យមានតុល្យភាពផលប្រយោជន៍រវាងឃុំនានាប្រកបដោយស្ថាបនា (ពិសេសរវាងឃុំមានធនធាននិងឃុំខ្វះខាងធនធាន ឃុំជនបទនិងឃុំទីប្រជុំជន ឃុំតូចនិងឃុំធំ ឃុំដែលមានប្រជាពលរដ្ឋនិយាយភាសាបារាំងនិងឃុំដែលមានប្រជាពលរដ្ឋនិយាយភាសាអាល្លឺម៉ង់) ព្រមទាំងធ្វើឱ្យប្រសើរឡើងនូវផលប្រយោជន៍រួមដែលមានស្រាប់ និងស្វែងរកដំណោះស្រាយដែលអាចទទួលយកបានដោយឃុំទាំងអស់។ សមាគមត្រូវប្រកាន់ជំហររបស់ខ្លួនចំពោះសេចក្តីព្រាងច្បាប់ បទដ្ឋានគតិយុត្តិ និងគោលនយោបាយនានារបស់ខេត្តដែលពាក់ព័ន្ធនឹងផលប្រយោជន៍របស់ឃុំ ទោះបីជានៅក្នុងដំណើរការពិគ្រោះយោបល់ជាផ្លូវការ (មានលក្ខណៈទូទៅនៅក្នុងប្រទេសស្វីស) ឬក៏មិនផ្លូវការក៏ដោយ។ ដោយហេតុថាសមាជិកក្រុមប្រឹក្សាភិបាលនៃសមាគមជាអ្នកនយោបាយមូលដ្ឋានដ៏សកម្ម និងបានចូលរួមយ៉ាងសកម្មក្នុងឆាកនយោបាយថ្នាក់ខេត្ត និងជារឿយៗក៏ជាសមាជិកសភាខេត្តផង ធ្វើឱ្យសមាគមកាន់តែមានឥទ្ធិពលក្នុងផ្នែកនយោបាយនៅថ្នាក់ខេត្ត។ ការផ្តល់សេវាដ៏មានអត្ថប្រយោជន៍ និងប្រសិទ្ធភាពដល់សមាជិករបស់ខ្លួន បានជួយឱ្យសមាគមកាន់តែរឹងមាំនៅក្នុងកិច្ចការរបស់ឃុំដែលផ្តោតសំខាន់លើការអនុវត្ត និងការដោះស្រាយបញ្ហានានារបស់ឃុំ។ សមាគមបានរៀបចំកិច្ចប្រជុំផ្សព្វផ្សាយព័ត៌មានជាសាធារណៈ និងវេទិកានានាជាប្រចាំ ដើម្បីផ្តល់ព័ត៌មានដល់បណ្តាឃុំនានា អំពីផែនការ និងកំណែទម្រង់សំខាន់ៗ ក៏ដូចជាការប្រមូលមតិយោបល់នានាផងដែរ។ សមាគមបានធ្វើការស្ទាបស្ទង់មតិជាទៀងទាត់ ដើម្បីកំណត់អំពីជំហរនានារបស់ឃុំ។ បន្ថែមលើសនេះ សមាគមក៏បានផ្តល់សេវាប្រឹក្សាយោបល់ផ្នែកច្បាប់ និងផ្តល់សេវាគាំទ្រ

ដល់សមាជិករបស់ខ្លួនផងដែរ។ ជាមួយគ្នានេះ សមាគមក៏បានចូលរួមនៅក្នុងសកម្មភាពអប់រំ និងបណ្តុះបណ្តាលវិជ្ជាជីវៈដល់បុគ្គលិកឃុំ និងបានផ្តល់ការអភិវឌ្ឍសមត្ថភាពដល់អ្នកនយោបាយមូលដ្ឋានផងដែរ ដោយមានកិច្ចសហការជាមួយសមាគម និងគ្រឹះស្ថានអប់រំនានា។

នៅថ្នាក់សហព័ន្ធ មានសមាគមចំនួន២ ជាតំណាងឱ្យផលប្រយោជន៍របស់ឃុំ។ តាំងពីឆ្នាំ១៩៥៣មក សមាគមឃុំស្វីស (Swiss Association of Municipalities-SGV) តំណាងឱ្យផលប្រយោជន៍ និងជំហររួមរបស់បណ្តាឃុំនានាទូទាំងប្រទេសស្វីស ចំពោះមុខអាជ្ញាធរនានានៅថ្នាក់សហព័ន្ធ។ **៧១% នៃឃុំទាំង២១៣១នាពេលបច្ចុប្បន្ន** គឺជាសមាជិកនៃសមាគមនេះ។ សមាគមនេះ ខិតខំក្នុងការពង្រឹងជំហររបស់ឃុំនានានៅចំពោះមុខរដ្ឋសហព័ន្ធ។ សមាគមមានគោលបំណង ដើម្បីចូលរួមចំណែកដល់ការកាត់បន្ថយវិសមភាពហិរញ្ញវត្ថុរវាងឃុំនិងឃុំ រវាងតំបន់និងតំបន់ ព្រមទាំងជំរុញនូវការលើកកម្ពស់ប្រសិទ្ធភាព ប្រសិទ្ធផល នវានុវត្ត និងភាពងាយស្រួលសម្រាប់ប្រជាពលរដ្ឋក្នុងការទទួលសេវានៅក្នុងឃុំនានានៅក្នុងប្រទេសស្វីស។ ក្នុងនាមជាសមាគមថ្នាក់ជាតិ និងឯករាជ្យភាពផ្នែកនយោបាយសម្រាប់គ្រប់ឃុំទាំងអស់ សមាគមនេះ មានគោលបំណងក្នុងការធ្វើឱ្យប្រសើរឡើងដល់សមត្ថភាព និងការបំពេញការងាររបស់ឃុំដែលជាសមាជិក ដើម្បីលើកកម្ពស់កិច្ចសហប្រតិបត្តិការនិងសាមគ្គីភាពរវាងឃុំនិងឃុំ និងដើម្បីគាំទ្រដល់ឃុំក្នុងការការពារលើស្វ័យភាពលើការរៀបចំកិច្ចការនានានៅចំពោះមុខថ្នាក់ខេត្ត និងថ្នាក់សហព័ន្ធ។ សមាគមនេះក៏បានគិតគូរអំពីផលប្រយោជន៍ឃុំ ជាពិសេសនៅតំបន់ភ្នំ ឃុំនៅជនបទ តំបន់និយាយភាសាទាំងបួន និងតំបន់ផ្សេងៗទៀត។ សមាគមបានផ្តល់សេវាគាំទ្រ និងផ្តល់វេទិកាសម្រាប់ឃុំនានាក្នុងការផ្លាស់ប្តូរចំណេះដឹង មេរៀនបទពិសោធន៍ និងការអនុវត្តល្អៗ ព្រមទាំងការដោះស្រាយបញ្ហានានាពាក់ព័ន្ធនឹងការគ្រប់គ្រង

រដ្ឋបាលមូលដ្ឋាន ហេដ្ឋារចនាសម្ព័ន្ធ និងការអភិវឌ្ឍមូលដ្ឋានផងដែរ។

សមាគមទីក្រុងស្វីស (Swiss Association of Cities-SSV) ត្រូវបានបង្កើតឡើងនៅឆ្នាំ ១៨៩៧ ដែលបច្ចុប្បន្នមានសមាជិកចំនួន១៣០។ បេសកកម្មជាចម្បងរបស់សមាគមនេះ គឺតស៊ូមតិសម្រាប់ផលប្រយោជន៍ឃុំនៅក្នុងតំបន់ទីប្រជុំជននៅចំពោះមុខអាជ្ញាធរថ្នាក់សហព័ន្ធស្វីស។ សមាគមនេះ បានចូលរួមយ៉ាងសកម្មនៅក្នុងដំណើការពិគ្រោះយោបល់នានានៅថ្នាក់សហព័ន្ធ សហការជាមួយគណៈកម្មការជំនាញនានា និងរក្សានូវទំនាក់ទំនងជាប្រចាំជាមួយរដ្ឋសភា និងរដ្ឋបាលសហព័ន្ធ។ ជាការគួរឱ្យកត់សម្គាល់ ទីក្រុងហ្ស៊ូរិច (Zurich) ដែលជាទីក្រុងដែលមានទំហំធំ បានដើរតួនាទីយ៉ាងសំខាន់នៅក្នុងការកំណត់គោលនយោបាយទីប្រជុំជននៅក្នុងប្រទេសស្វីស។

### ១.៣.៧. ប្រព័ន្ធប៉ូលីសនៅប្រទេសស្វីស

នៅថ្នាក់សហព័ន្ធ មានអង្គភាពប៉ូលីសជាច្រើន។ អង្គភាពទាំងនេះមានសមត្ថកិច្ច និងការទទួលខុសត្រូវលើការស៊ើបអង្កេតបទឧក្រិដ្ឋដែលមានការរៀបចំកិច្ចការពាក់ព័ន្ធការជួញដូរមនុស្ស ការរត់ពន្ធ ការលាងលុយកខ្វក់ ការដោះស្រាយអំពើពុករលួយ ការដោះស្រាយឧក្រិដ្ឋកម្មដែលមានលក្ខណៈស្មុគស្មាញពាក់ព័ន្ធអន្តរជាតិ និងអន្តរកម្ម ការប្រឆាំងភេរវកម្ម និងការផ្តល់ហិរញ្ញវត្ថុដល់ភេរវៈករជាដើម។ ខេត្តគឺជាសមាសភាពដ៏ចម្បងនៃរដ្ឋាភិបាលសហព័ន្ធ ហេតុដូច្នេះជាទូទៅនគរបាលគឺស្ថិតនៅក្រោមការគ្រប់គ្រងរបស់ថ្នាក់ខេត្ត និងឃុំ។ ថ្នាក់ខេត្ត និងថ្នាក់ឃុំមានសេរីភាពក្នុងការជ្រើសរើស និងប្រើប្រាស់កម្លាំងប៉ូលីសទៅតាមតម្រូវការរបស់ខ្លួន។ គិតត្រឹមខែមករា ឆ្នាំ ២០២២ កងកម្លាំងប៉ូលីសមានចំនួនសរុប **២៥.៦៩៤នាក់** ក្នុងនោះ **១៤.៩៥០នាក់**ជាកម្លាំងប៉ូលីសនៅថ្នាក់ខេត្ត និងថ្នាក់ឃុំ។ តួលេខនេះធ្វើឱ្យ

ដង់ស៊ីតេរបស់ប៉ូលីសធៀបនឹងចំនួនប្រជាជនស្មើនឹង **១/៤៤៧**។ ទោះបីជាយ៉ាងណាក៏ដោយ តួលេខនេះមានភាពខុសគ្នាពីខេត្តមួយទៅខេត្តមួយក្នុងចន្លោះពី **១/៣០១ ដល់ ១/៧៣៧**។

ប៉ូលីសចំនួន ២៦កង (ឬអង្គភាព) ស្ថិតនៅថ្នាក់ខេត្ត និងចំនួន ៩០ កងនៅថ្នាក់ឃុំ។ មកទល់ពេលនេះ កងប៉ូលីសថ្នាក់ឃុំមាននៅក្នុងខេត្តចំនួន ១០ប៉ុណ្ណោះ ហើយពួកគេ គឺជាផ្នែកមួយនៃសមាគមកងកម្លាំងប៉ូលីសឃុំនៃប្រទេសស្វីស។ កងប៉ូលីសខេត្ត និងឃុំដើរតួនាទីយ៉ាងសំខាន់ក្នុងការធានាសុវត្ថិភាពសាធារណៈនៅក្នុងដែនដីរបស់ពួកគេ ដោយធ្វើប្រតិបត្តិការអនុលោមទៅតាមក្របខណ្ឌច្បាប់។ ពួកគេបានផ្តល់សេវាប៉ូលីសដល់ប្រជាពលរដ្ឋប្រកបដោយស្វ័យភាព រួមទាំងការស៊ើបអង្កេតលើបទឧក្រិដ្ឋមួយចំនួនផងដែរ។

វេទិកាមេបញ្ជាការប៉ូលីសថ្នាក់ខេត្តនៃប្រទេសស្វីសដែលបានបង្កើតឡើងតាំងពីឆ្នាំ១៨៩៦ គឺជាសមាគមដែលមានសមាជិកចំនួន៣១ ក្នុងនោះរួមមានមេបញ្ជាការនៃកងប៉ូលីសមកពីខេត្តទាំង២៦ មេបញ្ជាការប៉ូលីសទីក្រុង Zurich នាយកការិយាល័យប៉ូលីសសហព័ន្ធ នាយកវិទ្យាស្ថានប៉ូលីសស្វីស និងប្រធានសមាគមមេប៉ូលីសឃុំនៃប្រទេសស្វីស។ វេទិកាមេបញ្ជាការប៉ូលីសថ្នាក់ខេត្តនៃប្រទេសស្វីសមានគោលដៅជំរុញកិច្ចសហប្រតិបត្តិការ ការផ្លាស់ប្តូរគំនិតយោបល់ និងបទពិសោធន៍ ការបង្កើតឯកសណ្ឋានប៉ូលីស និងយុទ្ធសាស្ត្រនានា។ វេទិកានេះផ្តោតផងដែរលើការអប់រំបណ្តុះបណ្តាលតាមតម្រូវការប្រកបដោយនិរន្តរភាព ក៏ដូចជាការប្រើប្រាស់កម្លាំងសរុបនៅគ្រប់ទិដ្ឋភាពក្នុងវិស័យប៉ូលីស។ ទោះបីជាវេទិកានេះមិនមានអំណាចក្នុងការចេញសេចក្តីណែនាំណាមួយដល់សមាជិករបស់ខ្លួនយ៉ាងណាក៏ដោយ ប៉ុន្តែវេទិកាអាចផ្តល់ជាអនុសាសន៍បាន។

នៅក្នុងកិច្ចប្រតិបត្តិការការងារប្រចាំថ្ងៃ កងកម្លាំងប៉ូលីសបានសហការ

ជាមួយដៃគូពាក់ព័ន្ធជាច្រើន រួមមាន កងអាវុធហត្ថ (សម្រាប់ដោះស្រាយកិច្ចការដែលមានការទទួលខុសត្រូវរួមគ្នាពាក់ព័ន្ធការការពារទ្រព្យសម្បត្តិ) សេវាស៊ើបការណ៍សហព័ន្ធ (ដោះស្រាយបញ្ហាសន្តិសុខជាតិ) ការិយាល័យសហព័ន្ធសម្រាប់ការពារព្រំដែន និងគយ (ដោះស្រាយលើកិច្ចការការពារព្រំដែន) និងបណ្តាញសន្តិសុខស្វីស រួមចំណែកលើការងារសន្តិសុខផ្ទៃក្នុង តាមរយៈការពិគ្រោះយោបល់ ការសម្របសម្រួលលើការសម្រេចចិត្ត ធនធាន និងវិធានការនានាដែលត្រូវអនុវត្តរួមគ្នាដោយរដ្ឋាភិបាលសហព័ន្ធ និងខេត្ត ដើម្បីដោះស្រាយបញ្ហាប្រឈមលើគោលនយោបាយសន្តិសុខ។

## ២. ប្រព័ន្ធអភិបាលកិច្ចនៃប្រទេសអាល្លឺម៉ង់

### ២.១. អំពីទិដ្ឋភាពទូទៅនៃប្រទេសអាល្លឺម៉ង់

ប្រទេសអាល្លឺម៉ង់ មានឈ្មោះជាផ្លូវការថា សាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ ជាប្រទេសមួយស្ថិតនៅភាគកណ្តាល និងភាគខាងលិចនៃទ្វីបអឺរ៉ុប។ ប្រទេសនេះមានក្រឡាផ្ទៃសរុបប្រមាណ **៣៥៧.០២២គីឡូម៉ែត្រការ៉េ** មានប្រជាជនសរុប **៨២,៣លាននាក់** និងមានដង់ស៊ីតេប្រជាជនប្រមាណ **២៣២នាក់/គីឡូម៉ែត្រការ៉េ**។ ប្រទេសអាល្លឺម៉ង់មានទេសភាពចម្រុះ និងមានអាកាសធាតុប្រែប្រួលទៅតាមរដូវកាល ដោយនៅរដូវរងារមានសីតុណ្ហភាពត្រជាក់ខ្លាំង និងធ្លាក់ព្រឹលនៅតំបន់មួយចំនួន ហើយនៅរដូវក្តៅមានសីតុណ្ហភាពក្តៅល្មម និងទទួលរងរលកកម្តៅម្តងៗផងដែរ។ គិតត្រឹមឆ្នាំ២០២២ ផលិតផលក្នុងស្រុកសរុបសម្រាប់ប្រជាជនមួយនាក់ (GDP/Capita) នៅក្នុងប្រទេសអាល្លឺម៉ង់មានប្រមាណ **៤៣.៣៦១ដុល្លារ/ឆ្នាំ**។ តួលេខនេះបង្ហាញថា ប្រទេសអាល្លឺម៉ង់ជាប្រទេសដែលមានសេដ្ឋកិច្ចរឹងមាំ ដោយសារការរីកចម្រើនលើការកែច្នៃផ្នែកវិស្វកម្ម និងឧស្សាហកម្មគ្រឿងយន្ត។

### ២.២. ការរៀបចំរដ្ឋាភិបាលពហុកម្រិតនៅប្រទេសអាល្លឺម៉ង់

រដ្ឋាភិបាលមូលដ្ឋាននៃប្រទេសអាល្លឺម៉ង់ជាផ្នែកមួយនៅក្នុងប្រព័ន្ធអភិបាលកិច្ចពហុកម្រិតដែលមាន**កម្រិតសហព័ន្ធ (ថ្នាក់ជាតិ) កម្រិតរដ្ឋ និងកម្រិតមូលដ្ឋាន**។ រដ្ឋធម្មនុញ្ញសហព័ន្ធបានកំណត់អំពីការបែងចែកមុខងាររវាងកម្រិតសហព័ន្ធ និងកម្រិតរដ្ឋ ព្រមទាំងបានកំណត់អំពីយន្តការសម្រាប់សម្របសម្រួល និងធ្វើកិច្ចសហប្រតិបត្តិការផងដែរ។ ដែនសមត្ថកិច្ចរបស់រដ្ឋាភិបាលមូលដ្ឋានត្រូវបានចែងនៅថ្នាក់រដ្ឋ តាមរយៈច្បាប់សម្រាប់រដ្ឋាភិបាលមូលដ្ឋាន។ ច្បាប់សហព័ន្ធមិនបានចែងអំពីរដ្ឋាភិបាលមូលដ្ឋានទេ ប៉ុន្តែរដ្ឋធម្មនុញ្ញ

បានធានាឱ្យមានការរៀបចំរដ្ឋាភិបាលមូលដ្ឋាន ដោយបានផ្តល់អាណត្តិឱ្យថ្នាក់រដ្ឋជាអ្នកទទួលខុសត្រូវក្នុងការផ្តល់ថវិកាដល់រដ្ឋាភិបាលមូលដ្ឋានឱ្យបានគ្រប់គ្រាន់។

ប្រព័ន្ធសហព័ន្ធនៅប្រទេសអាល្លឺម៉ង់ផ្អែកលើគោលការណ៍សំខាន់ៗជាច្រើន (១). លទ្ធិប្រជាធិបតេយ្យ និងនីតិរដ្ឋ (២). គោលបំណងសម្រេចបាននូវជីវភាពរស់នៅដែលមានលក្ខណៈប្រហាក់ប្រហែលគ្នានៅគ្រប់តំបន់ទាំងអស់ទូទាំងប្រទេស (៣). កិច្ចសហប្រតិបត្តិការ និងការប្រកួតប្រជែង (៤). សហព័ន្ធនិយមប្រកបដោយកិច្ចសហប្រតិបត្តិការ និងប្រតិបត្តិការ (៥). សារពើពន្ធបែបសហព័ន្ធនិយម និង(៦). ការបើកចំហក្នុងការធ្វើកំណែទម្រង់លើការរៀបចំសហព័ន្ធក្នុងពេលចាំបាច់។ កម្រិតសហព័ន្ធមានឥទ្ធិពលគ្របដណ្តប់លើការបង្កើតគោលនយោបាយ និងច្បាប់នានា ខណៈពេលដែលកម្រិតរដ្ឋមានឥទ្ធិពលគ្របដណ្តប់លើការអនុវត្តគោលនយោបាយ និងមានចំណែកធំបំផុតលើការគ្រប់គ្រងរដ្ឋបាលសាធារណៈ។ ទោះបីជាយ៉ាងណាក៏ដោយ ឥទ្ធិពលគ្របដណ្តប់លើការបង្កើតគោលនយោបាយត្រូវបានរារាំងដោយការចូលរួមរបស់ថ្នាក់រដ្ឋនៅក្នុងដំណើរការនីតិប្បញ្ញត្តិ។ ក្រុមប្រឹក្សាសហព័ន្ធតំណាងឱ្យរដ្ឋាភិបាលរដ្ឋទាំង១៦ ត្រូវតែអនុម័តច្បាប់នានារបស់សហព័ន្ធដែលមានឥទ្ធិពលលើកិច្ចប្រតិបត្តិការរដ្ឋបាលនៅរដ្ឋរបស់ខ្លួន។

ប្រព័ន្ធហិរញ្ញវត្ថុសារពើព័ន្ធសហព័ន្ធផ្តោតលើស្វ័យភាពរបស់រដ្ឋបាលគ្រប់កម្រិត ក្នុងការផ្តល់មូលនិធិលើកិច្ចការនានារបស់ពួកគេ ការប្រមូលពន្ធរួមគ្នា និងដោយឡែកពីគ្នា យន្តការសមភាពហិរញ្ញវត្ថុខ្សែទទឹង និងខ្សែបណ្តោយ យន្តការផ្តល់មូលនិធិលើកិច្ចការរួមគ្នា ព្រមទាំងជំនួយហិរញ្ញវត្ថុនានាដល់បណ្តារដ្ឋដែលមានសមត្ថភាពហិរញ្ញវត្ថុទាប។ ចាប់តាំងពីឆ្នាំ២០០៩មករដ្ឋធម្មនុញ្ញបានចែងអំពីកម្រិតខ្ពស់បំផុតសម្រាប់បំណុលសាធារណៈនៅថ្នាក់

ជាតិ និងថ្នាក់រដ្ឋ (ហ្វ្រាំងទប់បំណុល=Debt Brake) ដែលតាមខ្លឹមសារនៃរដ្ឋធម្មនុញ្ញនេះ បានកម្រិតអំពីកម្ចីសាធារណៈ។

រដ្ឋាភិបាលសហព័ន្ធមិនមានសិទ្ធិត្រួតពិនិត្យតាមឋានានុក្រម ឬការត្រួតពិនិត្យលើផ្នែកច្បាប់របស់បណ្តារដ្ឋទាំងឡាយឡើយ។ ថ្វីត្បិតតែថ្នាក់រដ្ឋទាំងនេះទទួលបាននូវស្វ័យភាពដ៏ធំធេងនេះក៏ដោយ ក៏ប៉ុន្តែអំណាចខាងនីតិប្រតិបត្តិរបស់ថ្នាក់រដ្ឋត្រូវបានកម្រិត (ឧ. នៅក្នុងវិស័យប៉ូលីស សាលារៀន និងវប្បធម៌)។ ជាលទ្ធផល អង្គនីតិប្រតិបត្តិនៅថ្នាក់សហព័ន្ធមានការជាប់ពាក់ព័ន្ធដោយផ្ទាល់បន្តិចបន្តួចប៉ុណ្ណោះនៅក្នុងការអនុវត្ត និងការផ្តល់សេវាសាធារណៈ អាស្រ័យហេតុនេះ រដ្ឋាភិបាលសហព័ន្ធមិនមានការិយាល័យប្រតិបត្តិការនានានៅថ្នាក់តំបន់ ឬថ្នាក់មូលដ្ឋានឡើយ លើកលែងតែវិស័យការពារជាតិ កិច្ចការគយ ការងារដឹកជញ្ជូនផ្លូវទឹក និងការងារប៉ូលីសសហព័ន្ធ។

នៅក្នុងការអនុវត្តជាក់ស្តែង កម្រិតថ្នាក់ទាំងពីរនេះមានទំនាក់ទំនងជាមួយគ្នាយ៉ាងជិតស្និត។ ការប្រាស្រ័យទាក់ទងនានាលើកិច្ចសហប្រតិបត្តិការអាចមានភាពខុសគ្នាខ្លាំងរវាងអង្គភាពដែលមានទំនាក់ទំនងតែជាមួយថ្នាក់រដ្ឋ (កិច្ចសហប្រតិបត្តិការខ្សែទទឹង) និងអង្គភាពដែលមានទំនាក់ទំនងទាំងជាមួយថ្នាក់រដ្ឋផង និងថ្នាក់សហព័ន្ធផង (កិច្ចសហប្រតិបត្តិការខ្សែបណ្តោយ)។ កិច្ចសហប្រតិបត្តិការទាំងពីរទម្រង់នេះ មានចែងជាផ្លូវការនៅក្នុងច្បាប់ លិខិតបទដ្ឋាននានា ឬស្ថិតនៅក្នុងការរៀបចំស្ថាប័នជាផ្លូវការ (កិច្ចសហប្រតិបត្តិការជាផ្លូវការ) ឬត្រូវបានទទួលយកជាមេរៀនបទពិសោធន៍ល្អក្រោយពេលអនុវត្ត (កិច្ចសហប្រតិបត្តិការមិនផ្លូវការ)។ ភាពជំពាក់វាក់វិនគ្នាលើការទទួលខុសត្រូវរបស់សហព័ន្ធ និងរដ្ឋដែលកំពុងមានការកើនឡើងថ្មីៗបានធ្វើឱ្យការទទួលខុសត្រូវកាន់តែមានភាពលំបាក ព្រមទាំងបានជំរុញឱ្យមានការកែទម្រង់នៅក្នុងប្រព័ន្ធសហព័ន្ធនៅឆ្នាំ២០០៦ និងឆ្នាំ២០០៩ ក្នុងគោលបំណង ដើម្បី

ស្វែងរកដំណោះស្រាយពាក់ព័ន្ធនឹងការទទួលខុសត្រូវលើការអនុវត្តមុខងារ និងដើម្បីចៀសវាងការអនុវត្តមុខងារត្រួតស៊ីគ្នា។

រដ្ឋាភិបាលសហព័ន្ធមិនមានសិទ្ធិត្រួតពិនិត្យតាមឋានានុក្រម ឬការត្រួតពិនិត្យលើផ្នែកច្បាប់របស់បណ្តារដ្ឋទាំងឡាយឡើយ ដូចនេះ បញ្ហាខ្សែគណនេយ្យភាពរបស់ថ្នាក់រដ្ឋទៅថ្នាក់សហព័ន្ធមិនមានអ្វីកើតឡើងឡើយ គឺរដ្ឋមានគណនេយ្យភាពចំពោះតែប្រជាពលរដ្ឋប៉ុណ្ណោះ។ ទោះបីយ៉ាងណាក៏ដោយ បណ្តារដ្ឋត្រូវគោរព និងអនុវត្តតាមច្បាប់របស់ថ្នាក់ជាតិ ហើយត្រូវបង្ខំឱ្យអនុវត្តតាមរយៈប្រព័ន្ធតុលាការ។

បណ្តារដ្ឋមានតួនាទីចម្បងក្នុងការគ្រប់គ្រងកិច្ចការប៉ូលីស។ ប៉ូលីសសហព័ន្ធ ជាធម្មតាមានចំនួនតិច**ប្រហែល៥៤.០០០នាក់** (ឆ្នាំ២០២២) ដែលមានមុខងារចម្បងៗ ដូចជា ការពារព្រំដែន ការពារអគារ និងស្ថាប័នរបស់សហព័ន្ធ ការពារផ្លូវដែក និងអាកាសយានដ្ឋាន។ កម្លាំងប៉ូលីសរបស់បណ្តារដ្ឋមានកម្លាំង**ប្រហែល៣៥០.០០០នាក់** (ឆ្នាំ២០២១) ហើយស្ថិតក្រោមការទទួលខុសត្រូវរបស់ក្រសួងមហាផ្ទៃនៅថ្នាក់រដ្ឋ។

### ២.២.១. ប្រភេទអង្គភាពរដ្ឋបាលមូលដ្ឋាន

រដ្ឋធម្មនុញ្ញប្រទេសអាល្លឺម៉ង់មិនបានចាត់ទុករដ្ឋាភិបាលមូលដ្ឋានជារដ្ឋាភិបាលកម្រិតទី៣ឡើយ ប៉ុន្តែបានចាត់ទុកជាផ្នែកមួយនៃរដ្ឋបាលរបស់ថ្នាក់រដ្ឋ។ អ្នកជំនាញ និងអ្នកសិក្សាភាគច្រើនដែលបានសិក្សាទៅលើរដ្ឋធម្មនុញ្ញបានអះអាងថា ក្រុមប្រឹក្សាមូលដ្ឋានមិនអាចបង្កើតអង្គនីតិប្បញ្ញត្តិ ឬសភាបានទេ។ ដូចគ្នានេះដែរ ក្រុមប្រឹក្សាមិនអាចដាក់ចេញជាឧបករណ៍ច្បាប់ ដើម្បីដាក់ឱ្យអនុវត្តសម្រាប់ប្រជាពលរដ្ឋ និងអង្គភាពពាណិជ្ជកម្មនានា។

ដោយសាររដ្ឋទាំង១៦ មានដែនសមត្ថកិច្ចក្នុងការកំណត់ប្រព័ន្ធ

រដ្ឋាភិបាលមូលដ្ឋានរបស់ខ្លួន (ច្បាប់សហព័ន្ធមិនបានចែងទេ) ដូចនេះ ប្រភេទអង្គភាពរដ្ឋបាលមូលដ្ឋានពីរដ្ឋមួយទៅរដ្ឋមួយមានលក្ខណៈខុសៗគ្នា ជាពិសេសលើការបែងចែកមុខងារ និងការរៀបចំរចនាសម្ព័ន្ធ ដូចជាដំណើរការបោះឆ្នោត និងតួនាទីភារកិច្ចរបស់មេឃុំ/ឬអភិបាលក្រុង។ល។ ទោះបីជាយ៉ាងណាក៏ដោយ ជាទូទៅអង្គភាពទាំងនេះ មានលក្ខណៈប្រហាក់ប្រហែលគ្នាមួយចំនួនត្រូវបានគេសង្កេតឃើញនៅក្នុងបណ្តារដ្ឋនានាដូចជា៖

**រូបភាពទី១៖ ផែនទីប្រទេសអាល្លឺម៉ង់**




- ឃុំត្រូវបានគេចាត់ទុកថាជាសរសរស្តម្ភនៃរដ្ឋបាលសាធារណៈ (រួមជាមួយរដ្ឋបាលថ្នាក់រដ្ឋ) ជាពិសេសសម្រាប់ការផ្តល់សេវាសង្គមនានានៅឃុំ
- ឃុំមានភាពជានីតិបុគ្គលក្រោមច្បាប់រដ្ឋបាលសាធារណៈ និងច្បាប់រដ្ឋប្បវេណី
- ឃុំត្រូវបានធានាដោយរដ្ឋធម្មនុញ្ញអំពីសិទ្ធិក្នុងការគ្រប់គ្រងបញ្ហានានានៅសហគមន៍មូលដ្ឋាន ដែលជាផ្នែកមួយនៃការទទួលខុសត្រូវក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ ក្រៅពីនេះ ឃុំមានមុខងារ

ជាអាណត្តិទូទៅ ឬសមត្ថកិច្ចទូទៅក្នុងការអនុវត្តកិច្ចការមូលដ្ឋាន។

ប្រព័ន្ធគ្រប់គ្រងរដ្ឋាភិបាលមូលដ្ឋាន រួមមានអង្គភាពរដ្ឋបាលមូលដ្ឋានដូចខាងក្រោម៖

- **ឃុំ** (Municipality)៖ គឺជាអង្គភាពនៅមូលដ្ឋានកម្រិតទាបបំផុត។ ឃុំ គឺជាពាក្យទូទៅមួយសំដៅចំពោះរដ្ឋាភិបាលមូលដ្ឋានដែលមានលក្ខណៈជាទីប្រជុំជន ឬជនបទ និងសំដៅចំពោះរដ្ឋាភិបាលមូលដ្ឋានដែលមានទំហំផ្សេងៗគ្នា។ យោងតាមប្រវត្តិឃុំ ត្រូវបានកើតឡើងមុនស្ថាប័នផ្លូវការនានារបស់រដ្ឋ ដូចនេះឃុំត្រូវបានចាត់ទុកថាជាអង្គភាពពិសេសមួយនៅក្នុងរចនាសម្ព័ន្ធនយោបាយ និងរដ្ឋបាលរបស់ប្រទេសអាល្លឺម៉ង់
- **ស្រុក** (county)៖ ស្រុកត្រូវបានចាត់ថ្នាក់ជាសមាគម/បណ្តុំនៃឃុំ ដោយសារឃុំភាគច្រើនស្ថិតនៅក្នុងដែនដីរបស់ស្រុក និងជាសមាជិករបស់ស្រុក។ ស្រុកមានមុខងារពីរ៖ (១). មានតួនាទីជារដ្ឋាភិបាលមូលដ្ឋាន និង (២). ជាអ្នកអនុវត្តកិច្ចការនានាដែលបានធ្វើប្រតិភូកម្ម (ស្រុកមានកម្រិតស្វ័យភាព និងសិទ្ធិក្នុងការធ្វើសេចក្តីសម្រេចចិត្តក្នុងកម្រិតជាក់លាក់ណាមួយ) និងវិសហវិមជ្ឈការ (ស្រុកពុំមានសិទ្ធិក្នុងការធ្វើសេចក្តីសម្រេចចិត្តឡើយ) ពីថ្នាក់រដ្ឋ។ រដ្ឋបាលស្រុកភាគច្រើនមានលក្ខណៈជនបទ ទោះបីស្រុកទាំងនោះបានបញ្ចូលឃុំដែលមានលក្ខណៈទីប្រជុំជនក៏ដោយ។
- **ទីក្រុងស្វយ័ត** (Cities not affiliated with a district)៖ ជាទីក្រុងដែលមិនស្ថិតក្រោមការគ្រប់គ្រងរបស់ស្រុក ហើយត្រូវបានចាត់ថ្នាក់ជាអង្គភាពដាច់ដោយឡែក។ មិនទាន់មានច្បាប់ណាមួយកំណត់ច្បាស់លាស់អំពីចំនួនប្រជាជន ឬទំហំជាក់លាក់សម្រាប់

ក្រុងនៅឡើយទេ ដូចករណីទីក្រុងតូច**ស៊ូល** (Suhl) មានប្រជាជនត្រឹមតែចំនួន **៣៧.០០០នាក់** រីឯទីក្រុងធំដូចជា**ប៊ែកឡាំង** (Berlin) មានប្រជាជនច្រើនរហូតដល់ **៣,៥លាននាក់**។ ថ្នាក់រដ្ឋមានបុព្វសិទ្ធិក្នុងការកំណត់ចំណាត់ថ្នាក់ទីក្រុង។ ដូចស្រុកដែរ ទីក្រុងស្វយ័ត មានតួនាទីពីរ គឺ (១). ដើរតួនាទីជាអង្គភាពរដ្ឋាភិបាលមូលដ្ឋានផង និង(២). អនុវត្តតួនាទីជារដ្ឋបាលកម្រិតទាបបំផុតនៃរដ្ឋបាលរបស់ថ្នាក់រដ្ឋផង។

រដ្ឋាភិបាលមូលដ្ឋានទាំងបីប្រភេទខាងលើនេះ មាននៅគ្រប់រដ្ឋទាំងអស់នៃប្រទេសអាល្លឺម៉ង់។ គិតត្រឹមឆ្នាំ២០២៤ មានឃុំសរុបប្រមាណ **១១.០០០ឃុំ** (ប្រជាជនជាមធ្យម **៥.០០០នាក់**) មានស្រុកចំនួន **២៩៤ស្រុក** (ប្រជាជនជាមធ្យម **១៩០.០០០នាក់**) និងមានទីក្រុងស្វយ័តចំនួន **១០៦ទីក្រុង** (ប្រជាជនជាមធ្យម **២៥០.០០០នាក់**) (សូមមើលរូបភាពទី២)។

**រូបភាពទី២៖ កម្រិតរដ្ឋបាលថ្នាក់ក្រោមជាតិ និងថ្នាក់ជាតិនៅប្រទេសអាល្លឺម៉ង់**




នៅថ្នាក់ស្រុក និងទីក្រុងស្វយ័ត មានការរៀបចំចាត់ចែងដែលមានលក្ខណៈខុសគ្នាពីរដ្ឋមួយទៅរដ្ឋមួយ។ រដ្ឋដែលមានទឹកដីធំ និងមានប្រជាជន

ច្រើន ដូចជា Saxey North Rhine- Westphalia, Lithy-Westphalia Bead-Württemberg និងBavaria តែងតែរៀបចំឱ្យមានរដ្ឋាភិបាលមូលដ្ឋានមួយកម្រិតទៀត ហៅថា**រដ្ឋបាលតំបន់ (Bezirek)**។ ដោយឡែកចំពោះរដ្ឋតូចៗ គឺមិនមានលំដាប់រដ្ឋបាលកម្រិតនេះទេ ហើយរដ្ឋាភិបាលថ្នាក់រដ្ឋប្រាស្រ័យទាក់ទងដោយផ្ទាល់ជាមួយអង្គភាពនានារបស់រដ្ឋាភិបាលមូលដ្ឋានតែម្តង។

រដ្ឋ Bavaria មានរដ្ឋបាលតំបន់ចំនួន៧ (សូមមើលរូបទី៣) ហើយតំបន់ទាំងនោះ គឺជាអង្គភាពដែលមានភូមិសាស្ត្រ ឬដែនដី និងមានការកំណត់ព្រំដែនច្បាស់លាស់។ អង្គភាពរដ្ឋាភិបាលមូលដ្ឋានទាំងអស់ដែលស្ថិតក្នុងដែនដីរដ្ឋបាលតំបន់ គឺជាសមាជិករបស់រដ្ឋបាលតំបន់។

**រដ្ឋបាលតំបន់** មានចរិកលក្ខណៈចំនួនពីរគឺ៖ (១). ជារដ្ឋបាលតំបន់ស្ថិតនៅក្នុងកម្រិតវិសហមជ្ឈការនៃរដ្ឋាភិបាលថ្នាក់រដ្ឋ មានតួនាទីអនុវត្តមុខងារវិសហមជ្ឈការ និង (២). ជាតំបន់កម្រិតខ្ពស់បំផុតក្នុងប្រភេទ រដ្ឋាភិបាលមូលដ្ឋាន (រដ្ឋាភិបាលដែលមានស្ថាប័នជាតំណាងជាប់ឆ្នោតដោយផ្ទាល់ មានក្រុមប្រឹក្សាប្រតិបត្តិជាប់ឆ្នោត និងមានរដ្ឋបាលខ្លួនឯង)។ ដូចរដ្ឋបាលស្រុកដែលបានរៀបរាប់ខាងលើដែរ រដ្ឋបាលតំបន់ត្រូវបានចាត់ទុកជាសមាគម ឬបណ្តុំនៃឃុំ។ ចំពោះរដ្ឋបាលតំបន់ Upper Bavaria មានស្រុក និងទីក្រុងស្វយ័ត (ដូចរូបភាពទី៤) និងមានឃុំជាសមាជិក (ដូចរូបភាពទី៥)។

រូបភាពទី៣៖ *រដ្ឋបាលតំបន់បាវ៉ារៀ* (Bavaria)




រូបភាពទី៤៖ ស្រុក និងទីក្រុងស្វយ័តនៅបាវ៉ារៀខាងលើ




រូបភាពទី៥៖ ឃុំនៅនៅបាវ៉ារៀខាងលើ




## ២.២.២. ការរៀបចំស្ថាប័ននៅកម្រិតមូលដ្ឋាន

ការរៀបចំស្ថាប័ននៅថ្នាក់មូលដ្ឋានមានលក្ខណៈផ្សេងៗគ្នា តាមការកំណត់ដោយច្បាប់នៃរដ្ឋនីមួយៗ។ ភាពខុសគ្នានេះអាចកើតមានឡើងជាឧទាហរណ៍ទាក់ទងទៅនឹងវិធីសាស្ត្រនៃការបោះឆ្នោតសម្រាប់មេឃុំ ប្រព័ន្ធបោះឆ្នោតសម្រាប់ក្រុមប្រឹក្សាមូលដ្ឋាន អាណត្តិការងារ និងទំនាក់ទំនងរវាងមុខងារនយោបាយ និងមុខងាររដ្ឋបាលរបស់មេឃុំ។

នៅក្នុងរដ្ឋភាគច្រើន មេឃុំត្រូវបានជ្រើសរើសដោយផ្ទាល់ពីប្រជាពលរដ្ឋរស់នៅក្នុងឃុំ និងមានអាណត្តិការងារខុសគ្នាពី៥ទៅ១០ឆ្នាំ។ ដោយសារអាណត្តិរបស់ក្រុមប្រឹក្សាមានភាពខុសគ្នាពី៥ទៅ៦ឆ្នាំ ធ្វើឱ្យអាណត្តិការងាររបស់មេឃុំ និងក្រុមប្រឹក្សាឃុំ ជាធម្មតាមិនស៊ីសង្វាក់គ្នា ដោយក្នុងករណីភាគច្រើនការបោះឆ្នោតទាំងពីរត្រូវបានធ្វើដោយឡែកៗពីគ្នា និងនៅពេលផ្សេងៗគ្នា។ ជាអត្ថប្រយោជន៍ គឺការទទួលបាននូវតុល្យភាពអំណាចរវាងមេឃុំ និងក្រុមប្រឹក្សាឃុំ។ម្យ៉ាងទៀត គឺទំនាក់ទំនងនយោបាយរបស់មេឃុំ និងក្រុមអ្នកនយោបាយរបស់ក្រុមប្រឹក្សាអាចមានភាពខុសគ្នាដែលជួនកាលនាំឱ្យមានដំណើរការចរចានយោបាយកាន់តែមានភាពស្មុគស្មាញ (ដូចបានបញ្ជាក់ដោយអភិបាលក្រុង Kempten លោក Thomas Kiechle ក្នុងអំឡុងពេលទស្សនកិច្ចនៅថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២៤)។ រដ្ឋភាគច្រើនក៏បានផ្តល់ជម្រើសក្នុងការអនុញ្ញាតឱ្យមេឃុំចាស់ៗឱ្យឈរឈ្មោះបោះឆ្នោតឡើងវិញ (ករណីលើកលែងរដ្ឋ Bavaria និងរដ្ឋ Baden-Württemberg)។

រដ្ឋភាគច្រើនប្រើប្រាស់ប្រព័ន្ធតំណាងសមាមាត្រសម្រាប់ការបោះឆ្នោតក្រុមប្រឹក្សា។ បញ្ជីបេក្ខជនត្រូវបានស្នើឡើងដោយគណបក្សនយោបាយ ប៉ុន្តែក៏អាចស្នើឡើងដោយក្រុមប្រជាពលរដ្ឋ ឬសម្ព័ន្ធភាពបោះឆ្នោតដែលមិនស្ថិតនៅក្រោមគណបក្សនយោបាយផងដែរ។ នៅរដ្ឋមួយចំនួន ប្រជាពលរដ្ឋអាចបោះឆ្នោតទាំងទៅលើបញ្ជីឈ្មោះ និងលើបេក្ខជនជាបុគ្គលនៅក្នុងបញ្ជីឈ្មោះនោះ។ នៅកន្លែងមួយចំនួន ប្រព័ន្ធបោះឆ្នោតបានអនុញ្ញាតឱ្យប្រជាពលរដ្ឋបោះឆ្នោតបានច្រើនជាងមួយសំឡេង ហើយប្រជាពលរដ្ឋអាចចែករំលែកសំឡេងឆ្នោតនេះទៅបេក្ខជនផ្សេងៗទៀត ឬផ្តល់សំឡេងឆ្នោតទាំងអស់ទៅបេក្ខជនតែម្នាក់។ នៅក្នុងការអនុវត្តនេះ អ្នកបោះឆ្នោតអាចកំណត់លំដាប់ថ្នាក់បេក្ខជននៅក្នុងបញ្ជីឈ្មោះបោះឆ្នោត ហើយនៅចុងក្រោយឈានទៅរក

បេក្ខជននៅក្នុងបញ្ជីឈ្មោះដែលអាចក្លាយជាក្រុមប្រឹក្សា។ បច្ចុប្បន្នច្បាប់នៅតាមរដ្ឋកាន់តែច្រើនឡើងតម្រូវឱ្យគណបក្សនយោបាយ និងសម្ព័ន្ធភាពបោះឆ្នោតគិតគូរអំពីតុល្យភាពយេនឌ័រ (បេក្ខជនបុរស និងបេក្ខជនស្ត្រី)។

រូបភាពទី៦៖ មុខងារផ្សេងៗរបស់មេឃុំ




រដ្ឋចំនួនពាក់កណ្តាល (៨/១៦) ប្រជាពលរដ្ឋក្មេងៗមានសិទ្ធិចូលរួមបោះឆ្នោត ក្នុងពេលពួកគេមានអាយុ១៦ឆ្នាំ (បើប្រៀបធៀបនឹងរដ្ឋផ្សេងៗទៀត និងការបោះឆ្នោតជាតិត្រូវមានអាយុ ១៨ ឆ្នាំ)។ ការបោះឆ្នោតជ្រើសរើសមេឃុំដោយផ្ទាល់បានផ្តល់ឱ្យមេឃុំមានជំហររឹងមាំនៅក្នុងប្រព័ន្ធនយោបាយមូលដ្ឋាន។ វាកាន់តែល្អប្រសើរឡើងនៅពេលដែលមេឃុំក្លាយជាប្រធានក្រុមប្រឹក្សា និងជាប្រធានរដ្ឋបាលមូលដ្ឋាន។ ការច្របាច់បញ្ចូលគ្នានូវតួនាទីមេឃុំ និងប្រធានក្រុមប្រឹក្សាឃុំ គឺជាការអនុវត្តមានលក្ខណៈទូទៅនៅប្រទេសអាល្លឺម៉ង់ ទោះបីមិនមានលក្ខណៈជាសកលក៏ដោយ។ នៅរដ្ឋភាគខាងជើង មុខតំណែងទាំងពីរស្ថិតនៅដាច់ដោយឡែកពីគ្នា។ មេឃុំត្រូវបានបោះឆ្នោតដោយផ្ទាល់ ហើយប្រធានក្រុមប្រឹក្សាត្រូវបានបោះឆ្នោតដោយសមាជិកក្រុមប្រឹក្សារបស់ខ្លួន។ នៅរដ្ឋ Bavaria តំណែងទាំងពីរត្រូវបានបញ្ចូលគ្នា។ ការធ្វើឱ្យមេឃុំក្លាយជាប្រធានរដ្ឋបាលឃុំ គឺជាស្ថានភាពធម្មតានៅក្នុងរដ្ឋស្ទើរតែទាំងអស់នៅក្នុងប្រទេសអាល្លឺម៉ង់ លើកលែងនៅ Hesse និងទីក្រុង Bremerhaven (ជាផ្នែកមួយនៃទីក្រុង Bremen) ដែលនៅទីនោះ អភិបាលទីក្រុង និងសមាជិកក្រុមប្រឹក្សាត្រូវបានបោះឆ្នោតដោយផ្ទាល់ ហើយអភិបាលទីក្រុងក្លាយជាផ្នែកមួយនៃស្ថាប័ននីតិប្រតិបត្តិ

ដែលសមាជិកផ្សេងទៀតត្រូវបានបោះឆ្នោតដោយក្រុមប្រឹក្សា។

ជាគោលការណ៍ រដ្ឋាភិបាលមូលដ្ឋាននៅប្រទេសអាល្លឺម៉ង់មានទំហំស្វ័យភាពផ្សេងៗគ្នាជាច្រើន ដែលអាចសង្ខេបដូចខាងក្រោម៖

- **ស្វ័យភាពលើការរៀបចំស្ថាប័ន៖** ដូចជាការរៀបចំរចនាសម្ព័ន្ធផ្ទៃក្នុងរបស់រដ្ឋបាលមូលដ្ឋាន
- **ស្វ័យភាពលើការងារគ្រប់គ្រងបុគ្គលិក៖** ការជ្រើសរើស ការតែងតាំង និងការបណ្តេញមន្ត្រី និងបុគ្គលិក (ជួល និងបណ្តេញ)
- **ស្វ័យភាពលើការរៀបចំផែនការ៖** ផែនការប្រើប្រាស់ដីធ្លី និងផែនការគ្រប់គ្រងទ្រព្យសម្បត្តិ ឬដីធ្លីក្នុងឃុំ
- **ស្វ័យភាពលើការដាក់ចេញបទប្បញ្ញត្តិ៖** សម្រាប់ការគ្រប់គ្រងកិច្ចការផ្ទាល់ខ្លួន តាមរយៈការដាក់ចេញបទប្បញ្ញត្តិ
- **ស្វ័យភាពហិរញ្ញវត្ថុ៖** ការគ្រប់គ្រងចំណូល និងចំណាយផ្ទាល់ ការគ្រប់គ្រងទ្រព្យសម្បត្តិនានា
- **ស្វ័យភាពដែនដី៖** ការអនុវត្តអំណាចនៅក្នុងដែនដីរបស់រដ្ឋបាលរៀងៗខ្លួន
- **ដែនសមត្ថកិច្ចក្នុងកិច្ចការប្រមូលពន្ធ៖** ការប្រមូលពន្ធដោយខ្លួនឯង (ឧ. ពន្ធលើការធ្វើពាណិជ្ជកម្ម និងទ្រព្យសម្បត្តិ) ការកំណត់អត្រាពន្ធ។

ឃុំមានស្វ័យភាពក្នុងការកំណត់រចនាសម្ព័ន្ធ និងធនធានមនុស្សរបស់ខ្លួនឱ្យតែរចនាសម្ព័ន្ធ និងធនធានមនុស្សទាំងនោះស្របទៅនឹងសមត្ថភាពហិរញ្ញវត្ថុរបស់ឃុំ។ នៅក្នុងដំណើរការនៃការត្រួតពិនិត្យថវិកា អាជ្ញាធររដ្ឋអាចជំទាស់ប្រសិនបើពួកគេមើលឃើញអំពីហានិភ័យនៃការចំណាយច្រើនហួសហេតុទៅលើរចនាសម្ព័ន្ធ។ នៅថ្នាក់ស្រុក និងទីក្រុងដែលមិនស្ថិតក្រោម

ថ្នាក់ស្រុក (ប៉ុន្តែក្នុងករណីនៅរដ្ឋ Bavaria ក៏ដូចជានៅថ្នាក់តំបន់ មានរដ្ឋបាលពីរប្រភេទ៖ គឺរដ្ឋបាលមូលដ្ឋាន (មានតួនាទីដោះស្រាយកិច្ចការនានានៅមូលដ្ឋាន ឬកិច្ចការជាអាណត្តិទូទៅ និងកិច្ចការដែលបានប្រគល់/ធ្វើប្រតិភូកម្ម) និងរដ្ឋបាលវិសហមជ្ឈការថ្នាក់រដ្ឋ។

មិនដូចគ្នានឹងថ្នាក់ក្រុង ស្រុកនៅកម្ពុជា ពោលគឺរដ្ឋបាលមូលដ្ឋាននៅប្រទេសអាល្លឺម៉ង់មិនមានរដ្ឋបាលឯកភាពដែលកិច្ចការដែលបានធ្វើវិសហមជ្ឈការមិនស្ថិតនៅក្រោមការត្រួតពិនិត្យរបស់ក្រុមប្រឹក្សាជាប់ឆ្នោតឡើយ។ ក្នុងស្ថានភាពជាក់ស្តែង ប្រជាពលរដ្ឋមានការលំបាកនឹងមើលឃើញអំពីភាពខុសគ្នារវាងរដ្ឋបាលវិសហមជ្ឈការ និងរដ្ឋបាលមូលដ្ឋានណាស់។ រដ្ឋបាលទាំងពីរប្រភេទនេះ ត្រូវបានត្រួតពិនិត្យ និងដឹកនាំដោយប្រធានប្រតិបត្តិ (Mayor)។ នៅថ្នាក់ឃុំ មានរដ្ឋបាលមូលដ្ឋានតែមួយប៉ុណ្ណោះ។

យន្តការសំខាន់នៃការអនុវត្តមុខងាររបស់ក្រុមប្រឹក្សា គឺគណៈកម្មាធិការនានារបស់ក្រុមប្រឹក្សា ដែលអាចមានសមត្ថកិច្ចទៅលើកិច្ចការទូទៅជាច្រើន ដូចជា ការងារផែនការ និងថវិកា ឬកិច្ចការតាមវិស័យនានា ដូចជា វិស័យអប់រំ សុខភាពសាធារណៈ និងការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋានជាដើម។ ចំនួនគណៈកម្មាធិការ ការទទួលខុសត្រូវ និងយន្តការការងាររបស់គណៈកម្មាធិការរបស់ក្រុមប្រឹក្សាត្រូវបានកំណត់ដោយក្រុមប្រឹក្សាខ្លួនឯង ដោយមិនចាំបាច់មានការអនុម័តដោយថ្នាក់លើឡើយ។ រដ្ឋមួយចំនួនបានអនុញ្ញាតឱ្យគណបក្សនយោបាយតែងតាំងអ្នកដែលមានចំណេះដឹងជ្រៅជ្រះចូលរួមនៅក្នុងកិច្ចដំណើរការនៃគណៈកម្មាធិការទាំងនេះ ក្នុងនាមជាសមាជិកដែលពុំមានសិទ្ធិបោះឆ្នោត ទោះបីពួកគេមិនបានជាប់ឆ្នោតជាសមាជិកក្រុមប្រឹក្សាក៏ដោយ។

### ២.២.៣. កិច្ចការ និងមុខងារនានារបស់រដ្ឋាភិបាលមូលដ្ឋាន

ការរៀបចំច្បាប់ស្តីពីរដ្ឋាភិបាលមូលដ្ឋាន និងការកំណត់ប្រភេទមុខងារនៅមូលដ្ឋានស្ថិតនៅក្រោមសមត្ថកិច្ចថ្នាក់រដ្ឋ។ មាត្រា២៨ នៃរដ្ឋធម្មនុញ្ញអាល្លឺម៉ង់បានផ្តល់ការការពារដល់ការបង្កើតរដ្ឋាភិបាលមូលដ្ឋាន។ ច្បាប់បានចែងអំពីសិទ្ធិនៃការបង្កើតរដ្ឋបាលមូលដ្ឋាន ដើម្បីគ្រប់គ្រងកិច្ចការនៅមូលដ្ឋានដោយខ្លួនឯង ហើយផ្តល់ឱ្យឃុំនូវការទទួលខុសត្រូវជាទូទៅលើបញ្ហាទាំងអស់ពាក់ព័ន្ធនឹងសហគមន៍មូលដ្ឋាន (មុខងារជាអាណត្តិទូទៅ)។ ទោះបីជាយ៉ាងណាក៏ដោយ ការធានាតាមរដ្ឋធម្មនុញ្ញនេះអនុវត្តបានចំពោះតែឃុំប៉ុណ្ណោះ ប៉ុន្តែមិនអាចអនុវត្តបានចំពោះស្រុក និងទីក្រុងដែលមិនស្ថិតនៅក្រោមស្រុកឡើយ (មុខងារជាក់លាក់ត្រូវបានកំណត់ដោយច្បាប់នៅថ្នាក់រដ្ឋ)។ ច្បាប់នេះក៏មិនអាចអនុវត្តចំពោះរដ្ឋបាលតំបន់ឡើយ ដែលអាណត្តិរបស់រដ្ឋបាលតំបន់ត្រូវបានចែងដូចគ្នាក្នុងច្បាប់នៅថ្នាក់រដ្ឋ។ ក្នុងការពិពណ៌នាអំពីកិច្ចការ និងមុខងាររបស់រដ្ឋាភិបាលមូលដ្ឋានរបស់ប្រទេសអាល្លឺម៉ង់ ពិតជាមានផលប្រយោជន៍សម្រាប់ប្រទេសកម្ពុជាដោយសារការប្រើប្រាស់នូវវាក្យស័ព្ទមួយចំនួនមានលក្ខណៈដូចគ្នាទៅនឹងបរិបទកម្ពុជាដូចជា **"មុខងារដែលបានផ្ទេរ"** **"មុខងារដែលបានប្រគល់"** **"មុខងារដែលបានធ្វើប្រតិភូកម្ម"** និង **"មុខងារជាជម្រើស"** រួមទាំងពាក្យដូចជា **"មុខងារជាអាណត្តិទូទៅ"** "មុខងារជាកាតព្វកិច្ច" និង **"មុខងារជាជម្រើស"** (សូមមើលរូបភាពទី៧)។

ឧបករណ៍ដែលមានប្រយោជន៍សម្រាប់ការវិភាគគឺថា **"តើអ្នកណាជាអ្នកសម្រេចលើកិច្ចការដែលឃុំត្រូវធ្វើ?"** និង **"អ្នកណាជាអ្នកសម្រេចថា តើឃុំត្រូវធ្វើដូចម្តេច?"**។ នៅក្នុងប្រព័ន្ធអាល្លឺម៉ង់ ភាពខុសគ្នាគឺរវាង**ការទទួលខុសត្រូវលើកិច្ចការមូលដ្ឋានផ្ទាល់** និង**ការទទួលខុសត្រូវលើកិច្ចការដែលបាន**

**ផ្ទេរ/ប្រគល់**។ នៅក្នុងប្រភេទទាំងពីរនេះ មានជម្រើសចំនួនពីរគឺ៖ មុខងារជាជម្រើស និងមុខងារជាកាតព្វកិច្ច។

**រូបភាពទី៧៖ ប្រភេទកិច្ចការរបស់ឃុំ**




**នៅក្នុងការទទួលខុសត្រូវលើកិច្ចការមូលដ្ឋានផ្ទាល់** មានកិច្ចការមួយចំនួនដែលជាកិច្ចការស្ម័គ្រចិត្តទាំងស្រុង ដូចជា ឃុំជាអ្នកកំណត់ថាតើខ្លួនចង់ធ្វើកិច្ចការអ្វីខ្លះ និងចង់ធ្វើកិច្ចការទាំងនោះយ៉ាងដូចម្ដេច? លក្ខណៈនេះ ត្រូវបានចាត់ទុកថាជាមុខងារអាណត្តិទូទៅ និងមុខងារជាជម្រើស។ មានន័យថា ប្រសិនបើមិនមានរដ្ឋាភិបាលកម្រិតណាមួយធ្វើកិច្ចការនេះទេ នោះឃុំមានសិទ្ធិពេញលេញក្នុងការអនុវត្តមុខងារទាំងនោះ។ ប៉ុន្តែក៏មានកិច្ចការដែលត្រូវបានប្រគល់ជាកាតព្វកិច្ចផងដែរ ដែលឃុំមិនមានជម្រើសក្នុងការគិតថា តើត្រូវធ្វើកិច្ចការនោះឬអត់ឡើយ ប៉ុន្តែត្រូវតែសម្រេចថា តើត្រូវអនុវត្តកិច្ចការនោះយ៉ាងដូចម្ដេច?។

**នៅក្នុងការទទួលខុសត្រូវលើកិច្ចការ ដែលបានផ្ទេរ/ប្រគល់** មានកិច្ចការជាកាតព្វកិច្ចមួយចំនួនដែលថ្នាក់រដ្ឋ គឺជាអ្នកកំណត់ចំនួនកិច្ចការ(កិច្ចការអ្វីខ្លះ?) និងនីតិវិធីនៃការអនុវត្តកិច្ចការទាំងនោះ (មិនបានផ្ដល់ស្វ័យភាពដល់ឃុំឡើយ)។ ហើយចំពោះកិច្ចការដែលបានធ្វើប្រតិភូកម្ម ឃុំបានអនុវត្តកិច្ចការ

ទាំងនោះក្នុងនាមស្ថាប័ននានានៃរដ្ឋាភិបាលរដ្ឋ (មិនបានផ្តល់ស្វ័យភាពដល់ឃុំឡើយ)។

ការកំណត់ប្រភេទមុខងារទាំងនេះមានសារៈសំខាន់សម្រាប់ការរៀបចំថវិកា និងការតាមដាន ត្រួតពិនិត្យដោយអាជ្ញាធរថ្នាក់លើ។ មុខងារជាជម្រើសជារឿយៗប្រឈមទៅនឹងការខ្វះថវិកា ខណៈដែលមុខងារជាកាតព្វកិច្ចត្រូវបានផ្តល់អាទិភាពក្នុងការប្រើប្រាស់ថវិកាមូលដ្ឋាន។

រូបភាពទី៧បង្ហាញអំពីប្រភេទមុខងាររបស់ឃុំ ដូចបានបង្ហាញក្នុងអំឡុងពេលទស្សនកិច្ចទៅកាន់ក្រសួងមហាផ្ទៃ នៃរដ្ឋបារាំងនៅថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២៤ កន្លងទៅនេះ។

ការប្រគល់កិច្ចការ និងមុខងារនានា មានភាពខុសគ្នាសម្រាប់រដ្ឋាភិបាលមូលដ្ឋានកម្រិតខ្ពស់ (ដែលក្នុងករណីស្រុក និងរដ្ឋបាលតំបន់ ត្រូវបានគេមើលឃើញថាជាសមាគមនៃឃុំ)៖

- **ស្រុក និងទីក្រុងស្វយ័ត** អនុវត្តកិច្ចការដែលបានប្រតិភូកម្មពីរដ្ឋាភិបាលថ្នាក់រដ្ឋ (កិច្ចការផ្ទេរ) និងកិច្ចការមូលដ្ឋាន (កិច្ចការផ្ទាល់ខ្លួន)។ ជាពិសេស នៅថ្នាក់ស្រុក កិច្ចការទាំងនេះជាកិច្ចការមូលដ្ឋានដែលត្រូវអនុវត្ត ដោយសារកត្តាសេដ្ឋកិច្ច មាត្រដ្ឋាន និងផលប៉ះពាល់នានា ក៏ដូចជាដោយសារតម្រូវការជំនាញបច្ចេកទេស និងជំនាញគ្រប់គ្រងដែលហួសពីសមត្ថភាពរបស់ឃុំនីមួយៗផងដែរ។ ឧទាហរណ៍៖ កិច្ចការពាក់ព័ន្ធអនុវិទ្យាល័យ មន្ទីរពេទ្យទូទៅ សេវាសង្គម សុខុមាលភាពយុវជន និងផ្លូវថ្នល់ថ្នាក់ស្រុកជាដើម។
- **រដ្ឋបាលតំបន់នៅបារាំង** គឺជារដ្ឋបាលកម្រិតខ្ពស់បំផុតនៅក្នុង

ប្រព័ន្ធរដ្ឋាភិបាលមូលដ្ឋាន ដែលអនុវត្តកិច្ចការ និងមុខងារវិស័យមួយចំនួននៅក្នុងឃុំជាច្រើន។ កិច្ចការទាំងនោះ រួមមាន៖ (១). ការផ្តល់សេវា និងការគ្រប់គ្រងមន្ទីរពេទ្យឯកទេសផ្នែកវិកលចរិត (២). ការធ្វើសមាហរណកម្មមនុស្សដែលមានពិការភាពផ្លូវចិត្តបញ្ញា ឬរាងកាយ (៣). ការលើកកម្ពស់ការអភិរក្សធម្មជាតិ និងកិច្ចការពារបរិស្ថាន និង (៤). ហេដ្ឋារចនាសម្ព័ន្ធគ្រឹះស្ថានបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ។ តំបន់រដ្ឋបាលបាវ៉ារៀខាងលើជាឧទាហរណ៍បានរាយបញ្ជីកិច្ចការនានា ដូចជា កិច្ចការអប់រំ កិច្ចការសង្គម និងហេដ្ឋារចនាសម្ព័ន្ធវប្បធម៌ ដែលផ្តល់មូលនិធិ និងគ្រប់គ្រងដោយរដ្ឋបាលតំបន់។

តួនាទីទាំងពីររបស់រដ្ឋាភិបាលមូលដ្ឋាន (តំណាងរដ្ឋាភិបាលក្នុងមូលដ្ឋានរបស់ខ្លួន និងអនុវត្តមុខងារនានារបស់រដ្ឋ) មានជាក់ស្តែងសម្រាប់ថ្នាក់ស្រុក និងទីក្រុងស្វយ័ត ដែលអង្គភាពរដ្ឋបាលនានាអនុវត្តកិច្ចការដែលបានផ្ទេរពីថ្នាក់រដ្ឋ មិនស្ថិតនៅក្រោមសិទ្ធិអំណាចរបស់ក្រុមប្រឹក្សាជាប់ឆ្នោតទេ។ ករណីនៅរដ្ឋបាលតំបន់បាវ៉ារៀ គឺមិនមានតួនាទីពីរនេះទេ ដោយសារថានៅទីនោះរដ្ឋាភិបាលនៃរដ្ឋបាលតំបន់ (ដែលជាផ្នែកមួយនៃវិសហមជ្ឈការនៃរដ្ឋបាលថ្នាក់រដ្ឋ) បានស្ថិតនៅដោយឡែកពីការគ្រប់គ្រងផ្នែកនយោបាយ និងការអនុវត្តកិច្ចការរដ្ឋបាលរបស់តំបន់បាវ៉ារៀដែលជារដ្ឋាភិបាលមូលដ្ឋានកម្រិតខ្ពស់។

### ២.២.៤. ហិរញ្ញវត្ថុរដ្ឋាភិបាលមូលដ្ឋាន

នៅក្នុងមាត្រា ២៨.២ នៃរដ្ឋធម្មនុញ្ញសហព័ន្ធ បានចែងថាស្វ័យភាពរបស់ឃុំតម្រូវឱ្យឃុំមានថវិកាគ្រប់គ្រាន់ ដើម្បីឱ្យឃុំមានសិទ្ធិស្របច្បាប់ក្នុងការ

ទទួលបានចំណូលពន្ធ "ដោយផ្អែកលើសមត្ថភាពសេដ្ឋកិច្ច និងសិទ្ធិក្នុងការកំណត់អត្រាពន្ធពីប្រភពនានា"។ ដូចនេះ ជាគោលការណ៍ រដ្ឋនីមួយៗត្រូវធានាថា ស្រុក ទីក្រុង និងឃុំបានទទួលបានថវិកាគ្រប់គ្រាន់។ ក្នុងពេលជាមួយគ្នានេះ ច្បាប់សារពើពន្ធអាល្លឺម៉ង់បានហាមឃាត់រាល់ទំនាក់ទំនងហិរញ្ញវត្ថុដោយផ្ទាល់ ឬដោយប្រយោលរវាងរដ្ឋាភិបាលសហព័ន្ធ និងឃុំ។ អាចនិយាយម្យ៉ាងទៀតថា ប្រសិនបើរដ្ឋាភិបាលសហព័ន្ធចង់ផ្តល់ការលើកទឹកចិត្តណាមួយផ្នែកសារពើពន្ធដល់ឃុំសម្រាប់គោលបំណងគោលនយោបាយជាក់លាក់ណាមួយនោះ (ដូចជាការកែលម្អការផ្តល់សេវាវិស័យអប់រំមធ្យមសិក្សា) រដ្ឋាភិបាលសហព័ន្ធត្រូវវិភាជន៍ថវិកានោះតាមរយៈរដ្ឋាភិបាលថ្នាក់រដ្ឋ។

មានលក្ខណៈខុសគ្នាពីឃុំមួយទៅឃុំមួយ (ជាកម្រិតមូលដ្ឋានទាបបំផុតនៃអង្គភាពរដ្ឋាភិបាលមូលដ្ឋាន) និងពីស្រុកមួយទៅស្រុកមួយ និងរដ្ឋបាលតំបន់មួយទៅរដ្ឋបាលតំបន់មួយដែលត្រូវបានមើលឃើញថាជាសមាគម/បណ្តុំនៃឃុំ ឃុំដែលជាសមាជិករួមគ្នាផ្តល់ហិរញ្ញប្បទានលើការចំណាយរបស់រដ្ឋបាលស្រុក និងរដ្ឋបាលតំបន់ តាមរយៈការចូលរួមបដិភាគដោយផ្អែកលើចំនួនប្រជាពលរដ្ឋ។ លើសពីនេះ ស្រុក និងទីក្រុងស្វយ័តបានទទួលមូលនិធិពីរដ្ឋាភិបាលថ្នាក់រដ្ឋសម្រាប់អនុវត្តមុខងារដែលបានប្រគល់ និងមុខងារដែលបានធ្វើប្រតិភូកម្មពីថ្នាក់រដ្ឋ។ នៅក្នុងរដ្ឋបាវ៉ារៀ ចំណូលនានារបស់ឃុំត្រូវបានបែងចែងជាប្រាំប្រភេទធំៗ រួមមាន៖

- **ចំណូលផ្ទាល់**៖ ពន្ធពាណិជ្ជកម្ម និងពន្ធលើអចលនទ្រព្យ១៥% ពន្ធចែករំលែកលើប្រាក់ចំណូល២% ចែករំលែកលើពន្ធតម្លៃបន្ថែម និងពន្ធតូចៗនៅមូលដ្ឋាន
- **វិភាគទាន (ឧបត្ថម្ភធន)**
- **ថ្លៃសេវារដ្ឋបាល និងកម្រៃទទួលបានពីអ្នកប្រើប្រាស់**

- **ប្រភពប្រាក់ចំណូលផ្សេងទៀត** (សកម្មភាពសេដ្ឋកិច្ច ឬការខ្ចីប្រាក់)
- **ការចូលរួមចំណែកបដិភាគសារពើពន្ធពីថ្នាក់រដ្ឋ** ក្នុងទម្រង់ជាគម្រោងសមភាពហិរញ្ញវត្ថុឃុំ ដែលត្រូវបានគណនាផ្អែកលើចំនួនប្រជាពលរដ្ឋ និងស្ថានភាពសេដ្ឋកិច្ចសង្គមរបស់ឃុំ។ នៅក្នុងឆ្នាំ២០២៤ ថវិកាប្រមាណ **១១ពាន់លានអឺរ៉ូ** ត្រូវបានផ្តល់ដោយគម្រោងសមភាពហិរញ្ញវត្ថុធៀបជាមួយនឹងប្រមាណ**២៤ពាន់លានអឺរ៉ូ** ដែលជាចំណូលទទួលបានពីប្រភពផ្សេងទៀត។

ជារួម ប្រមាណ៤0%នៃប្រាក់ចំណូលរបស់ឃុំក្នុងប្រទេសអាល្លឺម៉ង់ទទួលបានមកពីការវិភាជន៍ដោយថ្នាក់រដ្ឋ រីឯចំណូលទទួលបានពីការប្រមូលពន្ធមានចំនួនប្រហែល៤0%។ កម្រៃសេវានានា និងវិភាគទាន (ដែលត្រូវបានគេសន្មត់ថាជាប្រភពសំខាន់នៃមូលនិធិឃុំ) គឺមានប្រហែល៨%នៃប្រាក់ចំណូលសរុប។ ដោយឡែកប្រហែល១២%ទៀត គឺទទួលបានមកពីប្រភពចំណូលផ្សេងៗទៀត រួមមាន៖ អំណោយ ប្រាក់ចំណូលពីការជួញដូរ (sales proceeds៖ រដ្ឋបាលឃុំអាចទិញ-លក់អចលនវត្ថុបាន) ការផាកពិន័យ និងពីមរតកផ្សេងៗ។

### ២.២.៩. សេវាការពារប្រជាពលរដ្ឋនិងគ្រប់គ្រងគ្រោះមហន្តរាយ និងសេវាសង្គ្រោះបន្ទាន់

សហព័ន្ធអាល្លឺម៉ង់បានប្រគល់មុខងារ និងការទទួលខុសត្រូវលើសេវាការពារប្រជាពលរដ្ឋ និងគ្រប់គ្រងគ្រោះមហន្តរាយទៅឱ្យកម្រិតរដ្ឋបាលនានា។ កម្រិតសហព័ន្ធទទួលខុសត្រូវលើសេវា ការពារប្រជាពលរដ្ឋ (ឧ. កិច្ចការពារប្រជាពលរដ្ឋក្នុងករណីមានវិវាទយោធា)។ ចំពោះសេវាគ្រប់គ្រងគ្រោះមហន្តរាយដូចជា គ្រោះទឹកជំនន់ ភ្លើងឆេះព្រៃ និងគ្រោះថ្នាក់ទ្រង់ទ្រាយធំ

មុខងារទាំងអស់នេះទទួលខុសត្រូវដោយថ្នាក់រដ្ឋ។ ទោះបីជាយ៉ាងណាក៏ដោយ ជាធម្មតាថ្នាក់មូលដ្ឋាន គឺជាថ្នាក់ដំបូងក្នុងការឆ្លើយតប ដូចនេះថ្នាក់មូលដ្ឋាន ទទួលខុសត្រូវលើការគ្រប់គ្រងគ្រោះមហន្តរាយនៅមូលដ្ឋាន។ ផ្អែកលើទំហំនៃគ្រោះមហន្តរាយ រដ្ឋនីមួយៗអាចស្វែងរកការគាំទ្រពីថ្នាក់សហព័ន្ធ (រួមមានការគាំទ្រផ្នែកបច្ចេកទេស ការផ្តល់ឱ្យនូវអង្គភាពយោធានិងប៉ូលីសសហព័ន្ធ រួមទាំងការគាំទ្រផ្នែកហិរញ្ញវត្ថុផងដែរ)។ តួអង្គសំខាន់ដើរតួក្នុងការផ្តល់សេវាគ្រប់គ្រងគ្រោះមហន្តរាយ និងសេវាគ្រោះអាសន្ន គឺអង្គការឯកជនដែលមិនរកប្រាក់ចំណេញ។ អង្គការទាំងនោះមានដូចជា កាកបាទក្រហមអាល្លឺម៉ង់ ដែលធ្វើការយ៉ាងជិតស្និតជាមួយរដ្ឋ និងអាជ្ញាធរមូលដ្ឋាននានា។ ដោយរួមបញ្ចូលគ្នា ពួកគេបានផ្តល់អ្នកស្ម័គ្រចិត្តចំនួន **៦00.000នាក់** និងបុគ្គលិកពេទ្យនៅក្នុងក្រុងតូចៗជាច្រើន។ អ្នកពន្លត់អគ្គីភ័យស្ម័គ្រចិត្ត និងសាខាក្នុងតំបន់នៃអង្គការឯកជនទាំងនោះ គឺជាឆ្អឹងខ្នងនៃការឆ្លើយតបបន្ទាន់នៅក្នុងមូលដ្ឋាន។ ឃុំ និងស្រុកជាច្រើន (ប៉ុន្តែមិនគ្រប់ឃុំ និងស្រុកទេ) បានរៀបចំផែនការគ្រប់គ្រងគ្រោះមហន្តរាយ។ ការកើនឡើងនៃឧប្បត្តិហេតុដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុ ដូចជា ព្យុះ ភ្លៀងធ្លាក់ខ្លាំង ទឹកជំនន់ និងភ្លើងឆេះព្រៃទ្រង់ទ្រាយធំក្នុងអំឡុងពេលរដូវក្តៅស្ងួត បានបង្កើនការយល់ដឹងអំពីគ្រោះមហន្តរាយធម្មជាតិ និងជំរុញឱ្យមានកិច្ចខិតខំប្រឹងប្រែងគ្រប់លំដាប់ថ្នាក់ក្នុងការវិនិយោគលើសម្ភារបរិក្ខារ និងដំណើរការគ្រប់គ្រងគ្រោះមហន្តរាយ។ ក្នុងឆ្នាំ២០២៣ ស្ថាប័នផ្តល់សេវាទូរស័ព្ទចល័តវិស័យឯកជនត្រូវបានតម្រូវដោយច្បាប់ក្នុងការដាក់ឱ្យអនុវត្តនូវលក្ខខណ្ឌបច្ចេកទេស ដែលអនុញ្ញាតឱ្យអាជ្ញាធររដ្ឋអាចបញ្ជូនពត៌មាន ឬដំណឹងបន្ទាន់ដោយផ្ទាល់ទៅកាន់ទូរស័ព្ទចល័តទាំងអស់នៅក្នុងតំបន់ដែលមានគ្រោះមហន្តរាយកើតឡើង ឬទំនងនឹងអាចកើតឡើង។

ឋានានុក្រមនៃការគ្រប់គ្រងគ្រោះមហន្តរាយ និងគ្រោះអាសន្ន គឺអាស្រ័យលើទំហំ និងភាពស្មុគស្មាញផ្នែកបច្ចេកទេសនៃហេតុការណ៍នីមួយៗ។ ជាធម្មតា ឃុំគឺជាអ្នកឆ្លើយតបដំបូងគេចំពោះហេតុការណ៍នានាដែលកើតឡើងនៅក្នុងមូលដ្ឋាន ដោយប្រើអ្នកពន្លត់អគ្គីភ័យស្ម័គ្រចិត្ត ឬអង្គភាពឆ្លើយតបផ្នែកវេជ្ជសាស្ត្រ។ ស្រុក និងទីក្រុងស្វយ័ត គឺជាអង្គភាពគ្រប់គ្រងគ្រោះមហន្តរាយដ៏សំខាន់សម្រាប់ហេតុការណ៍ក្នុងទ្រង់ទ្រាយធំ។ ជានិច្ចជាកាលឃុំមានផែនការគ្រប់គ្រងគ្រោះមហន្តរាយដោយខ្លួនឯង មានហេដ្ឋារចនាសម្ព័ន្ធពិសេសនានា (ដូចជាបន្ទប់ត្រួតពិនិត្យកណ្តាល) និងធ្វើលំហាត់គ្រប់គ្រងគ្រោះមហន្តរាយជាទៀងទាត់ ដើម្បីពិនិត្យថា តើលំហូរនៃព័ត៌មាន និងការសម្របសម្រួលជាមួយអង្គភាព និងអង្គការពាក់ព័ន្ធបានដំណើរការតាមផែនការដែលបានគ្រោងទុកដែរឬទេ។ ប្រធានប្រតិបត្តិនៃស្រុក ឬនៃទីក្រុងស្វយ័ត គឺជាអ្នកបញ្ជា និងជាអ្នកទំនាក់ទំនងទៅថ្នាក់រដ្ឋ។ នៅតំបន់បាវ៉ារៀ រដ្ឋបាលស្រុកមានតួនាទីយ៉ាងសំខាន់លើកិច្ចការនេះ។ ដូចបានបកស្រាយក្នុងអំឡុងពេលនៃដំណើរទស្សនកិច្ចទៅកាន់រដ្ឋបាលតំបន់ Upper Bavaria នៅថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២៤ ដំណើរការផ្លូវការ និងការទំនាក់ទំនងជាច្រើនត្រូវបានប្រើប្រាស់នៅពេលការទទួលខុសត្រូវលើការគ្រប់គ្រងគ្រោះមហន្តរាយត្រូវបានប្តូរពីកម្រិតមួយទៅកម្រិតបន្ទាប់មួយទៀត។

បច្ចុប្បន្ន ការគ្រប់គ្រងគ្រោះមហន្តរាយ និងគ្រោះអាសន្នតែងមានកិច្ចសហប្រតិបត្តិការអន្តរឃុំ ដូចជាតាមរយៈការហៅទូរស័ព្ទបន្ទាន់ (ដោយប្រើលេខ១១០ និង១១២) ត្រូវបានទទួលនៅ**បន្ទប់ត្រួតពិនិត្យរួម**ដែលគ្របដណ្តប់ដែនដីនៃអង្គភាពរដ្ឋបាលមូលដ្ឋានច្រើន មានការដាក់ពង្រាយអង្គភាពវេជ្ជសាស្ត្រ ឬអង្គភាពពន្លត់អគ្គីភ័យ និងមានការសម្របសម្រួលដឹកជញ្ជូនអ្នករងរបួសទៅកាន់មន្ទីរពេទ្យដែលនៅជិតបំផុត។ បន្ទប់ត្រួតពិនិត្យរួមនេះ ប្រមូល

ព័ត៌មានសំខាន់ៗដែលអាចមានភាពងាយស្រួលសម្រាប់អ្នកធ្វើសេចក្ដីសម្រេចចិត្ត។ ក្នុងករណីតំបន់អាល់ហ្គោ (ដែលស្ថិតនៅទីក្រុង Kempten) វិសាលភាពនៃការបញ្ជូនពត៌មានរបស់បន្ទប់បញ្ជាការត្រួតពិនិត្យរួម គឺគ្របណ្ដប់ប្រជាជនប្រហែល **៥០០.០០០នាក់** រួមបញ្ចូលទាំងកិច្ចប្រតិបត្តិការជាមួយសេវាគ្រោះអាសន្នប្រទេសអូទ្រីសដែលនៅជាប់ព្រំដែនសម្រាប់ឧបទ្ទវហេតុ ឬហេតុការណ៍នានា ដែលអាចកើតមានឡើងនៅតំបន់ព្រំដែនជួរភ្នំរួមគ្នា។

### ២.២.៦. ការចូលរួមរបស់ប្រជាពលរដ្ឋ

ជាយូរមកហើយ ប្រព័ន្ធរដ្ឋាភិបាលមូលដ្ឋានប្រទេសអាល្លឺម៉ង់ ត្រូវបានបង្កើតឡើងដោយផ្អែកលើគំនិតប្រជាធិបតេយ្យជាតំណាង។ ប្រជាពលរដ្ឋបោះឆ្នោតជ្រើសរើសតំណាងរដ្ឋាភិបាលមូលដ្ឋានរបស់ខ្លួនរៀងរាល់៤-៥ឆ្នាំម្ដង ហើយតំណាងដែលជាប់ឆ្នោតនោះត្រូវកំណត់អំពីអាទិភាពគោលនយោបាយរបស់ឃុំ ដូចជា ការអនុម័តថវិកា និងការសម្រេចចិត្តលើគម្រោងវិនិយោគពាក់ព័ន្ធនឹងហេដ្ឋារចនាសម្ព័ន្ធនានា។

ការផ្ដោតលើប្រជាធិបតេយ្យជាតំណាងនេះ ត្រូវបានដាក់ជំនួសដោយទស្សនទានប្រជាធិបតេយ្យនៅមូលដ្ឋានដែលមានលក្ខណៈទូលំទូលាយជាងមុន និងមានលក្ខណៈចម្រុះជាងមុននៅក្នុងទម្រង់នៃការចូលរួមដោយផ្ទាល់ដែលបំពេញបន្ថែមទៅលើប្រព័ន្ធប្រជាធិបតេយ្យជាតំណាង។ មានតម្រូវការជាខ្លាំងក្នុងការចូលរួមជាសាធារណៈ ពិសេសពាក់ព័ន្ធការរៀបចំគម្រោងហេដ្ឋារចនាសម្ព័ន្ធ និងការរៀបចំផែនការគម្រោងនានា ដែលមានផលប៉ះពាល់ផ្ទាល់ទៅនឹងបរិយាកាស បរិស្ថាន និងជីវភាពប្រចាំថ្ងៃរបស់ប្រជាជន។ ក្នុងពេលបច្ចុប្បន្ន អ្វីដែលមានការព្រួយបារម្ភបំផុតគឺ គម្រោងប្រើប្រាស់ដី (ការជីករ៉ែ ចំការកសិកម្ម ការធ្វើទំនប់វារីអគ្គីសនី) ប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនសាធារណៈ

(អាកាសយានដ្ឋាន ផ្លូវរថភ្លើង) ការសាងសង់សំណង់ឧស្សាហកម្មធំៗ និងគម្រោងផលិតថាមពល (ឧស្សាហកម្មគីមីនិងដែក ឧស្សាហកម្មដុតសំរាម ឡដុតសំរាម ថាមពលខ្យល់) និងការរៀបចំអភិវឌ្ឍន៍ទីក្រុងដូចជាតំបន់លំនៅឋានថ្មី ការពង្រីកទីក្រុង ឬប្រព័ន្ធដឹកជញ្ជូនសាធារណៈថ្មី។

មូលដ្ឋានច្បាប់សម្រាប់ការចូលរួមរបស់ប្រជាពលរដ្ឋមានចែងនៅក្នុងច្បាប់តាមវិស័យ ដូចជា ច្បាប់សហព័ន្ធស្តីពីការត្រួតពិនិត្យការបញ្ចេញឧស្ម័នឆ្នាំ១៩៧៤ ដែលជាច្បាប់មួយក្នុងចំណោមច្បាប់ដំបូងៗ មាននីតិវិធីផ្លូវការអនុញ្ញាតឱ្យសាធារណជនបញ្ចេញមតិ និងតវ៉ាក្នុងដំណាក់កាលរៀបចំផែនការ/គម្រោង។ តាមច្បាប់អឺរ៉ុប ច្បាប់ជាច្រើនរបស់អាល្លឺម៉ង់បានពង្រីកបន្ថែមលើបញ្ហានៃការចូលរួមដោយផ្ទាល់របស់ប្រជាពលរដ្ឋ ឧទាហរណ៍ ច្បាប់អំពីបណ្ដឹងបរិស្ថាន (អនុម័តឆ្នាំ២០០៦) អនុញ្ញាតឱ្យអង្គការមិនមែនរដ្ឋាភិបាលនានាដែលធ្វើការងារបរិស្ថានអាចបញ្ជូនការសម្រេចចិត្តទៅតុលាការរដ្ឋបាល ហើយនៅឆ្នាំ២០១៣ ច្បាប់ស្តីពីនីតិវិធីរដ្ឋបាល ត្រូវបានបំពេញបន្ថែមផ្នែកថ្មីមួយស្តីពី "ការចូលរួមជាសាធារណៈ" ដែលជាតម្រូវការទូទៅមួយក្នុងដំណើរការរដ្ឋបាល។

ឧទាហរណ៍៖ ការចូលរួមដោយផ្ទាល់របស់ប្រជាពលរដ្ឋរួមមានដូចខាងក្រោម៖

- ការធ្វើប្រជាមតិនៅមូលដ្ឋាន ដែលបញ្ហាត្រូវបានសម្រេចតាមរយៈការបោះឆ្នោតផ្ទាល់របស់ប្រជាពលរដ្ឋ
- វេទិកាសាធារណៈដែលតំណាងជាប់ឆ្នោត និងមន្ត្រីមូលដ្ឋានចូលរួមជាមួយប្រជាពលរដ្ឋ និងអង្គការសង្គមស៊ីវិល ដើម្បីពិភាក្សាអំពីបញ្ហាគោលនយោបាយ និងយុទ្ធសាស្ត្រនៅមូលដ្ឋាន
- ការបង្ហាញជាសាធារណៈអំពីសេចក្ដីព្រាងផែនការនៃការប្រើប្រាស់ដី ផែនការកំណត់តំបន់ និងផែនការអភិវឌ្ឍន៍ដោយប្រជាពលរដ្ឋ

និងអាជីវកម្មនានាមានសិទ្ធិក្នុងការជំទាស់ ហើយប្រសិនបើការជំទាស់ទាំងនោះមិនត្រូវបានពិចារណាត្រឹមត្រូវទេនោះ ត្រូវលើកយកទៅដោះស្រាយនៅតុលាការរដ្ឋបាល

- ថវិការួមចំណែកដែលប្រជាពលរដ្ឋអាចចូលរួមក្នុងការកំណត់ភាគរយជាក់លាក់នៃថវិកាមូលដ្ឋាន
- ភាពជាសមាជិករបស់ពលរដ្ឋដែលមានចំណេះដឹងនៅក្នុងគណៈកម្មាធិការក្រុមប្រឹក្សាក្នុងនាមជាសមាជិកមិនបោះឆ្នោត
- យន្តការបញ្ចប់មុខតំណែង (Recall Mechanism) ប្រសិនបើប្រជាពលរដ្ឋមិនពេញចិត្តនឹងគោលនយោបាយ ឬការអនុវត្តរបស់អភិបាលជាប់ឆ្នោត។

ឧទាហរណ៍នៅក្រុង Kempten បានបង្ហាញពីការរៀបចំស្ថាប័នដែលមានលក្ខណៈចម្រុះ ការផ្តល់មូលនិធិ និងការចូលរួមរបស់អង្គការយុវជនអាចជួយធ្វើឱ្យគោលនយោបាយនៅមូលដ្ឋានកាន់តែទាក់ទាញសម្រាប់យុវជន។ ការអនុញ្ញាតឱ្យក្រុមយុវជនមានទំនាក់ទំនងជាមួយគណៈកម្មាធិការនៃក្រុមប្រឹក្សាក្រុង ធានាបានថាការពិភាក្សា និងយោបល់របស់យុវជនជំនាន់ក្រោយមានឥទ្ធិពល និងជំរុញដល់ការពិភាក្សា ព្រមទាំងការការសម្រេចចិត្តរបស់ក្រុមប្រឹក្សាដែលបានជាប់ឆ្នោត។

### ២.២.៧. កិច្ចសហប្រតិបត្តិការខ្សែបណ្តោយ និងខ្សែទទឹងរវាងរដ្ឋ និងរដ្ឋបាលមូលដ្ឋាន

ការរៀបចំប្រព័ន្ធនយោបាយ និងរដ្ឋបាលពហុកម្រិតរបស់ប្រទេសអាល្លឺម៉ង់ទាមទារឱ្យមានបណ្តាញរឹងមាំក្នុងការចែករំលែកព័ត៌មាន ការសហការ និងការសម្របសម្រួលរវាងកម្រិតនៃរដ្ឋបាលនីមួយៗ។ ជាក់ស្តែងបានបង្ហាញ

ក្នុងអំឡុងពេលជំងឺរាតត្បាតកូវីដ១៩ និងការណែនាំថ្មីៗលើសំបុត្រសម្រាប់សេវាដឹកជញ្ជូនសាធារណៈនៅមូលដ្ឋានដែលតម្រូវឱ្យមានការរៀបចំផ្នែកនយោបាយ ហិរញ្ញវត្ថុ និងរដ្ឋបាលច្បាស់លាស់រវាងរដ្ឋាភិបាលសហព័ន្ធ (រួមទាំងសាជីវកម្មផ្លូវដែកដែលគ្រប់គ្រងដោយសហព័ន្ធ) រដ្ឋាភិបាលរដ្ឋទាំង១៦ និងសមាគមដឹកជញ្ជូនរបស់រដ្ឋបាលមូលដ្ឋានប្រហែល ១០០ ដែលកំពុងដំណើរការដឹកជញ្ជូនសាធារណៈនៅមូលដ្ឋាននីមួយៗ។

តួនាទីរបស់ស្រុក និងទីក្រុងស្វយ័ត មានសារៈសំខាន់ក្នុងកិច្ចសហប្រតិបត្តិការខ្សែបណ្តោយ ព្រោះវាភ្ជាប់ទំនាក់ទំនងរវាងឃុំ និងទីក្រុងស្វយ័តជាមួយរដ្ឋាភិបាលរដ្ឋ (ដែលបន្ទាប់មកផ្សាភ្ជាប់ជាមួយរដ្ឋាភិបាលសហព័ន្ធ)។ ប្រព័ន្ធរដ្ឋាភិបាលមូលដ្ឋានមិនមានតំណាងនយោបាយនៅកម្រិតថ្នាក់រដ្ឋទេ ដែលអាចប្រៀបធៀបបានជាមួយនឹងស្ថាប័ននយោបាយតំណាងឱ្យរដ្ឋនៅកម្រិតសហព័ន្ធទេ។ ទោះបីយ៉ាងណាក៏ដោយ សមាគមផ្សេងៗនៃរដ្ឋាភិបាលមូលដ្ឋានមានសារៈសំខាន់ក្នុងការធានាទំនាក់ទំនងនយោបាយ ការតស៊ូមតិ ការចែករំលែកចំណេះដឹង និងការផ្សព្វផ្សាយនូវការអនុវត្តល្អៗ។

ដូចនៅប្រទេសស្វីសដែរ កិច្ចសហប្រតិបត្តិការអន្តរឃុំកើតមានយូរមកហើយនៅប្រទេសអាល្លឺម៉ង់ និងបានអនុញ្ញាតឱ្យថ្នាក់មូលដ្ឋានរក្សាកិច្ចការ និងមុខងារនៅមូលដ្ឋាន ទោះបីជាហួសពីសមត្ថភាពហិរញ្ញវត្ថុ និងបច្ចេកទេសនៃឃុំនីមួយៗក៏ដោយ។ មានឧទាហរណ៍ជាច្រើននៃកិច្ចសហប្រតិបត្តិការអន្តរឃុំ ដែលត្រូវបានរៀបចំជាលក្ខណៈសមាគមក្នុងគោលបំណងពិសេសជាក់លាក់ ដូចជា លើការដឹកជញ្ជូនសាធារណៈ ការផ្គត់ផ្គង់ទឹក ការគ្រប់គ្រងទឹកស្អុយ ការគ្រប់គ្រងសំណល់រឹង ឬការផ្តល់ការអប់រំនៅអនុវិទ្យាល័យជាដើម។ ថ្មីៗនេះ ឃុំបានរួមគ្នា (តាមរយៈសមាគមគោលបំណងពិសេស) ក្នុងការបង្កើតបណ្តាញ

ខ្សែហ្វាយប័រអ៊ុបទិក (Glass Fibre Network) នៅតំបន់ជនបទ ដើម្បីឱ្យប្រជាពលរដ្ឋទាំងអស់អាចប្រើប្រាស់អ៊ិនធឺណេតល្បឿនលឿន។

វិធីមួយទៀតដែលមានលក្ខណៈជាប្រយោល (Indirect) ក្នុងការរក្សាកិច្ចសហការតាមខ្សែបណ្ដោយ និងខ្សែទទឹង គឺធ្វើឡើងតាមរយៈគណបក្សនយោបាយដូចជា បុគ្គលិកគណបក្ស ប្រធានការិយាល័យ និងអ្នកតំណាងនយោបាយនៅថ្នាក់មូលដ្ឋាន និងថ្នាក់តំបន់ ព្រមទាំងការភ្ជាប់ទំនាក់ទំនងជាមួយតំណាងគណបក្សនៅកម្រិតរដ្ឋ និងកម្រិតសហព័ន្ធ ដើម្បីបង្កើតបណ្ដាញទំនាក់ទំនងមួយដ៏មានឥទ្ធិពល។

### ២.២.៨. ការត្រួតពិនិត្យ ការធ្វើអធិការកិច្ច និងការត្រួតពិនិត្យផ្នែកច្បាប់

ការត្រួតពិនិត្យលើរដ្ឋាភិបាលមូលដ្ឋានអាចត្រូវបានបែងចែកជាពីរប្រភេទធំៗ៖ ការត្រួតពិនិត្យផ្នែកច្បាប់ និងការត្រួតពិនិត្យផ្នែកបច្ចេកទេស៖

- **ការត្រួតពិនិត្យផ្នែកច្បាប់** គឺទាក់ទងទៅនឹងសកម្មភាពរបស់រដ្ឋាភិបាលមូលដ្ឋានក្នុងការអនុវត្តតាមច្បាប់ និងបទប្បញ្ញត្តិនានាដែលមានស្រាប់។ ការត្រួតពិនិត្យផ្នែកច្បាប់មិនពិនិត្យមើល ឬបញ្ជាក់ថាតើការសម្រេចចិត្តរបស់រដ្ឋបាលឃុំសមស្រប ឆ្លើយតបបានត្រឹមត្រូវចំពោះតម្រូវការជាអាទិភាពរបស់សហគមន៍ ឬមានភាពងាយស្រួលខាងនយោបាយនោះទេ។ ការត្រួតពិនិត្យផ្នែកច្បាប់គ្រាន់តែចោទសួរថា**តើការសម្រេចចិត្តមួយត្រូវបានធ្វើឡើងក្នុងលក្ខណៈត្រឹមត្រូវ ហើយមានការបំពានលើច្បាប់ឬបទប្បញ្ញត្តិណាមួយដែរទេ**។ ការត្រួតពិនិត្យផ្នែកច្បាប់ត្រូវបានអនុវត្តទាក់ទងនឹងកិច្ចការរបស់ឃុំ (តើកិច្ចការនោះជាកិច្ចការបានប្រគល់ឱ្យជាកិច្ចការស្ម័គ្រចិត្ត ឬជាកាតព្វកិច្ច?)។

- **ការត្រួតពិនិត្យបច្ចេកទេស** គឺទាក់ទងទៅនឹងការវាយតម្លៃថា **តើការសម្រេចចិត្តមានលក្ខណៈត្រឹមត្រូវតាមបច្ចេកទេស និងស្របតាមបទដ្ឋាន និងស្តង់ដាដែលមានស្រាប់ដែរឬទេ។** ទន្ទឹមនឹងនេះ ការត្រួតពិនិត្យបច្ចេកទេសគឺពិនិត្យទៅលើភាពស្របច្បាប់នៃសកម្មភាពរបស់រដ្ឋបាលមូលដ្ឋាន។ ការត្រួតពិនិត្យបច្ចេកទេសនេះ ត្រូវបានអនុវត្តទាក់ទងនឹងកិច្ចការដែលបានធ្វើប្រតិភូកម្មនៅពេលដែលអង្គភាពធ្វើប្រតិភូកម្ម (ដូចជា ក្រសួងបច្ចេកទេសរបស់រដ្ឋាភិបាលរដ្ឋ) ចង់ឱ្យមានការធានាថា កិច្ចការដែលបានធ្វើប្រតិភូកម្មត្រូវបានអនុវត្តក្នុងលក្ខណៈត្រឹមត្រូវ ស្របតាមច្បាប់ និងបទប្បញ្ញត្តិដែលមានស្រាប់។

មានការត្រួតពិនិត្យផងដែរលើ**ថវិកាឃុំ** (**ការត្រួតពិនិត្យហិរញ្ញវត្ថុ**) ដែលជាធម្មតាត្រូវបានចាត់ទុកថាជាផ្នែកមួយនៃការត្រួតពិនិត្យផ្នែកច្បាប់។ ប្រព័ន្ធនៃប្រទេសអាល្លឺម៉ង់បានបែងចែករវាងការត្រួតពិនិត្យហិរញ្ញវត្ថុបែបបង្ការទុកជាមុន (តាមរយៈការណែនាំ និងផ្តល់យោបល់ដល់ឃុំទាក់ទងនឹងហិរញ្ញវត្ថុ និងថវិកា) និងការត្រួតពិនិត្យហិរញ្ញវត្ថុបែបតឹងរឹង ដែលអាចកែសម្រួលចំពោះថវិកាដែលបានស្នើសុំ អាចបដិសេធថវិកាទាំងនោះ ឬការចេញសេចក្តីណែនាំដល់ឃុំដោយផ្ទាល់ទាក់ទងនឹងថវិកា។ ទោះជាយ៉ាងណាក៏ដោយ នៅក្នុងការអនុវត្តខ្សែបន្ទាត់រវាងការត្រួតពិនិត្យហិរញ្ញវត្ថុ និងការត្រួតពិនិត្យផ្សេងៗទៀត អាចមានការលំបាកក្នុងការញែកឱ្យដាច់ពីគ្នា។

ការត្រួតពិនិត្យលើរដ្ឋាភិបាលមូលដ្ឋានត្រូវបានរៀបចំតាមឋានានុក្រមដូចខាងក្រោម (សូមមើលរូបភាពទី៨)៖

- សម្រាប់ឃុំជាធម្មតានឹងត្រូវបានត្រួតពិនិត្យដោយស្រុកដែលដើរតួនាទីជាតំណាងឱ្យរដ្ឋ

- សម្រាប់ស្រុក និងទីក្រុងស្វយ័តត្រូវបានត្រួតពិនិត្យដោយរដ្ឋបាលតំបន់។ ប៉ុន្តែប្រសិនបើមិនមានរដ្ឋបាលតំបន់ទេនោះ នឹងត្រូវបានត្រួតពិនិត្យដោយក្រសួងហិរញ្ញវត្ថុ ឬក្រសួងមហាផ្ទៃនៃរដ្ឋបាលថ្នាក់រដ្ឋ
- សម្រាប់រដ្ឋបាលតំបន់នឹងត្រូវបានត្រួតពិនិត្យដោយក្រសួងមហាផ្ទៃរបស់រដ្ឋ (ដូចដែលបានបង្ហាញនៅក្នុងបទបង្ហាញរបស់ក្រសួងមហាផ្ទៃរដ្ឋ Bavaria កាលពីថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២៤)។

**រូបភាពទី៨៖ ការត្រួតពិនិត្យលើរដ្ឋាភិបាលមូលដ្ឋាននៅរដ្ឋបាវ៉ារៀ**




ប្រសិនបើរដ្ឋបាលមូលដ្ឋានមិនយល់ស្របនឹងការសម្រេចចិត្តណាមួយរបស់អង្គភាពត្រួតពិនិត្យទេនោះ អាចយកបញ្ហានោះទៅថ្នាក់លើបន្ទាប់ ដើម្បីត្រួតពិនិត្យ និងផ្ទៀងផ្ទាត់ឡើងវិញ។ បញ្ហាទាំងនោះក៏អាចយកទៅតុលាការរដ្ឋបាលផងដែរ។

ឃុំ និងនៅរដ្ឋបាលមូលដ្ឋានផ្សេងៗទៀតត្រូវមានគណនេយ្យភាពចំពោះមុខរដ្ឋាភិបាលថ្នាក់រដ្ឋសម្រាប់តែមុខងារដែលបានធ្វើប្រតិភូកម្ម ដែល

រដ្ឋបាលមូលដ្ឋានទាំងនេះបានអនុវត្តក្នុងនាមរដ្ឋាភិបាលថ្នាក់រដ្ឋ។ ក្រៅពីមុខងារដែលបានធ្វើប្រតិភូកម្ម រដ្ឋបាលមូលដ្ឋានទាំងនេះត្រូវមានគណនេយ្យភាពចំពោះប្រជាពលរដ្ឋ។ ការអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិដែលមានស្រាប់ត្រូវបានធានាតាមរយៈការត្រួតពិនិត្យផ្នែកច្បាប់ដែលបានលើកឡើងខាងលើ។

### ២.២.៩. ឌីជីថលភាវូបនីយកម្ម

ដូចរដ្ឋាភិបាលសហព័ន្ធ និងរដ្ឋាភិបាលរដ្ឋដែរ រដ្ឋាភិបាលមូលដ្ឋានត្រូវប្រើប្រាស់សក្តានុពលបច្ចេកវិទ្យាព័ត៌មាន និងឌីជីថលភាវូបនីយកម្ម។ ជាទូទៅ គេបានឃើញការកើនឡើងនៃការប្រើប្រាស់ "ប្រព័ន្ធផ្សព្វផ្សាយសង្គម" ដោយរដ្ឋបាលមូលដ្ឋាន ការប្រើប្រាស់ឧបករណ៍រដ្ឋាភិបាលឌីជីថល (e-government) និងកិច្ចខិតខំប្រឹងប្រែងក្នុងការប្រើប្រាស់ដំណើរការឌីជីថលនៅក្នុងកិច្ចការរដ្ឋបាលដើម្បីកាត់បន្ថយការចំណាយ និងបង្កើនល្បឿននៃការសម្រេចចិត្ត និងការផ្តល់សេវាសាធារណៈ។ ទោះជាយ៉ាងណាក៏ដោយ រដ្ឋាភិបាលអាល្លឺម៉ង់គ្រប់កម្រិត មិនទាន់ត្រូវបានគេមើលឃើញថាមានឧទាហរណ៍នៃការអនុវត្តល្អលើការងារឌីជីថលនៅឡើយទេ។ គោលដៅរបស់ច្បាប់សហព័ន្ធបានកំណត់នៅចុងឆ្នាំ២០២២ ឱ្យសេវារដ្ឋបាលសរុបចំនួន **៥៧៥សេវា** ត្រូវបានផ្តល់តាមប្រព័ន្ធអនឡាញ ប៉ុន្តែត្រូវបានខកខានលើចំនួនសេវាមួយចំណែកធំ។

មានការសិក្សាមួយរបស់សាកលវិទ្យាល័យ Hof នៅពាក់កណ្តាលឆ្នាំ២០២២ បានបង្ហាញឱ្យឃើញថា ការផ្លាស់ប្តូរបរិវត្តកម្មឌីជីថលនៅតែជាបញ្ហាប្រឈមសម្រាប់រដ្ឋាភិបាលមូលដ្ឋានទូទាំងប្រទេសអាល្លឺម៉ង់។ ខណៈពេលដែលនយោបាយ និងសង្គមកំពុងទាមទារឱ្យមានការផ្តល់សេវាតាមប្រព័ន្ធអនឡាញ រួមទាំងសេវាប្រជាពលរដ្ឋផង (ជាទូទៅត្រូវបានគេចាត់ទុកថា "ជា

រដ្ឋាភិបាលឌីជីថល") អង្គភាពរដ្ឋបាលជាច្រើននៅតែមានភាពច្របូកច្របល់រវាងបច្ចេកវិទ្យាឌីជីថល និងបច្ចេកវិទ្យាថ្មីៗ និងការប្រើប្រាស់រចនាសម្ព័ន្ធរឹងដែលមានស្រាប់ដែលត្រូវសម្រេចចិត្តផ្នែករដ្ឋបាលស្របទៅតាមច្បាប់ដែលត្រូវបានគេមើលឃើញថាមានសារៈសំខាន់ជាជាងល្បឿន និងការឆ្លើយតបនានា។ ការសិក្សាបានរកឃើញអំពីកម្រិតចម្រុះនៃឌីជីថលនីយកម្មនៅថ្នាក់មូលដ្ឋាន និងកង្វះជំនាញ និងចំណេះដឹងជាបន្តបន្ទាប់អំពីរបៀបប្រើប្រាស់ឱកាសនានាទៅតាមវិធីសាស្ត្រឌីជីថល។

កត្តាមួយទៀតដែលពន្យារពេល និងរារាំងដំណើរការបរិវត្តកម្មឌីជីថលគឺការព្រួយបារម្ភខ្លាំងអំពីការការពារទិន្នន័យ និងការការពារឯកជនភាព និងភាពផ្សេងៗគ្នានៅក្នុងប្រព័ន្ធអភិបាលកិច្ចពហុកម្រិតរបស់ប្រទេសអាល្លឺម៉ង់ផងដែរ។ សូម្បីតែតំណាងរដ្ឋាភិបាលមូលដ្ឋានក៏បានអំពាវនាវឱ្យមានស្តង់ដាបន្ថែមទៀតលើដំណើរការបរិវត្តកម្មការឌីជីថល និងឯកភាពរួមលើផ្នែករឹង និងផ្នែកទន់នៅទូទាំងប្រទេសអាល្លឺម៉ង់ ជាពិសេសសម្រាប់កិច្ចការចាំបាច់របស់រដ្ឋាភិបាលមូលដ្ឋានដែលពួកគេមិនមានឆន្ទានុសិទ្ធិក្នុងការសម្រេចចិត្តថាតើត្រូវផ្តោតលើ "អ្វី" និងត្រូវ "ធ្វើយ៉ាងដូចម្តេច"។

Kempten គឺជាក្រុងសាកល្បងមួយក្នុងចំណោមក្រុងចំនួន **៧៣** សម្រាប់គំរូនៃក្រុងឆ្លាតវៃ ដែលត្រូវបានផ្តល់មូលនិធិដោយរដ្ឋាភិបាលសហព័ន្ធ និងស្ថាប័នក្រុមធនាគារអភិវឌ្ឍន៍អាល្លឺម៉ង់ KFW។ កិច្ចអន្តរាគមន៍នានារបស់ក្រុង Kempten ទទួលបានមូលនិធិក្រោមកម្មវិធីអភិវឌ្ឍន៍ទីក្រុងរួមគ្នា (Integrated-Urban Development) ការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលសម្រាប់សេវាកម្មទីក្រុង ដូចជាការប្រមូលសំរាម និងការគ្រប់គ្រងចរាចរណ៍ជាដើម។ ដូចនៅទីក្រុងផ្សេងទៀតនៅ Bavaria ដែរ Kempten បានរៀបចំឱ្យមាន "ឌីជីថលភ្លោះ" "Digital twin" (ទីក្រុងដែលបង្ហាញផ្លូវ អគារ និងប្រព័ន្ធហេដ្ឋា

រចនាសម្ព័ន្ធសាធារណៈតាមគំរូ3D)។ ឌីជីថលភ្លោះនេះ ត្រូវបានប្រើសម្រាប់គោលបំណងធ្វើផែនការ និងដំណើរការរដ្ឋបាល ហើយក៏អាចប្រើប្រាស់ដោយពលរដ្ឋម្នាក់ៗ និងអង្គភាពអាជីវកម្មដែលកំពុងស្វែងរកព័ត៌មានជាក់លាក់ផងដែរ។ ដើម្បីជំរុញសហគមន៍ឱ្យចូលរួមក្នុងការដំណើរការបរិវត្តកម្មឌីជីថល ក្រុង Kempten បានបង្កើត "បន្ទប់ពិសោធន៍" នៅកណ្ដាលទីក្រុង (កន្លែងបើកចំហសម្រាប់សាធារណជនដែលបុគ្គលិកអាចជួយដល់ប្រជាពលរដ្ឋឱ្យប្រើប្រាស់ឧបករណ៍ និងដំណើរការឌីជីថលបាន)។

### ២.២.១០. តួនាទី និងមុខងាររបស់សមាគមរដ្ឋាភិបាលមូលដ្ឋាន

សមាគមស្ម័គ្រចិត្តនៃរដ្ឋាភិបាលមូលដ្ឋានបានផ្ដល់ឱកាសសម្រាប់ការផ្លាស់ប្ដូរ និងការរៀនសូត្រពីគ្នាទៅវិញទៅមក ក៏ដូចជាសម្រាប់ការតស៊ូមតិផ្នែកនយោបាយ និងក៏ជាតំណាងនៅថ្នាក់រដ្ឋ និងថ្នាក់សហព័ន្ធផងដែរ។ មានសមាគមសំខាន់ៗចំនួនបីនៅថ្នាក់ជាតិ៖ សមាគម Deutsche Städtetag (តំណាងឱ្យរដ្ឋាភិបាលមូលដ្ឋានក្នុងតំបន់ទីប្រជុំជនជាង **៥.៧00**) សមាគម Deutsche Städte-und Gemeindebund (សមាគមជាតិនៃសមាគមឃុំក្នុងរដ្ឋទាំង១៧) និងសមាគម Deutsche Landkreistag (តំណាងឱ្យស្រុកនៅជនបទ)។ សមាគមទាំងនេះដំណើរការរួមគ្នាជាមួយការិយាល័យតំណាងអឺរ៉ុបនៅទីក្រុងប្រ៊ុយសែល (Brussels) ខណៈដែលកិច្ចការជាច្រើនរបស់រដ្ឋាភិបាលមូលដ្ឋាននាពេលបច្ចុប្បន្នក៏ទទួលឥទ្ធិពល និងកំណត់នៅក្នុងបទប្បញ្ញត្តិរបស់សហភាពអឺរ៉ុបផងដែរ។

សមាគមទាំងអស់ត្រូវបានផ្ដល់ហិរញ្ញប្បទានដោយថវិកាសមាជិក និងការរួមចំណែកពីរដ្ឋាភិបាលមូលដ្ឋានដែលជាសមាជិករបស់ខ្លួន។ សមាគមមានស្វ័យភាព និងមិនមែនជាផ្នែកនៃប្រព័ន្ធរដ្ឋបាលសាធារណៈឡើយ។ នៅ

ក្នុងរដ្ឋមួយចំនួន (ដូចជា Bayern, Baden-Württemberg, Sachsen, Thüringen und Brandenburg) ច្បាប់របស់រដ្ឋបានចែងអំពីការចូលរួមជាកាតព្វកិច្ចនៃសមាគមបែបនេះនៅក្នុងដំណើរការរៀបចំបទប្បញ្ញត្តិរបស់ថ្នាក់រដ្ឋ (សមាគមទាំងនេះត្រូវបានស្នើឱ្យផ្ដល់មតិយោបល់ជាទៀងទាត់លើសេចក្ដីព្រាងច្បាប់រដ្ឋ និងត្រូវបានអញ្ជើញឱ្យចូលរួមសវនាការជាសាធារណៈរបស់សភារដ្ឋ និងអាចស្នើអ្នកជំនាញបច្ចេកទេសសម្រាប់គណៈកម្មាធិការនានាក្រុមការងារបច្ចេកទេស និងស្ថាប័នផ្ដល់យោបល់នៃក្រសួងរបស់រដ្ឋ)។

សមាគមនានាគឺជាដៃគូ និងសមាជិកនៃ ក្រុមការងាររួមគ្រប់គ្រងរដ្ឋបាលមូលដ្ឋាន (Kommunale Gemeinschaftsstelle für Verwaltungsmanagement) ដែលជាស្ថាប័នឯករាជ្យសម្រាប់ការអភិវឌ្ឍសមត្ថភាព ការរៀនសូត្រ ការផ្លាស់ប្ដូរយោបល់ និងការប្រមូលផ្ដុំបទពិសោធន៍ល្អៗសម្រាប់រដ្ឋបាលមូលដ្ឋានដែលជាសមាជិក។

## គ. មេរៀន និងបទពិសោធន៍សំខាន់ៗដែលគណៈប្រតិភូបានរៀនសូត្រ

នៅក្នុងដំណើរទស្សនកិច្ចសិក្សារយៈពេលមួយសប្ដាហ៍នេះ គណៈប្រតិភូកម្ពុជាបានសិក្សារៀនសូត្រអំពីចំណុចសំខាន់ៗមួយចំនួននៃប្រព័ន្ធគ្រប់គ្រងអភិបាលកិច្ចនៅក្នុងប្រទេសទាំងពីរ៖

១). ប្រព័ន្ធអភិបាលកិច្ចនៃប្រទេសទាំងពីរ (ស្វីស និងអាល្លឺម៉ង់) បានផ្ដល់សិទ្ធិអំណាច និងស្វ័យភាពយ៉ាងច្រើនដល់រដ្ឋាភិបាលមូលដ្ឋានលើកិច្ចការសំខាន់ៗដូចជា ការរៀបចំស្ថាប័ន (រចនាសម្ព័ន្ធគ្រប់គ្រងរដ្ឋបាល) ការគ្រប់គ្រងបុគ្គលិក (ការជួល/ជ្រើសរើសបុគ្គលិកផ្អែកតាមរចនាសម្ព័ន្ធ) ការអនុវត្តកិច្ចការផ្ដល់សេវា (រដ្ឋបាលថ្នាក់ទាបបំផុតមានសិទ្ធិផ្ដល់សេវាសំខាន់ៗតាមដែលអាចធ្វើទៅបានដែលជាការ

បង្និតសេវាកាន់តែកៀកជិតប្រជាពលរដ្ឋ) និងការប្រមូលចំណូលមូលដ្ឋាន (ការប្រមូលពន្ធ និងចំណូលមិនមែនពន្ធ) ដើម្បីធានាផ្តល់មូលនិធិក្នុងការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋានជូនប្រជាពលរដ្ឋ។ ការផ្តល់សិទ្ធិអំណាច និងស្វ័យភាពដល់រដ្ឋាភិបាលមូលដ្ឋាននេះ បានធ្វើឱ្យប្រទេសទាំងពីរឆ្លើយតបយ៉ាងមានប្រសិទ្ធភាពលើសេចក្តីត្រូវការនានារបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន និងអាចនាំប្រទេសឱ្យមានសេដ្ឋកិច្ចរឹងមាំផងដែរ។ សម្រាប់ប្រទេសកម្ពុជាដែលកំពុងអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ ការផ្តល់សិទ្ធិអំណាច និងស្វ័យភាពទៅរដ្ឋបាលថ្នាក់ក្រោមជាតិ គឺជាចក្ខុវិស័យ និងគោលបំណងចម្បងនៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ។ ទោះបីជាយ៉ាងណាក៏ដោយ កិច្ចការនេះគួរអនុវត្តក្នុងលក្ខណៈសន្សឹមៗបន្តិចម្តងៗ តាមរយៈការអនុវត្តសាកល្បង និងបន្ទាប់មកធ្វើការពង្រីកវិសាលភាពអនុវត្តជាក្រោយ។ មុខងារ/កិច្ចការមួយចំនួនត្រូវបានផ្ទេររួចហើយពីថ្នាក់ជាតិ (តាមរយៈការប្រគល់ ឬធ្វើប្រតិភូកម្ម) ទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ប៉ុន្តែទាមទារឱ្យមានការផ្ទេរកិច្ចការ/មុខងារជាបន្តបន្ទាប់បន្ថែមទៀត ដើម្បីបង្និតសេវាឱ្យកាន់តែកៀកជិតប្រជាពលរដ្ឋ។ ការផ្តល់សិទ្ធិអំណាច និងស្វ័យភាពដល់រដ្ឋបាលថ្នាក់ក្រោមជាតិ (ពិសេសរដ្ឋបាលក្រុង ស្រុក ខណ្ឌ ដែលជារដ្ឋបាលឯកភាព និងមានរចនាសម្ព័ន្ធរឹងមាំ) គួរជាតែជាអាទិភាពសំខាន់ ដើម្បីពង្រឹងដល់ដំណើរការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន ផ្អែកតាមរចនាសម្ព័ន្ធ ប្រព័ន្ធ និងយន្តការដែលបានបង្កើតរួចហើយ។ សិទ្ធិអំណាច និងស្វ័យភាពលើការគ្រប់គ្រង និងការចាត់ចែងបុគ្គលិកនឹងធានាឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌអាចឆ្លើយតបបានយ៉ាងមាន

ប្រសិទ្ធភាពទៅលើតម្រូវការសេវាចាំបាច់នានារបស់ប្រជាពលរដ្ឋ ហើយសិទ្ធិអំណាច និងស្វ័យភាពផ្នែកហិរញ្ញវត្ថុនឹងធានាឱ្យរដ្ឋបាលក្រុងស្រុកមានធនធានគ្រប់គ្រាន់ដើម្បីផ្តល់មូលនិធិលើការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន។ ចំណុចខាងលើនេះ គឺជាចំណុចសំខាន់មួយនៃការធ្វើវិមជ្ឈការប្រកបដោយនិរន្តរភាពផងដែរ។ កិច្ចការហិរញ្ញវត្ថុមូលដ្ឋាន គួរចាប់ផ្តើមការអនុវត្តជាជំហានៗនៅថ្នាក់ក្រោមជាតិដែលមានរចនាសម្ព័ន្ធ និងសមត្ថភាពសមស្រប ដូចជា រដ្ឋបាលក្រុង ស្រុក និងរដ្ឋបាលរាជធានី ខេត្ត តាមរយៈការផ្តល់សិទ្ធិ និងស្វ័យភាពលើការប្រមូលពន្ធ និងការប្រមូលចំណូលជាក់លាក់ៗមួយចំនួនដែលអាចចាត់ទុកថាជាចំណូលផ្ទាល់របស់ពួកគេ ហើយកម្រិត/ទំហំនៃការអនុវត្តការប្រមូលចំណូលនេះ អាចពង្រីកម្តងបន្តិចៗ ក្នុងរយៈពេលសមស្របណាមួយ។

២). ការចូលរួមពីប្រជាពលរដ្ឋលើកិច្ចការអភិវឌ្ឍន៍មូលដ្ឋានមានលក្ខណៈទូលំទូលាយ តាមរយៈការប្រើប្រាស់នូវឧបករណ៍ប្រជាធិបតេយ្យដ៏មានឥទ្ធិពលជាច្រើនដូចជា ការបោះឆ្នោត ការធ្វើប្រជាមតិ ការផ្តួចផ្តើមគំនិត ការតស៊ូមតិ និងឧបករណ៍ផ្សេងៗទៀត។ ប្រទេសទាំងពីរមានអង្គការសង្គមស៊ីវិលច្រើនដែលតំណាងឱ្យគ្រប់ផលប្រយោជន៍នានានៅក្នុងសហគមន៍ មានភាពសកម្ម និងមានឯករាជ្យភាពលើធនធានហិរញ្ញវត្ថុ។ ជាទូទៅ ការចូលរួមរបស់ប្រជាពលរដ្ឋមានឥទ្ធិពលលើការផ្លាស់ប្តូរធំៗមួយចំនួនដូចជា ការផ្លាស់ប្តូរច្បាប់ និងមូលដ្ឋានច្បាប់នានានៅមូលដ្ឋាន អត្រាពន្ធ និងការចំណាយសាធារណៈនានា ។ល។ ការចូលរួមរបស់ប្រជាពលរដ្ឋលើកិច្ចការនៅមូលដ្ឋាននៅប្រទេសកម្ពុជា ត្រូវបានរៀបចំតាមរយៈដំណើរការរៀបចំផែនការ

ការរៀបចំថវិកា ការអនុវត្តគម្រោង ការរៀបចំវេទិកាសាធារណៈ កិច្ចប្រជុំនានា និងយន្តការគណនេយ្យភាពសង្គម។ ទោះបីជាយ៉ាងណាក៏ដោយ ការអនុវត្តយន្តការគណនេយ្យភាពសង្គម ត្រូវបានអនុវត្តភាគច្រើននៅថ្នាក់ឃុំ សង្កាត់ដោយផ្តោតលើសេវាសំខាន់ៗមួយចំនួនប៉ុណ្ណោះ ដែលការងារនេះទាមទារឱ្យមានការពង្រីកវិសាលភាពបន្ថែមទៅថ្នាក់ក្រុង ស្រុក ខណ្ឌ និងផ្តោតលើគ្រប់សេវាទាំងអស់។ តាមរយៈបទពិសោធន៍នៃប្រទេសទាំងពីរគួរពង្រឹងការអនុវត្តយន្តការនៃការចូលរួមរបស់ប្រជាពលរដ្ឋបន្ថែមទៀត រួមទាំងការលើកទឹកចិត្ត និងបង្កលក្ខណៈងាយស្រួល ដើម្បីឱ្យយន្តការទាំងនេះ ជាពិសេសប្រជាពលរដ្ឋមានភាពសកម្មក្នុងការចូលរួមជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងដំណើរការនៃការរៀបចំផែនការ ការធ្វើសេចក្តីសម្រេចចិត្តនានា ការអនុវត្ត និងការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ។

៣). រដ្ឋាភិបាលគ្រប់កម្រិតមានកិច្ចសហប្រតិបត្តិល្អក្នុងការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋានជូនដល់ប្រជាពលរដ្ឋ។ កិច្ចសហប្រតិបត្តិការអន្តររដ្ឋាភិបាល រវាងរដ្ឋាភិបាលមូលដ្ឋានដែលមានកម្រិតស្មើគ្នា (ខ្សែទទឹង) និងរវាងរដ្ឋាភិបាលដែលកម្រិតផ្សេងគ្នា (ខ្សែបណ្តោយ) តាមរយៈការចែករំលែកការទទួលខុសត្រូវ បានដើរតួនាទីយ៉ាងសំខាន់ក្នុងការវិនិយោគលើគម្រោងហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត និងការផ្តល់សេវាចាំបាច់នានា ដើម្បីបំពេញសេចក្តីត្រូវការជូនប្រជាពលរដ្ឋ។ អង្គភាព ស្ថាប័នពាក់ព័ន្ធជាច្រើនត្រូវបានបង្កើតឡើងដើម្បីជួយសម្របសម្រួលដល់កិច្ចសហប្រតិបត្តិការទាំងនោះ។ មេរៀន និងបទពិសោធន៍នៃប្រទេសទាំងពីរនេះ បានបង្ហាញផ្លូវមួយចំនួនសម្រាប់រដ្ឋបាលមូលដ្ឋាននៅកម្ពុជា។ កិច្ចសហប្រតិបត្តិការរវាងឃុំ/

សង្កាត់និងឃុំ/សង្កាត់ ក្រុង/ស្រុកនិងក្រុង/ស្រុក ខេត្តនិងខេត្ត និង ការចែករំលែកការទទួលខុសត្រូវលើកិច្ចការជាក់លាក់មួយចំនួនរវាង ថ្នាក់រដ្ឋបាលទាំងអស់ (ឧ. ថ្នាក់ជាតិ/ក្រសួង ស្ថាប័នជាមួយរដ្ឋបាល រាជធានី/ខេត្ត ក្រុង/ស្រុក និងឃុំ/សង្កាត់) ដើរតួនាទីយ៉ាងសំខាន់ក្នុង ការឆ្លើយតបតម្រូវការនៃការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍ មូលដ្ឋានជូនដល់ប្រជាពលរដ្ឋដែលជាចក្ខុវិស័យ និងគោលដៅ ចុងក្រោយនៃការងារកំណែទម្រង់។

៤). សមាគមរដ្ឋាភិបាលមូលដ្ឋាននៃប្រទេសទាំងពីរបានដើរតួនាទីយ៉ាង សំខាន់សម្រាប់ការផ្លាស់ប្តូរបទពិសោធន៍និងការរៀនសូត្រពីគ្នាទៅ វិញទៅមក ការតស៊ូមតិផ្នែកនយោបាយ និងធ្វើជាតំណាងនៅថ្នាក់រដ្ឋ និងថ្នាក់សហព័ន្ធផងដែរ។ សមាគមនេះបានជួយគាំទ្រឱ្យរដ្ឋាភិបាល មូលដ្ឋានមានសមត្ថភាពកាន់តែប្រសើរឡើងនៅក្នុងការផ្តល់សេវា និង អភិវឌ្ឍន៍មូលដ្ឋាន ព្រមទាំងការពារបាននូវសំឡេង និងអត្ថប្រយោជន៍ របស់ពួកគេចំពោះគោលនយោបាយ លិខិតបទដ្ឋាន និងការសម្រេចចិត្ត នានារបស់ថ្នាក់ជាតិដែលមានផលប៉ះពាល់ដល់រដ្ឋាភិបាលមូលដ្ឋាន និងការផ្តល់សេវាជូនប្រជាពលរដ្ឋ។ សមាគមទាំងនេះមានឯករាជ្យ ភាពផ្នែកហិរញ្ញវត្ថុតាមរយៈថវិកាសមាជិក និងការរួមចំណែកពី រដ្ឋាភិបាលមូលដ្ឋានដែលជាសមាជិករបស់ខ្លួន។ មេរៀនបទពិសោធន៍ ទាំងនេះជាមូលដ្ឋានដ៏ល្អមួយនៅក្នុងការពង្រឹងនូវតួនាទីរបស់សមាគម ក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការកសាងសមត្ថភាពរបស់ ក្រុមប្រឹក្សា និងការចូលរួមចំណែកក្នុងការគាំទ្រដល់ការពង្រឹងសិទ្ធិ អំណាច ការទទួលខុសត្រូវលើតួនាទី និងភារកិច្ចរបស់ក្រុមប្រឹក្សា ក៏ ដូចជាសិក្សាពីលទ្ធភាពក្នុងការរៀបចំឱ្យមានសមាគមរដ្ឋបាលថ្នាក់

ក្រោមជាតិដើម្បីធ្វើជាសំឡេង និងការការពារអត្ថប្រយោជន៍របស់រដ្ឋបាលថ្នាក់ក្រោមជាតិទាំងមូល ក៏ដូចជាប្រជាពលរដ្ឋនៅមូលដ្ឋាន។

៥). ប្រទេសទាំងពីរបានរៀបចំឱ្យមានយន្តការ និងនីតិវិធីតាមដានត្រួតពិនិត្យច្បាស់លាស់ទៅលើរដ្ឋាភិបាលមូលដ្ឋាន ជាពិសេសប្រទេសអាល្លឺម៉ង់ដែលបានរៀបចំការត្រួតពិនិត្យលើរដ្ឋាភិបាលមូលដ្ឋានតាមឋានានុក្រមច្បាស់លាស់រវាងរដ្ឋបាលឃុំ រដ្ឋបាលស្រុករដ្ឋបាលតំបន់ និងរដ្ឋបាលថ្នាក់រដ្ឋ ព្រមទាំងបានបែងចែកនីតិវិធីច្បាស់លាស់រវាងការត្រួតពិនិត្យផ្នែកច្បាប់ និងការត្រួតពិនិត្យផ្នែកបច្ចេកទេស។ ទន្ទឹមនេះ ប្រទេសទាំងពីរនេះ ក៏បានរៀបចំយន្តការជាក់លាក់សម្រាប់រដ្ឋាភិបាលមូលដ្ឋានក្នុងការធ្វើការតវ៉ាក្នុងករណីដែលរដ្ឋាភិបាលមូលដ្ឋានមិនឯកភាពចំពោះលទ្ធផលនៃការតាមដានត្រួតពិនិត្យនេះ ដោយរួមទាំងការប្ដឹងតវ៉ាទៅតុលាការរដ្ឋបាលផងដែរ។ មេរៀនបទពិសោធន៍ទាំងនេះ នឹងផ្ដល់ធាតុចូលយ៉ាងសំខាន់សម្រាប់ការរៀបចំ និងពង្រឹងនូវការគាំទ្រនិងតាមដានត្រួតពិនិត្យទៅលើរដ្ឋបាលថ្នាក់ក្រោមជាតិរបស់ប្រទេសកម្ពុជា ព្រមទាំងការរៀបចំឱ្យមានយន្តការជាក់លាក់មួយសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការត្រួតពិនិត្យ និងការធ្វើអធិការកិច្ច ព្រមទាំងការតវ៉ាឡើងវិញចំពោះលទ្ធផលនៃការត្រួតពិនិត្យ និងការធ្វើអធិការកិច្ច។

៦). ខាងក្រោមនេះ ជាចំណុចសំខាន់ៗនៃការយល់ដឹងរបស់គណៈប្រតិភូអំពីទម្រង់/គំរូនៃការគ្រប់គ្រងតាមបែបវិមជ្ឈការនៅប្រទេសស្វីស និងប្រទេសអាល្លឺម៉ង់៖

## តារាងទី០១៖ ភារកិច្ច និងមុខងារនៅក្នុងប្រព័ន្ធរដ្ឋបាលមូលដ្ឋានរបស់ប្រទេសអាល្លឺម៉ង់

| រដ្ឋបាលមូលដ្ឋាន | ប្រភេទនៃភារកិច្ច | ប្រភេទនៃមុខងារ | ឧទាហរណ៍ | ប្រភពចំណូល | ការរៀបចំរដ្ឋបាល |
|---|---|---|---|---|---|
| ឃុំ (*Gemeinde*) | ១. អាណត្តិទូទៅ (កិច្ចការមូលដ្ឋាន) | មុខងារស្ម័គ្រចិត្ត និង មុខងារជាជម្រើស | អាងហែលទឹកសាធារណៈ កន្លែងហាត់ប្រាណ បណ្ណាល័យ អគារសាលាក្រុង សួនកុមារ លំនៅដ្ឋានអ្នកចូលនិវត្តន៍ ការអភិវឌ្ឍន៍សេដ្ឋកិច្ច | ចំណូលផ្ទាល់ខ្លួន និងចំណូលបានពីការចែករំលែក | រដ្ឋបាលមូលដ្ឋាន |
| | ២. កិច្ចការដែលបានប្រគល់ (ច្បាប់របស់រដ្ឋ) | មុខងារជាកាតព្វកិច្ច និងមុខងារស្ម័គ្រចិត្ត | ការផ្តល់អគារសម្រាប់បឋមសិក្សា ការធ្វើផែនការ និងការកំណត់តំបន់ប្រើប្រាស់ដី ការផ្គត់ផ្គង់ទឹកស្អាត និងការចោលសំណល់រាវ កងពន្លត់អគ្គីភ័យ ការកសាងផ្លូវនៅមូលដ្ឋាន | ចំណូលផ្ទាល់ខ្លួន និងចំណូលបានពីការចែករំលែក | រដ្ឋបាលមូលដ្ឋាន |
| | ៣. កិច្ចការដែលបានធ្វើប្រតិភូកម្ម (ច្បាប់របស់រដ្ឋ) | មុខងារជាកាតព្វកិច្ច | សេវាសង្គម | ចំណូលផ្ទាល់ខ្លួន និងចំណូលបានពីការចែករំលែក | រដ្ឋបាលមូលដ្ឋាន |

| រដ្ឋបាលមូលដ្ឋាន | ប្រភេទនៃភារកិច្ច | ប្រភេទនៃមុខងារ | ឧទាហរណ៍ | ប្រភពចំណូល | ការរៀបចំរដ្ឋបាល |
|---|---|---|---|---|---|
| ស្រុក (*Kreis*) | ១. កិច្ចការមូលដ្ឋានហួសពីសមត្ថភាពឃុំ | មុខងារជាកាតព្វកិច្ច និងមុខងារស្ម័គ្រចិត្ត | ការផ្តល់អគារសម្រាប់អនុវិទ្យាល័យ ការកសាងផ្លូវក្នុង មូលដ្ឋាន | វិភាគទានហិរញ្ញវត្ថុពីសមាជិកឃុំ ចំណូលផ្ទាល់ខ្លួន និងចំណូលបានពីការចែករំលែក | រដ្ឋបាលមូលដ្ឋាន |
| | ២. កិច្ចការផ្ទាល់ខ្លួន និងកិច្ចការដែលធ្វើប្រតិភូកម្ម | មុខងារជាកាតព្វកិច្ច និងមុខងារស្ម័គ្រចិត្ត | សុខុមាលភាពយុវជន មន្ទីរពេទ្យទូទៅ | ចំណូលផ្ទាល់ខ្លួន និងចំណូលបានពីការចែករំលែក | រដ្ឋបាលមូលដ្ឋាន |
| | ៣. កិច្ចការដែលបានធ្វើប្រតិភូកម្ម (ច្បាប់របស់រដ្ឋ) | មុខងារជាកាតព្វកិច្ច | សេវាសង្គម ការចុះបញ្ជីជនអន្តោប្រវេសន៍ ការចុះសញ្ជាតិ ពាណិជ្ជកម្ម ការគ្រប់គ្រងអាវុធ សិទ្ធិទទួលបានច្បាប់រដ្ឋសភា | ចំណូលផ្ទាល់ខ្លួន និងចំណូលបានពីការចែករំលែក | រដ្ឋបាលមូលដ្ឋាន |

| រដ្ឋបាលមូលដ្ឋាន | ប្រភេទនៃភារកិច្ច | ប្រភេទនៃមុខងារ | ឧទាហរណ៍ | ប្រភពចំណូល | ការរៀបចំរដ្ឋបាល |
|---|---|---|---|---|---|
| | ៤. កិច្ចការដែលបានពីកំណែទម្រង់វិសហមជ្ឈការ | មុខងារជាកាតព្វកិច្ច | ការចុះបញ្ជីឈ្មោះប្រជាពលរដ្ឋ ការផ្ដល់អត្តសញ្ញាណប័ណ្ណ និងលិខិតឆ្លងដែន ការចុះបញ្ជីយានយន្ត | ការផ្ទេរធនធាន | រដ្ឋបាលវិសហមជ្ឈការ |
| ក្រុង (*Kreisfreie Stadt*) | ១. អាណត្តិទូទៅ (កិច្ចការមូលដ្ឋាន) | មុខងារស្ម័គ្រចិត្ត និងមុខងារជាជម្រើស | អាងហែលទឹកសាធារណៈ កន្លែងហាត់ប្រាណ បណ្ណាល័យ អគារសាលាក្រុង សួនកុមារ លំនៅដ្ឋានចូលនិវត្តន៍ ការអភិវឌ្ឍន៍សេដ្ឋកិច្ច | ចំណូលផ្ទាល់ខ្លួន | រដ្ឋបាលមូលដ្ឋាន |
| | ២. កិច្ចការដែលបានប្រគល់ (ច្បាប់របស់រដ្ឋ) | មុខងារជាកាតព្វកិច្ច និងមុខងារស្ម័គ្រចិត្ត | ការផ្ដល់អគារសម្រាប់បឋមសិក្សា ការធ្វើផែនការ និងការកំណត់តំបន់ប្រើប្រាស់ដី ការផ្គត់ផ្គង់ទឹកស្អាត និងការចោលសំណល់រាវ កងពន្លត់អគ្គីភ័យ ការកសាងផ្លូវនៅមូលដ្ឋាន | ចំណូលផ្ទាល់ខ្លួន និងចំណូលបានពីការចែករំលែក | រដ្ឋបាលមូលដ្ឋាន |

| រដ្ឋបាលមូលដ្ឋាន | ប្រភេទនៃនាវកិច្ច | ប្រភេទនៃមុខងារ | ឧទាហរណ៍ | ប្រភពចំណូល | ការរៀបចំរដ្ឋបាល |
|---|---|---|---|---|---|
| | ៣. កិច្ចការដែលបានធ្វើប្រតិភូកម្ម (ច្បាប់របស់រដ្ឋ) | មុខងារជាកាតព្វកិច្ច | សេវាសង្គម ការចុះឈ្មោះជនអន្តោប្រវេសន៍ ការចុះសញ្ជាតិ ពាណិជ្ជកម្ម ការគ្រប់គ្រងអាវុធ សិទ្ធិទទួលបានច្បាប់គ្រប់គ្រងសិទ្ធិក្នុងវេទិកាសាធារណៈ | ចំណូលផ្ទាល់ខ្លួន និងចំណូលបានពីការចែករំលែក | រដ្ឋបាលមូលដ្ឋាន |
| | ៤. កិច្ចការដែលបានពីកំណែទម្រង់វិសហមជ្ឈការ | មុខងារជាកាតព្វកិច្ច | ការចុះបញ្ជីឈ្មោះប្រជាពលរដ្ឋ ការផ្តល់អត្តសញ្ញាណប័ណ្ណ និងលិខិតឆ្លងដែន ការចុះបញ្ជីយានយន្ត | ការផ្ទេរធនធាន | រដ្ឋបាលវិសហមជ្ឈការ |
| រដ្ឋបាលតំបន់ (*Bezirke*) | កិច្ចការដែលបានធ្វើប្រតិភូកម្ម (ច្បាប់របស់រដ្ឋ) | មុខងារជាកាតព្វកិច្ច និងមុខងារស្ម័គ្រចិត្ត | ការគ្រប់គ្រងមន្ទីរពេទ្យឯកទេសផ្នែកវិកលចរិត ការប្រមូលផ្តុំមនុស្សដែលមានពិការភាពផ្លូវចិត្ត បញ្ញា ឬរាងកាយ ការលើកកម្ពស់ការអភិរក្សធម្មជាតិ និងការការពារបរិស្ថាន កន្លែងបណ្តុះបណ្តាលវិជ្ជាជីវៈ និងបច្ចេកទេស | វិភាគទានហិរញ្ញវត្ថុពីសមាជិកឃុំសង្កាត់ ចំណូលផ្ទាល់ខ្លួន និងចំណូលបានពីការចែករំលែក | រដ្ឋបាលតំបន់ |

## តារាងទី០២៖ ភាពខុសគ្នា និងភាពស្រដៀងគ្នានៃប្រព័ន្ធរដ្ឋបាលមូលដ្ឋាននៅប្រទេសស្វីស និងអាល្លឺម៉ង់

| ចំណុច | ប្រទេសស្វីស | ប្រទេសអាល្លឺម៉ង់ |
| --- | --- | --- |
| **រចនាសម្ព័ន្ធរដ្ឋ** | • កម្រិតសហព័ន្ធ និងខេត្ត ២៦<br>• សភា Bicameral (ក្រុមប្រឹក្សាជាតិ និងក្រុមប្រឹក្សារដ្ឋ) សមាជិកនៃសភាទាំងពីរត្រូវបានបោះឆ្នោតជ្រើសរើសដោយផ្ទាល់<br>• មុខងារ៖ មុខងារផ្តាច់មុខរបស់សហព័ន្ធ មុខងារផ្តាច់មុខរបស់ខេត្ត និងមុខងារចែករំលែក<br>• ផ្តោតលើរដ្ឋបាលសាធារណៈនៅកម្រិតរដ្ឋ និងកម្រិតមូលដ្ឋាន | • កម្រិតសហព័ន្ធ និងរដ្ឋចំនួន១៦<br>• ប្រព័ន្ធនីតិប្បញ្ញត្តិ Bicameral (សភាជាតិ បោះឆ្នោតជ្រើសរើសដោយផ្ទាល់) និងក្រុមប្រឹក្សារដ្ឋសហព័ន្ធ (Bundesrat) (តំណាងឱ្យរដ្ឋាភិបាលរដ្ឋ)<br>• មុខងារ៖ មុខងារផ្តាច់មុខរបស់សហព័ន្ធ មុខងារផ្តាច់មុខរបស់រដ្ឋ និងមុខងារចែករំលែក<br>• ផ្តោតលើរដ្ឋបាលសាធារណៈនៅកម្រិតរដ្ឋ និងកម្រិតមូលដ្ឋាន |
| **រដ្ឋធម្មនុញ្ញការពាររដ្ឋបាលមូលដ្ឋាន** | មាត្រា៥០៖ កិច្ចការពារស្វ័យភាពឃុំបានកំណត់ដោយខេត្ត។ | មាត្រា២៨៖ រដ្ឋបាលមូលដ្ឋានត្រូវបានធានាថា "មានសមត្ថភាពពេញលេញក្នុងការអនុវត្តសកម្មភាពរបស់ខ្លួន" |
| **ច្បាប់របស់រដ្ឋបាលដ្ឋាន** | • រដ្ឋធម្មនុញ្ញ និងច្បាប់ខេត្ត៖ ភាពខុសគ្នានៃប្រព័ន្ធរដ្ឋបាលមូលដ្ឋាន និងមុខងារចម្រុះនៃរដ្ឋបាលមូលដ្ឋាន | • រដ្ឋធម្មនុញ្ញ និងច្បាប់នៃរដ្ឋ៖ ភាពចម្រុះនៃប្រព័ន្ធរដ្ឋបាលមូលដ្ឋាន (ប៉ុន្តែបង្កើនភាពរួមបញ្ចូលគ្នា) |

| ចំណុច | ប្រទេសស្វីស | ប្រទេសអាល្លឺម៉ង់ |
|---|---|---|
| | • ភាពរឹងមាំនៃលទ្ធិប្រជាធិបតេយ្យ (ឧ. វេទិកាប្រជាពលរដ្ឋ គំនិតផ្តួចផ្តើម ការធ្វើប្រជាមតិក្នុងស្រុក) | • ផ្តោតលើលទ្ធិប្រជាធិបតេយ្យជាតំណាង ដែលមានការចូលរួមរបស់ប្រជាពលរដ្ឋ (ឧ.ការធ្វើប្រជាមតិ យន្តការបញ្ចប់មុខតំណែងអភិបាលក្រុង) |
| **រចនាសម្ព័ន្ធរដ្ឋបាលមូលដ្ឋាន** | • មានតែមួយប្រភេទ៖ ឃុំ<br>• ឆ្នាំ២០២២៖ ចំនួន ២.១៤៨ ក្រុង (មានប្រជាជនជាមធ្យមចំនួន ៤.០២១នាក់)<br>• គំនិតផ្តួចផ្តើមនៅមានកម្រិតចំពោះការបង្រួបបង្រួមឃុំបញ្ចូលគ្នា | • មានច្រើនប្រភេទ៖<br>– ឃុំ (Gemeinde)<br>– ស្រុក និង ក្រុងស្វយ័ត<br>– សមាគមក្រុង (Gemeindeverband ឬ Verbands-gemeinde)<br>• ឆ្នាំ២០២១៖ ឃុំចំនួន ១០.៧៨៩ (មានប្រជាជនជាមធ្យមចំនួន ៧.៧១៥នាក់), មានចំនួន ២៩៤ស្រុក និង១០៦ក្រុងស្វយ័ត (មានប្រជាជនជាមធ្យមចំនួន ២០៨.១០០នាក់)<br>• កំណែទម្រង់រដ្ឋបាលមូលដ្ឋានសំខាន់ៗនៅក្នុងឆ្នាំ១៩៧០ ១៩៩០ និងឆ្នាំ២000 ដល់ ២០១០(ការបង្រួបបង្រួមឃុំបញ្ចូលគ្នា ការប្រគល់មុខងារ) និងភាពខុសគ្នាពីរដ្ឋមួយទៅរដ្ឋមួយ។ |

| ចំណុច | ប្រទេសស្វីស | ប្រទេសអាល្លឺម៉ង់ |
|---|---|---|
| **លក្ខណៈនៃការផ្តល់សេវា** | បង្កើនកិច្ចសហប្រតិបត្តិការអន្តរក្រុងក្នុងវិស័យដូចជា ការចែកចាយទឹក ការធ្វើប្រព្រឹត្តិកម្មទឹកកខ្វក់ ការគ្រប់គ្រងសំរាមសំណល់រឹង សេវាអគ្គិភ័យជាដើម។ ការចូលរួមរបស់វិស័យឯកជនមានកម្រិត ក្នុងការផ្តល់សេវា ផ្តោតខ្លាំងលើតែការចូលរួមក្នុងការផ្តល់សេវាពីប្រជាពលរដ្ឋ | កិច្ចសហប្រតិបត្តិការអន្តរឃុំ (ឧទាហរណ៍ Zweck verbände/ សមាគមដែលបង្កើតឡើងសម្រាប់គោលបំណងពិសេស) ការចូលរួមរបស់វិស័យឯកជនក្នុងការផ្តល់សេវា |
| **មុខតំណែងប្រធានប្រតិបត្តិ** | • សមាសភាពពហុបក្សនៃក្រុមប្រឹក្សា<br>• ការបោះឆ្នោតដោយផ្ទាល់ ឬ ការបោះឆ្នោតដោយប្រយោលដោយក្រុមប្រឹក្សា<br>• អភិបាលគ្មានតួនាទីពីរឡើយ | • ការបោះឆ្នោតដោយផ្ទាល់ ឬ ការបោះឆ្នោតដោយប្រយោលដោយក្រុមប្រឹក្សា<br>• អភិបាលស្រុកមានតួនាទីពីរ ដែលជាតំណាងឱ្យរដ្ឋបាលរដ្ឋផងដែរ |
| **រចនាសម្ព័ន្ធផ្ទៃក្នុងនៃរដ្ឋបាលមូលដ្ឋាន** | • សន្និបាតក្រុង (សន្និបាតដែលប្រជាពលរដ្ឋទាំងអស់ដែលមានសិទ្ធិបោះឆ្នោត)<br>• បោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាដោយផ្ទាល់<br>• ក្រុមប្រឹក្សារដ្ឋបាលក្រុង ជានីតិប្រតិបត្តិនៃរដ្ឋបាលមូលដ្ឋាន (ក្រោមការមើលខុសត្រូវ អភិបាលក្រុង) | • បោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាមូលដ្ឋានដោយផ្ទាល់<br>• រដ្ឋបាលមូលដ្ឋាន ជាធម្មតាដឹកនាំដោយអភិបាល |

| ចំណុច | ប្រទេសស្វីស | ប្រទេសអាល្លឺម៉ង់ |
| --- | --- | --- |
| **ភារកិច្ច និង មុខងារ** | • មានសេរីភាពក្នុងការបំពេញភារកិច្ចទាំងឡាយណាដែលមិនត្រូវបានបែងចែកទៅឱ្យថ្នាក់រដ្ឋបាលផ្សេងទៀត<br>• ភារកិច្ចដែលបានផ្ទេរសិទ្ធិ<br>• រដ្ឋបាលមូលដ្ឋាន ដើរតួជាស្ថាប័នពហុគោលបំណង | • អាណត្តិទូទៅសម្រាប់កិច្ចការមូលដ្ឋាន (មុខងារជាកាតព្វកិច្ច និងមុខងារស្ម័គ្រចិត្ត)<br>• ភារកិច្ចដែលបានផ្ទេរសិទ្ធិ<br>• រដ្ឋបាលមូលដ្ឋានដើរតួជាស្ថាប័នពហុគោលបំណង |
| **ទំនាក់ទំនងតាមរយៈខ្សែបណ្តោយ** | • សន្និសីទត្រីភាគី (រវាងសហព័ន្ធ រដ្ឋ និងក្រុង)<br>• តួនាទីនយោបាយរបស់សមាគមនៃរដ្ឋបាលមូលដ្ឋាននៅកម្រិតរដ្ឋ និងសហព័ន្ធ<br>• កំណើននៃអាណត្តិបោះឆ្នោត (កម្រិតមូលដ្ឋាន រដ្ឋ និងសហព័ន្ធ) ដែលអាចទទួលយកបាន<br>• តួនាទីរបស់គណបក្សនយោបាយជាយានសម្រាប់ទំនាក់ទំនងខ្សែបណ្តោយ | • ចាប់តាំងពីឆ្នាំ២០០៦មក សហព័ន្ធមិនអនុញ្ញាតឱ្យផ្ទេរភារកិច្ចទៅឃុំឡើយ ដោយសារនៅតែជាសិទ្ធិរបស់រដ្ឋ។<br>• តួនាទីនយោបាយរបស់សមាគមនៃរដ្ឋបាលមូលដ្ឋាននៅកម្រិតរដ្ឋ និងសហព័ន្ធ<br>• កំណើននៃអាណត្តិបោះឆ្នោតញឹកញាប់រវាងកម្រិតមូលដ្ឋាន និងរដ្ឋ<br>• តួនាទីរបស់គណបក្សនយោបាយជាយានសម្រាប់ទំនាក់ទំនងខ្សែបណ្តោយ |
| **ស្ថានភាពហិរញ្ញវត្ថុ** | • គោលការណ៍នៃហិរញ្ញវត្ថុសមមូល (អ្នកណាអ្នកចំណាយអ្នកនោះជាអ្នកសម្រេច អ្នកណាជាអ្នក | • គោលការណ៍នៃការផ្សារភ្ជាប់ហិរញ្ញវត្ថុ (ការចាត់តាំងភារកិច្ចដែលសមស្របជាមួយធនធានហិរញ្ញវត្ថុ) |

| ចំណុច | ប្រទេសស៊ុយអែត | ប្រទេសអាល្លឺម៉ង់ |
|---|---|---|
| | សម្រេចអ្នកនោះជាអ្នកចំណាយ)<br>• ស្វ័យភាពហិរញ្ញវត្ថុ និងសារពើពន្ធទូលំទូលាយ | • ការផ្តល់ជំនួយផ្ទាល់ពីសហព័ន្ធដល់រដ្ឋបាលមូលដ្ឋានមិនត្រូវបានអនុញ្ញាតទេ<br>• ពឹងផ្អែកលើការផ្ទេរធនធានពីថ្នាក់រដ្ឋទៅថ្នាក់ឃុំ |
| **កំណែទម្រង់នៃប្រព័ន្ធ** | កំណែទម្រង់សហព័ន្ធក្នុងឆ្នាំ ២០០៨ និង២០២០ (សមភាពហិរញ្ញវត្ថុ ការពិនិត្យមើលនូវមុខងាររវាងកម្រិតសហព័ន្ធ និងរដ្ឋ និងកិច្ចសហប្រតិបត្តិការរវាងរដ្ឋ និងរដ្ឋ) | កំណែទម្រង់សហព័ន្ធនៅឆ្នាំ ២០០៦ (ការចាត់តាំងមុខងាររវាងកម្រិតសហព័ន្ធ និងរដ្ឋ) និងឆ្នាំ២០០៩ (ទំនាក់ទំនងហិរញ្ញវត្ថុរវាងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ)។ |

## ឃ. សេចក្តីសន្និដ្ឋាន

ជាលទ្ធផល គណៈប្រតិភូជាន់ខ្ពស់នៃព្រះរាជាណាចក្រកម្ពុជាបាន ទទួលនូវការយល់ដឹងខ្ពស់អំពីទម្រង់នៃការគ្រប់គ្រងតាមបែបវិមជ្ឈការ ព្រមទាំង បានរកឃើញនូវការអនុវត្តប្រកបដោយជោគជ័យមួយចំនួន ដែលអាចយកមក ផ្តួចផ្តើមគំនិតសម្រាប់កែលម្អការរៀបចំ និងការអនុវត្តក្នុងបរិបទកម្ពុជាផងដែរ។ ជាមួយគ្នានេះ ដំណើរទស្សនកិច្ចនេះ បានពង្រឹងទំនាក់ទំនងរវាងមន្ត្រីប្រទេស ស្វីស ប្រទេសអាល្លឺម៉ង់ និងមន្ត្រីប្រទេសកម្ពុជាដែលជាការពង្រឹងពង្រីកនូវ កិច្ចសហប្រតិបត្តិការនាពេលបច្ចុប្បន្ន និងនាពេលអនាគត។ កម្មវិធីសំខាន់ៗ នៃដំណើរទស្សនកិច្ចនេះ រួមមាន៖ ការជួបសម្តែងការគួរសមជាមួយមន្ត្រីជាន់ ខ្ពស់នៃរដ្ឋាភិបាលប្រទេសទាំងពីរ ការធ្វើទស្សនកិច្ចនៅការដ្ឋានអនុវត្តគម្រោង ការពិភាក្សាកម្រិតបច្ចេកទេសជាមួយអ្នករៀបចំគោលនយោបាយ និងមន្ត្រី រដ្ឋបាលមូលដ្ឋាន ព្រមទាំងការធ្វើបទបង្ហាញដ៏ក្បោះក្បាយបន្ថែមមួយចំនួនពី សំណាក់សាស្ត្រាចារ្យធ្វើឱ្យដំណើរទស្សនកិច្ចសិក្សាទៅកាន់ប្រទេសស្វីស និងប្រទេសអាល្លឺម៉ង់នេះ ប្រកបទៅដោយលទ្ធផលផ្លែផ្កា បានទទួលនូវការ យល់ដឹងច្រើន និងមានភាពទាក់ទាញ៕

ថ្ងៃ...ចន្ទ..១០កើត.....ខែអាសាឍ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី..១៥... ខែកក្កដា ឆ្នាំ២០២៤

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**និងជាប្រធាន គ.ជ.អ.ប.**

**អភិសន្តិបណ្ឌិត ស សុខា**

គជអប
NCDD

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍ
តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ


ក្រសួងមហាផ្ទៃ
Ministry of interior Cambodia

ផ្លូវព្រះនរោត្តម សង្កាត់ទន្លេបាសាក់
ខណ្ឌចំការមន រាជធានីភ្នំពេញ

interior.gov.kh

info@interior.gov.kh

ស្កេនដើម្បីទាញឯកសារ

www.facebook.com/ncdds

ផ្លូវព្រះនរោត្តម សង្កាត់ទន្លេបាសាក់
ខណ្ឌចំការមន រាជធានីភ្នំពេញ

www.ncdd.gov.kh

info@ncdd.gov.kh


ស្កេនដើម្បីទាញឯកសារ